មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

OMCT
SOS-Torture Network

# ការដាក់ស្នើបន្ថែម ទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្ស នៅមុនពេលត្រួតពិនិត្យលើកទីពីររបស់កម្ពុជា

ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥

ផ្តោតលើបញ្ហា ១,២,៣,៤,៥,៨,៩,១៥,១៧,១៨,១៩,២០,២១,២៣ និង ២៦

# មាតិកា

១. ក្របខណ្ឌរដ្ឋធម្មនុញ្ញ និងច្បាប់ដែលកតិកាសញ្ញានេះត្រូវបានអនុវត្ត (មាត្រា ២ នៃ ក.អ.ស.ព.ន) ........................ 4
ក. ពុំមានការអនុវត្ត ក.អ.ស.ព.ន នៅក្នុងតុលាការក្នុងស្រុក ........................................................................ 4
ខ. ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យនៅមិនទាន់បង្កើត.................................................................................. 5
២. ការមិនរើសអើង និងសមភាព (មាត្រា ២ កថាខណ្ឌទី ១, មាត្រា ៣ មាត្រា ២៦ និងមាត្រា ២៧ នៃ ក.អ.ស.ព.ន).. 7
ក. ការថយចុះនៃចំនួនស្ត្រីជាតំណាងក្នុងរដ្ឋសភា......................................................................................... 7
ខ. ភាសាបែបស្អប់ខ្ពើមចំពោះជនជាតិវៀតណាម ............................................................................................ 9
គ. កង្វះបញ្ញត្តិច្បាប់ប្រឆាំងនឹងការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នា ស្តីពីបទល្មើសស្អប់ខ្ពើម និងវិស័យការងារ 9
ឃ. ការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រលាញ់ភេទដូចគ្នា ..................................................................... 11
៣. សិទ្ធិរស់រានមានជីវិត និងការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (មាត្រា ២ កថាខណ្ឌទី ៣ មាត្រា ៦ មាត្រា ៧ មាត្រា ២១ នៃ ក.អ.ស.ព.ន) ..........................12
ក. ការឃាយីផ្នែកច្បាប់ និងវាយប្រហារមកលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជន និង កង្វះខាតគណនេយ្យភាព ក្នុងការបំពានពីសំណាក់ក្រុមហ៊ុនឯកជន ......................................................................12
ខ. ការប្រើប្រាស់កម្លាំងហួសហេតុពីសំណាក់មន្ត្រីនគរបាល និងកងកម្លាំងសន្តិសុខ ក្នុងអំឡុងការធ្វើបាតុកម្ម..........14
គ. មន្ត្រីនគរបាល និងកងកម្លាំងសន្តិសុខខណ្ឌដូនពេញប្រព្រឹត្តទង្វើដែលពោរពេញដោយនិទណ្ឌភាព....................17
៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ភាពស្មើគ្នាចំពោះមុខច្បាប់ សំណង និងការគ្រប់គ្រងនៃប្រព័ន្ធតុលាការ (មាត្រា ៧ មាត្រា ១៤ និង មាត្រា ២៦ នៃ ក.អ.ស.ព.ន) .........................................................................19
ក. ការជ្រៀតជ្រែកមិនស្របច្បាប់របស់រដ្ឋាភិបាលក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ...........................19
ខ. កង្វះខាតឯករាជ្យភាពក្នុងប្រព័ន្ធតុលាការទាំងស្រុង................................................................................ 20
គ. កង្វះខាតវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ និងធនធានដែលធ្វើឲ្យគុណភាពនៃការកាត់ក្តីធ្លាក់ចុះ..........................22
ឃ. ការបង្ខិតបង្ខំឲ្យសារភាព និងកង្វះខាតមធ្យោបាយសមស្របក្នុងការស៊ើបអង្កេត ..........................................24
៥. សេរីភាពខាងការបញ្ចេញមតិ និងខាងសមាគម និងសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី (មាត្រា ១៩ មាត្រា ២១ និង មាត្រា ២២ នៃ ក.អ.ស.ព.ន)...........................................................................................................26
ក. ក្រមព្រហ្មទណ្ឌថ្មីបានពង្រីកវិសាលភាពគ្រប់ដណ្តប់លើបទបរិហាកេរ្តិ៍ ស្របពេលជាមួយនឹងមោឃភាពនៃការតស៊ូដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ...............................................................................................26
ខ. ការឃាយីលើអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិដីធ្លី .......................................................................28
គ. ការកើនឡើងនៃការចាប់ខ្លួន និងចោទប្រកាន់ពាក់ព័ន្ធនឹងបញ្ហានយោបាយ......................................................29
ឃ. ការបដិសេធនូវសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី ..............................................................................................31

ង. ការគំរាមកំហែង និងការឃុំខ្លួនតាមទំនើងចិត្ត ដើម្បីមិនឲ្យអ្នកការពារសិទ្ធិមនុស្សធ្វើបាតុកម្ម ........................ 33
ច. ស្ថានភាពនៃច្បាប់អង្គការ និងច្បាប់សហជីពដ៏ចម្រូងចម្រាស់ នៅតែមិនច្បាស់លាស់ .....................................36
៦. សិទ្ធិកុមារ (មាត្រា ៧ និង មាត្រា ២៤ នៃ ក.អ.ស.ព.ន) ........................................................................38
ក. កង្វះខាតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កុមារ ...............................................................38
៧. ការចូលរួមក្នុងកិច្ចការសាធារណៈ (មាត្រា ២៥ នៃ ក.អ.ស.ព.ន) ...............................................................41
ក. កង្វះខាតឯករាជ្យភាពនៃគណៈកម្មការជាតិបោះឆ្នោត........................................................................41
ខ. ការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិរបស់អង្គការ ក្នុងអំឡុងការបោះឆ្នោត.......................................42
៨. អំពីអង្គភាពដែលបានដាក់ស្នើរបាយការណ៍នេះ ..........................................................................44

## ១. ក្របខណ្ឌរដ្ឋធម្មនុញ្ញ និងច្បាប់ដែលកតិកាសញ្ញានេះត្រូវបានអនុវត្ត (មាត្រា ២ នៃ ក.អ.ស.ព.ន)

### ក. ពុំមានការអនុវត្ត ក.អ.ស.ព.ន នៅក្នុងតុលាការក្នុងស្រុក

*បញ្ហាទី ១. សូមផ្តល់ឧទាហរណ៍ ប្រសិនបើមាន ក្នុងករណីដែលបញ្ញត្តិនៅក្នុងកតិកាសញ្ញាត្រូវបានអនុវត្តដោយផ្ទាល់ ឬក៏ប្រើប្រាស់ដោយតុលាការជាជំនួយក្នុងការបកស្រាយច្បាប់ក្នុងស្រុក។ សូមផ្តល់ព័ត៌មានបន្ថែមស្តីពីវគ្គបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្សដែលបានរៀបចំឡើង សម្រាប់ចៅក្រម និងមន្ត្រីអនុវត្តច្បាប់ដោយគោរពទៅតាមបញ្ញត្តិដែលមានក្នុងកតិកាសញ្ញា (អត្ថបទទី ២៨ នៃរបាយការណ៍របស់រដ្ឋ)*

យោងតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ក៏ដូចជានៅក្នុងសេចក្តីសម្រេចកាលពីខែកក្កដា ឆ្នាំ២០០៧ នៃក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ (សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧) អនុសញ្ញាអន្តរជាតិទាំងអស់ជាផ្នែកនៃច្បាប់ជាតិ ហើយតុលាការគួរតែពិចារណាវិធាននៃអនុសញ្ញាទាំងនោះ ក្នុងពេលដែលបកស្រាយច្បាប់ និងសម្រេចក្តីណាមួយ។ ប៉ុន្តែ ម.ស.ម.ក បានសង្កេតឃើញថា បើទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌរបស់ ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងរដ្ឋធម្មនុញ្ញ ដូចជាបានរួមបញ្ចូលគោលបំណងនៃកតិកាសញ្ញា ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែងប្រព័ន្ធយុត្តិធម៌មិនបានពិចារណានូវបញ្ញត្តិណាមួយនៃកតិកាសញ្ញាអន្តរជាតិផ្សេងៗនោះទេ មិនតែប៉ុណ្ណោះ ក្នុងករណីជាច្រើនថែមទាំងមិនបានអនុលោមទៅតាមបញ្ញត្តិនៃកតិកាសញ្ញាទៀតផង។ ក្នុងពេលដែលអនុវត្តសកម្មភាពសង្កេតការណ៍សវនាការជាប្រចាំថ្ងៃ[1] ដើម្បីកត់ត្រានូវរាល់សកម្មភាពរបស់សាលាឧទ្ធរណ៍ និងកម្រិតដែលសាលាក្តីនេះគោរពលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ម.ស.ម.ក បានសង្កេតឃើញថាតុលាការក្នុងស្រុក កម្រនឹងប្រើប្រាស់កតិកាសញ្ញាជាជំនួយនៅពេលដែលបកស្រាយបញ្ញត្តិច្បាប់ក្នុងស្រុក និងមិនដែលអនុវត្តដោយផ្ទាល់នោះទេ។ ក្នុងករណីចំនួន ៣៤០ ករណីដែល ម.ស.ម.ក បានសង្កេត ក្នុងចន្លោះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤ មានតែករណីមួយប៉ុណ្ណោះដែលតុលាការបានយោងលើ ក.អ.ស.ព.ន។

ក្នុងរបាយការណ៍រដ្ឋលើកទី ២ បានបញ្ជាក់ថាការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ("ក.ឧ.អ.ស.ប.ទ.ស") បានសហការណ៍ជាមួយនឹង គណៈកម្មាធិការជាតិសិទ្ធិមនុស្ស ដើម្បីរៀបចំសិក្ខាសាលាបណ្តុះបណ្តាលជាបន្តបន្ទាប់ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដល់មន្ត្រីមកពី ១៥ ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ផ្សេងៗគ្នា ចន្លោះចាប់ពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៩ និងថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១១។ យោងតាម

[1] គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បង្កើតឡើង ដើម្បីតាមដានសវនាការព្រហ្មទណ្ឌក្នុងតុលាការកម្ពុជា និងដើម្បីវាយតម្លៃការគោរពតាមបទដ្ឋានសិទ្ធិទទួលបានយុត្តិធម៌របស់តុលាការទាំងនោះ។ ចាប់តាំងពីថ្ងៃសម្ពោធគម្រោង ក្នុងខែសីហា ឆ្នាំ២០០៩ ដល់ ចុង ឆ្នាំ២០១២ គម្រោងបានផ្តោតទៅលើការសង្កេតការណ៍នៅសាលាដំបូងរាជធានីភ្នំពេញ និងតុលាការខេត្តកណ្តាល ខេត្តបន្ទាយមានជ័យ និងខេត្តរតនៈគិរី។ តាំងពីខែមីនា ឆ្នាំ២០១៣ ដោយមានទស្សនៈក្នុងការវាយតម្លៃរបៀបដែលបទដ្ឋានសិទ្ធិទទួលបានជំនុំជម្រះដោយយុត្តិធម៌ត្រូវបានអនុវត្តក្នុងកម្រិតខ្ពស់ជាងនេះ គម្រោងបានចាប់ផ្តើមតាមដានតែក្នុងសាលាឧទ្ធរណ៍នៃរាជធានីភ្នំពេញតែប៉ុណ្ណោះ។ ក្នុងវិសាលភាពនេះ គម្រោងបានបង្កើតនូវ បញ្ជីត្រួតពិនិត្យ ជាបទដ្ឋានមួយ។
http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=project_profile.php&id=3&pro=TMP&pro_id=8&show=show

របាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការ អង្គការសហប្រជាជាតិ ស្តីពី "តួនាទី និងសមិទ្ធិផល របស់ ក.ឧ.អ.ស.ប.ទ.ស ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស" ដាក់ស្នើទៅកាន់ ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងអំឡុងពេលនោះ ក.ឧ.អ.ស.ប.ទ.ស បានរៀបចំវគ្គបណ្តុះបណ្តាលតែមួយគត់ស្តីពី អ.ក.ស.ព.ន ដល់បុគ្គលិក គណៈកម្មាធិការជាតិសិទ្ធិមនុស្ស និងក្រុមស្នូលមកពីក្រសួងពាក់ព័ន្ធដើម្បីជួយ គណៈកម្មាធិការជាតិសិទ្ធិមនុស្ស ធ្វើសេចក្តីព្រាងរបាយការណ៍ ក.អ.ស.ព.ន។[2] មិនមានអ្វីបានបញ្ជាក់ថាតើចៅក្រម មន្ត្រីអនុវត្តច្បាប់ និងក្រសួងពាក់ព័ន្ធ ដូចជា ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សជាក់លាក់បានកម្រិតណានោះទេ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ដាក់ជូនរដ្ឋាភិបាល ៖*

- *បន្តធ្វើការងារជាមួយ ក.ឧ.អ.ស.ប.ទ.ស និងសង្គមស៊ីវិល ដើម្បីធានាថាចៅក្រម និងមន្ត្រីអនុវត្តច្បាប់បានទទួលវគ្គបណ្តុះបណ្តាលជាក់លាក់ ស្តីពី បញ្ញត្តិនៅក្នុងកតិកាសញ្ញា និងការអនុវត្តរបស់បញ្ញត្តិទាំងនោះ*
- *ផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមទី ១ នៃ ក.អ.ស.ព.ន ដែលអនុញ្ញាតឲ្យឯកត្តបុគ្គល ឬក្រុមដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការសិទ្ធិមនុស្សដោយផ្ទាល់។*

## ខ. ស្ថាប័នសិទ្ធិមនុស្សជាតិឯករាជ្យនៅមិនទាន់បង្កើត

***បញ្ហាទី ២. តើមានវិធានការណាដែលបានអនុម័តដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិដែលឯករាជ្យ ដោយស្របតាមគោលការណ៍ ដែលពាក់ព័ន្ធនឹងស្ថាប័នថ្នាក់ជាតិ ដើម្បីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ក្រុងប៉ារីស សេចក្តីសម្រេចរបស់មហាសន្និបាត ៤៨/១៣៤ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ("គោលការណ៍ក្រុងប៉ារីស")***

ថ្វីបើមានការព្រួយបារម្ភលើកឡើងដោយគណៈកម្មាធិការនេះនៅក្នុង "***សេចក្តីសន្និដ្ឋាន***បញ្ចប់" ទៅលើរបាយការណ៍ដំបូងរបស់កម្ពុជាក្នុងខែកក្កដា ឆ្នាំ១៩៩៩[3] ការថ្លែងគាំទ្ររបស់ លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងឆ្នាំ២០០៦[4] ការទទួលយកអនុសាសន៍របស់កម្ពុជាជាបន្តបន្ទាប់ ក្នុងការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សជាតិ (ស.ស.ជ) ស្របទៅតាមគោលការណ៍ទីក្រុងប៉ារីស ក្នុងអំឡុងពេលការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ ជុំ ទី១[5] និងជុំទី ២[6] និងកិច្ច

---

[2] របាយការណ៍នៃអង្គលេខាធិការ តួនាទី និងការសម្រេចបានរបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ជួយដល់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស A/HRC/15/47 ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។

[3] គណៈកម្មាធិការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ពិចារណាលើរបាយការណ៍ដែលដាក់ដោយភាគីរដ្ឋ ក្រោមមាត្រា ៤០ នៃកតិកា ការសង្កេតការណ៍បញ្ចប់របស់គណៈកម្មាធិការសិទ្ធិមនុស្ស CCPR/C/79/Add.108 ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩ ៖ http://tbinternet.ohchr.org/_layouts/treatybodyexternal/Download.aspx?symbolno=CCPR/C/79/Add.108&Lang=En.

[4] 'ហ៊ុន សែន ប្រកាសគាំទ្រស្ថាប័នសិទ្ធិមនុស្សឯករាជ្យ' *Friedrich-Naumann-Stiftung für die Freiheit*: http://www.freiheit.org/News/1322c14853i1p/index.html; សូមមើលបន្ថែម៖ 'ស្ថាប័នសិទ្ធិមនុស្សជាតិសម្រាប់កម្ពុជា' ក្រុមការងារសម្រាប់យន្តការសិទ្ធិមនុស្សអាស៊ាន ៖ http://www.aseanhrmech.org/news/national-human-rights-insitution-for-cambodia.html.

[5] 'ការឆ្លើយតបចំពោះអនុសាសន៍ ៖ កម្ពុជា' យូភីអ អ៊ីនហ្វូ: http://www.upr-info.org/sites/default/files/document/cambodia/session_6_-_november_2009/recommendationstocambodia2009.pdf.

ពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយសង្គមស៊ីវិល[7] ក៏ដោយ ក៏រដ្ឋាភិបាលមិនទាន់បានបង្ហាញសេចក្តីព្រាងច្បាប់ក្នុងការបង្កើត ស.ស.ជ ដែលអនុលោមទៅតាមគោលការណ៍ទីក្រុងប៉ារីសនៅឡើយទេ។

ស្ថាប័នជាច្រើនត្រូវបានបង្កើតនៅកម្ពុជា ដោយមានអាណត្តិការងាររបស់ខ្លួនក្នុងការដោះស្រាយលើពាក្យបណ្តឹងស្តីពីការរំលោភបំពានសិទ្ធិមនុស្ស[8] ប៉ុន្តែមិនទាន់មានស្ថាប័នណាមួយដែលទទួលស្គាល់ដោយ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ សម្រាប់ស្ថាប័នសិទ្ធិមនុស្សជាតិនៅឡើយទេ។ ម.ស.ម.ក បានកត់សម្គាល់ចំពោះសេចក្តីថ្លែងការណ៍របស់ សាស្ត្រាចារ្យ សុរិយា ស៊ូបេឌី អ្នករាយការណ៍ពិសេសទទួលបន្ទុកលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងការបញ្ចប់ទស្សនកិច្ចលើកចុងក្រោយរបស់លោកនៅក្នុងប្រទេសថា រដ្ឋាភិបាលមានបំណងបន្តកិច្ចខំប្រឹងប្រែងរបស់ខ្លួនដើម្បីបញ្ចប់ច្បាប់ដែលលើកឡើងពី ស្ថាប័នសិទ្ធិមនុស្សជាតិដ៏ឯករាជ្យ ប៉ុន្តែមិនបានដឹងថាមានចាត់វិធានការណាមួយដើម្បីធ្វើរឿងនេះនោះទេ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

*ចាត់វិធានការភ្លាមៗដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ឲ្យស្របតាមគោលការណ៍ទីក្រុងប៉ារីស។*

---

[6] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ផ្នែកបន្ថែមនៃរបាយការណ៍ក្រុមការងារ នៃ ការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់, កម្ពុជា ៖ ទស្សនៈលើការបញ្ចប់ និង/ឬ អនុសាសន៍ ការប្តេជ្ញាចិត្តដោយស្ម័គ្រចិត្ត និងការឆ្លើយតបដែលតំណាងដោយរដ្ឋដែលត្រូវបានត្រួតពិនិត្យ A/HRC/26/16/Add.1 ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០១៤ ៖ : http://lib.ohchr.org/HRBodies/UPR/Documents/Session18/KH/A_HRC_26_16_Add.1_Cambodia_E.doc

[7] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ មតិយោបល់ទទួលពីរដ្ឋាភិបាលកម្ពុជាស្តីពីរបាយការណ៍ របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្ស នៅកម្ពុជា សាស្ត្រាចារ្យសុរិយា ស៊ូបេឌី A/HRC/27/70/Add.1, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ៖ http://cambodia.ohchr.org/WebDOCs/DocReports/3-SG-RA-Reports/Comments_from_the_Govt_of_Cambodia_to_the_SR_Report-17Sept2014.pdf.

[8] ម.ស.ម.ក ‘កម្រងឯកសារផ្នែកស្ថាប័ន ៖ ស្ថាប័នសិទ្ធិមនុស្សជាតិនៅកម្ពុជា’ (ឆ្នាំ ២០១២), http://www.cchrcambodia.org/admin/media/factsheet/factsheet/english/2012_03_30_CCHR_Institutions_Series_Factsheet_National_Human_Rights_Bodies_ENG.pdf.

## ២. ការមិនរើសអើង និងសមភាព (មាត្រា ២ កថាខណ្ឌទី ១, មាត្រា ៣ មាត្រា ២៦ និងមាត្រា ២៧ នៃ ក.អ.ស.ព.ន)

### ក. ការថយចុះនៃចំនួនស្ត្រីជាតំណាងក្នុងរដ្ឋសភា

*បញ្ហាទី ៣. ពាក់ព័ន្ធនឹងព័ត៌មានដែលបានផ្តល់ឲ្យក្នុងកថាខណ្ឌទី ៥៦ ដល់ ៦០ នៅក្នុងរបាយការណ៍រដ្ឋភាគី សូមពណ៌នាវិធានការជាក់លាក់ដែលត្រូវបានអនុម័ត ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ និងគោលនយោបាយប្រកបដោយប្រសិទ្ធភាព ក្នុងការបង្កើតឲ្យមានសមភាពយេនឌ័រ និងធានាការចូលរួមរបស់ស្ត្រីក្នុងវិស័យផ្សេងៗក្នុងជីវភាពសាធារណៈ។ សូមផ្តល់ព័ត៌មានជាលម្អិតស្តីពីភាពខុសគ្នារវាងអត្រាការងាររបស់បុរស និងស្ត្រី និងចន្លោះប្រាក់ឈ្នួលផ្អែកលើយេនឌ័រ។ តើរដ្ឋភាគីមានផែនការដើម្បីជម្នះឧបសគ្គដែលរារាំងស្ត្រីក្នុងការចូលរួមយ៉ាងពេញលេញ និងបង្កើនសមត្ថភាពនៅក្នុងកន្លែងការងារហើយឬនៅ? សូមបញ្ជាក់ថាតើមានវិធានការមានស្រាប់ណាខ្លះដែលលើកកម្ពស់ ភាពជាតំណាងយ៉ាងស្មើភាពគ្នារបស់ស្ត្រីក្នុងតំណែងជាអ្នកសម្រេចចិត្ត ទាំងក្នុងកិច្ចការសាធារណៈ និងផ្នែកឯកជន។ សូមបង្ហាញនូវរាល់វិធានការទាំងឡាយដែលបានរៀបចំឡើងដើម្បីលុបបំបាត់ផ្នត់គំនិតយេនឌ័រ និងពង្រឹងការបញ្ជ្រាបទស្សនៈយេនឌ័រទៅក្នុងកម្មវិធីអប់រំ និងសៀវភៅសិក្សា?*

ទោះបីជា រដ្ឋាភិបាលបានព្រមទទួល ក.អ.ស.ព.ន និងកតិកាសញ្ញាដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ និងរដ្ឋធម្មនុញ្ញ និងមានច្បាប់ក្នុងស្រុកដទៃទៀតដែលការពារប្រជាពលរដ្ឋដោយបើកចំហ ប្រឆាំងនឹងការរើសអើងដោយផ្អែកលើយេនឌ័រ ប៉ុន្តែបញ្ហានៅតែកើតមានយ៉ាងខ្លាំង។[9] ខណៈពេលដែល រដ្ឋាភិបាលបានបង្កើតគោលនយោបាយថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងស្ថាប័នសម្រេចចិត្តសាធារណៈ "ស្ត្រីនៅកម្ពុជានៅតែមានភាពជាតំណាងតិចតួច ក្នុងតួនាទីសម្រេចចិត្តនៅក្នុងវិស័យនយោបាយ វិស័យសាធារណៈ និងវិស័យតុលាការ"។[10] ថ្វីបើមានការកើនឡើងតិចតួចនៃចំនួនភាពជាអ្នកតំណាងនៅក្នុងស្ថាប័នសាធារណៈថ្នាក់មូលដ្ឋានមួយចំនួន ដូចជា ក្រុមប្រឹក្សារាជធានី និងខេត្ត[11] បន្ទាប់ពីការបោះឆ្នោតជាតិកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៣ ភាគរយស្ត្រីក្នុងរដ្ឋសភាបានថយចុះជាលើកទីមួយ ក្នុងរយៈពេល ២០ ឆ្នាំ គឺពី ២២% ចុះមកត្រឹម ២០,៣៣%។ ដូច្នេះ ទីដៅ ៣.៨ នៃគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា ដើម្បីបង្កើនភាគរយចំនួនអាសនៈដែលកាន់កាប់ដោយស្ត្រី ក្នុងរដ្ឋសភាចាប់ពី ១២% ក្នុង ឆ្នាំ ២០១៣ រហូតដល់ ៣០% ក្នុងឆ្នាំ២០១៥ មិនទាន់សម្រេចបាននៅឡើយទេ។[12]

---

[9] គោលនយោបាយសង្ខេបរបស់ក្រសួងកិច្ចការនារី 'ទំនាក់ទំនងយេនឌ័រ និងឥរិយាបថ ៖ ការវាយតម្លៃផ្នែកយេនឌ័រនៅកម្ពុជា' ខែធ្នូ ឆ្នាំ២០១៤ ៖ https://drive.google.com/a/cchrcambodia.org/file/d/0B4FIfh9WosCGTUFLMnQ0Yms5STg/view.

[10] ក្រសួងកិច្ចការនារី 'នារីរតនៈ ៤' ខែធ្នូ ឆ្នាំ២០១៤ ទំព័រទី ១២ ៖ http://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Cambodian%20Gender%20Strategic%20Plan%20-%20Neary%20Rattanak%204_Eng.pdf.

[11] ដូចខាងលើ, ទំព័រទី ១២។

[12] ម.ស.ម.ក 'នយោបាយក្នុងព្រះរាជាណាចក្រ ៖ បង្កើនតំណាងស្ត្រីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ - ខែតុលា ឆ្នាំ២០១៣' (២០១៣) ៖ http://cchrcambodia.org/admin/media/report/report/english/CCHR_BOOKLET_National%20Election%20Assembly%202013_FINAL%20ENG.pdf.

នៅក្នុងខែមិថុនា ឆ្នាំ២០១២ ក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ ស្ត្រីដែលជាប់ឆ្នោតក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាមានចំនួន ១៧,៧៩% (ស្មើនឹង ២.០៣៨ អាសនៈ)[13] ដែលកើនឡើងពី ១៤,៦៤% ក្នុងការបោះឆ្នោតឆ្នាំ ២០០៧ (ស្មើនឹង ១.៦៦២ អាសនៈ) និង៨,៤% ក្នុង ឆ្នាំ២០០២ (ស្មើនឹង ៩៥៤ អាសនៈ)។[14] ថ្វីបើមានការកើនឡើងនេះក៏ដោយ ក៏ចំនួនតំណាងរបស់ស្ត្រីក្នុងពេលបច្ចុប្បន្ននៅថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅឆ្ងាយពីទីដៅ ៣.១៥ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងគោលដៅនៃនារីរតនៈ៣ សម្រាប់ឆ្នាំ ២០១៥ ដែលមានបំណងចង់បង្កើនចំនួនអាសនៈនៅថ្នាក់ឃុំ សង្កាត់ឲ្យបាន ២៥ %។ ជាទូទៅភាគរយបេក្ខជនស្ត្រីនៅក្នុងបញ្ជីបេក្ខជនបម្រុងមានចំនួនច្រើនជាង នៅក្នុងបញ្ជីបេក្ខជនពេញសិទ្ធិ ហើយដែលស្ត្រីភាគច្រើនដាក់នៅលេខរៀងខាងក្រោមនៅក្នុងបញ្ជី ដែលនេះបញ្ជាក់ថាគណបក្សនយោបាយមើលឃើញស្ត្រីគឺជាជម្រើសទីពីរបន្ទាប់ពីបុរស ក្នុងពេលដែលពិចារណាពីភាពដឹកនាំផ្នែកនយោបាយ។ នៅថ្នាក់ជាតិ ស្ត្រីតែងតែផ្តល់មុខតំណែងមិនសូវសំខាន់ ដូចជាមុខតំណែងដែលមានអំណាចក្នុងការសម្រេចចិត្ត និងធ្វើថវិកាបន្តិចបន្តួចតែប៉ុណ្ណោះ។[15]

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ដាក់ជូនរដ្ឋាភិបាល ៖*

- *ទទួលយកកូតាយេនឌ័រជាចាំបាច់នូវចំនួនអប្បបរមា ៣០% នៃបញ្ជីបេក្ខជនសម្រាប់ការបោះឆ្នោតដោយផ្ទាល់ ដោយដាក់បន្ថែមប្រព័ន្ធ "បញ្ជីឆ្លាស់" ដែលតម្រូវឲ្យគណបក្សនយោបាយដាក់ឈ្មោះបេក្ខជនបុរស និងបេក្ខជនស្ត្រីឆ្លាស់គ្នានៅលើបញ្ជីឈ្មោះបេក្ខជន។*
- *ទទួលយកជាចាំបាច់នូវអាសនៈបម្រុងយ៉ាងហោចណាស់មួយភាគបី នៃអាសនៈព្រឹទ្ធសភាសម្រាប់ស្ត្រី ដោយក្រុមប្រឹក្សាទាំងអស់បោះឆ្នោតទៅលើបញ្ជីដាច់ដោយឡែកពីគ្នា បញ្ជីមួយសម្រាប់បេក្ខជនបុរស និងបញ្ជីមួយទៀតសម្រាប់បេក្ខជនស្ត្រី*
- *លើកយកមកពិចារណានូវលិខិតបទដ្ឋានដាច់តែឯង និងទូលំទូលាយ ដើម្បីដោះស្រាយលើបញ្ហាការរើសអើងដោយផ្អែកលើយេនឌ័រ ដែលរួមបញ្ចូលទាំងនិយមន័យនៃការរើសអើងដោយផ្អែកលើយេនឌ័រទាំងដោយផ្ទាល់ និងមិនផ្ទាល់ យោងតាមមាត្រា ១ នៃកតិកាសញ្ញាដើម្បីកាត់បន្ថយរាល់ទម្រង់នៃការរើសអើងលើនារីភេទ (ស៊ី.ដ) ការដាក់ទោសទណ្ឌសម្រាប់ជនល្មើសប្រព្រឹត្តការរើសអើង និងយន្តការសម្រាប់ផ្តល់សំណងជូនដល់ជនរងគ្រោះ។*

---

[13] ទិន្នន័យពេញ អាចរកបាននៅលើគេហទំព័រសិទ្ធិមនុស្ស របស់ ម.ស.ម.ក Sithi.org, at: http://sithi.org/temp.php?url=commune/commune_election.php&tab_id=2&lg=.

[14] ម.ស.ម.ក 'នយោបាយក្នុងព្រះរាជាណាចក្រ ៖ បង្កើនតំណាងស្ត្រី' (ឆ្នាំ ២០១៣), page 22: http://www.cchrcambodia.org/admin/media/report/report/english/2013_03_28_CCHR_Report_eng.pdf.

[15] តាមរយៈការមើលទៅលើការបែងចែកតួនាទីក្នុងរដ្ឋាភិបាល ក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ ចំនួនស្ត្រីដែលជារដ្ឋមន្ត្រីជាន់ខ្ពស់ ថយចុះពី ៦,៦៦% ក្នុងឆ្នាំ ២០០៣ ទៅ 0% ក្នុងឆ្នាំ២០១៣។ ចំណុចនេះនាំឲ្យមានការខកចិត្តជាខ្លាំង ដោយសារថាតួនាទីនោះ ជាតួនាទីថ្នាក់ខ្ពស់បំផុតក្នុងរដ្ឋាភិបាល។ ក្នុង ឆ្នាំ២០១៣ ចំនួនស្ត្រី ដែលបានតែងតាំងក្នុងតួនាទី ឧបនាយករដ្ឋមន្ត្រី មានចំនួនស្មើនឹងចំនួនកាលពី ឆ្នាំ២០០៨ គឺ ១១,១១%។ ចំណុចនេះ ក៏បង្ហាញយ៉ាងច្បាស់ផងដែរថា ចំនួនស្ត្រីដែលត្រូវតែងតាំងក្នុងថ្នាក់រដ្ឋមន្ត្រី គឺមិនផ្លាស់ប្តូរតាំងពី ឆ្នាំ១៩៩៨ (ចាប់ពី ៧,៤% ទៅ ៧.៨៩%)។ ប៉ុន្តែ មានដំណើរការមួយចំនួន ពាក់ព័ន្ធនឹងការតែងតាំងស្ត្រីក្នុងតំណែងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ដែលមានការតែងតាំងស្ត្រីរហូតដល់ ២០,២២% នៃតំណែងទាំងអស់ក្នុង ឆ្នាំ២០១៣ ធៀបទៅនឹង ៨,០៨% ក្នុង ឆ្នាំ ២០០៨។ ទិន្នន័យពេញ អាចមើលបាន ៖ http://cchrcambodia.org/admin/media/report/report/english/CCHR_BOOKLET_National%20Election%20Assembly%202013_FINAL%20ENG.pdf.

## ខ. ភាសាបែបស្អប់ខ្ពើមចំពោះជនជាតិវៀតណាម

*បញ្ហាទី ៤. សូមផ្តល់មតិយោបល់លើរបាយការណ៍ពាក់ព័ន្ធនឹងទស្សនៈប្រឆាំងនឹងជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជា និងឧទាហរណ៍ ដែលទស្សនៈទាំងនេះត្រូវបានប្រើប្រាស់ដើម្បីកេងចំណេញខាងនយោបាយ។ តើរដ្ឋភាគីមានបំណងបង្កើតផែនការសកម្មភាពថ្នាក់ជាតិប្រឆាំងនឹងការរើសអើងពូជសាសន៍ដែរឬទេ?*

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣ ម.ស.ម.ក បានចេញផ្សាយលិខិតចំហ[16] លើកឡើងពីភាសាម៉ាក់ងាយ និងរើសអើងរបស់លោក សម រង្ស៊ី ដែលជាប្រធានគណបក្សប្រឆាំង គណបក្សសង្គ្រោះជាតិកម្ពុជា (គ.ស.ជ) ក្នុងសុន្ទរកថារបស់លោកនៅខេត្តសៀមរាប កាលពីថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០១៣។ ក្នុងអំឡុងពេលដង្ហែក្បួន លោក រង្ស៊ី បានលើកយកបញ្ហាអន្តោប្រវេសន៍របស់ជនជាតិវៀតណាមចូលមកកម្ពុជា ដោយហៅជនជាតិវៀតណាមថា "យួន" ដែលជាពាក្យចម្រូងចម្រាស់ ជាទូទៅតែងតែប្រើនៅពេលដែលប្រើជាភាសាបែបស្អប់ខ្ពើម ជាពិសេសប្រើប្រាស់ក្នុងសម្តីប្រឆាំងនឹងជនជាតិវៀតណាម ឬប្រជាជនកម្ពុជាដែលមានដើមកំណើតជាជនជាតិវៀតណាម។ បន្ទាប់ពីមានការចេញផ្សាយលិខិតនេះ ម.ស.ម.ក ជាពិសេស ប្រធានអង្គភាពដែលពេលនោះគឺ លោក អ៊ូ វីរៈ ទទួលបានសារបែបស្អប់ខ្ពើម និងការគំរាមកំហែងជាច្រើន រួមទាំងការគំរាមសម្លាប់ តាមរយៈអ៊ីម៉ែល និងបណ្តាញសង្គម អះអាងថាពាក្យ "យួន" មិនមែនជាពាក្យបែបស្អប់ខ្ពើមនោះទេ។[17] សមាជិក គ.ស.ជ បានរាយការណ៍ថាបានបន្តការពារការប្រើប្រាស់ពាក្យ "យួន" ដោយប្រកែកថាពាក្យនេះមិនមែនពាក្យបែបស្អប់ខ្ពើមនោះទេ[18] ក្នុងចំណោមការរីករាលដាលនៃទស្សនៈប្រឆាំងលើជនជាតិវៀតណាមនៅក្នុងប្រទេស។[19]

## គ. កង្វះបញ្ញត្តិច្បាប់ប្រឆាំងនឹងការរើសអើងទៅលើអ្នកស្រលាញ់ភេទដូចគ្នា ស្តីពីបទល្មើសស្អប់ខ្ពើម និងវិស័យការងារ

*បញ្ហាទី ៥. សូមពណ៌នានូវច្បាប់ និង/ឬ វិធានការរដ្ឋបាល ក៏ដូចជា សេចក្តីសម្រេចរបស់តុលាការថ្មីៗ ស្តីពីការការពារប្រឆាំងការរើសអើងនៅលើមូលដ្ឋាននិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ រួមទាំងការរើសអើងនៅក្នុងវិស័យការងារ និងការទទួលបានសេវាសុខភាពផងដែរ។ សូមផ្តល់យោបល់លើរបាយការណ៍នៃបទល្មើសដែលកើតឡើងពីការស្អប់ខ្ពើម រួមទាំងហិង្សាផ្លូវភេទ និងការយាយីលើស្រីស្រលាញ់ស្រី បុរសស្រលាញ់បុរស និងអ្នកប្តូរភេទ។ តើរដ្ឋភាគីបានពិចារណាលើលទ្ធភាពនៃការទទួលស្គាល់សមត្ថសង្វាសភេទដូចគ្នាដែរឬទេ?*

---

[16] ម.ស.ម.ក 'លិខិតចំហ ពីម.ស.ម.ក សម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះពាក្យសម្តីរើសអើង ដែលបានពោលឡើងដោយគណបក្សសង្គ្រោះជាតិ' (ឆ្នាំ ២០១៣) ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=455&id=5.

[17] ការសង្កេតដើម្បីការការពារអ្នកការពារសិទ្ធិមនុស្ស កម្មវិធីរួមរវាង អង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម និងសហព័ន្ធអន្តរជាតិដើម្បីសិទ្ធិមនុស្ស 'កម្ពុជា ៖ យុទ្ធការ និងការគំរាមកំហែងយ៉ាងខ្លាំងក្លាមកលើ លោក អ៊ូ វីរៈ និង បុគ្គលិក ម.ស.ម.ក' ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ ៖ http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2014/01/d22517/.

[18] ដេនីស ហើប៊ី 'គណបក្សប្រឆាំង និយាយថា គ.ស.ជ មិនប្រកាន់ពូជសាសន៍ ពាក្យថា 'យួន' មិនមែនជាពាក្យរើសអើងនោះទេ' ខេមបូឌា ដេលី (ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៤): https://www.cambodiadaily.com/archives/opposition-says-cnrp%E2%80%88not-racist-yuon-not-derogatory-56484/.

[19] ប៊ីប៊ីស៊ី 'វៀតណាម 'ត្រូវបានដៅមុខសញ្ញា' នៅកម្ពុជា' (ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤): http://www.bbc.com/news/world-asia-29471222.

ខណៈដែលរដ្ឋាភិបាលមិនបានរៀបចំច្បាប់ ឬវិធានរដ្ឋបាលជាក់លាក់ដើម្បីការពារប្រឆាំងនឹងការរើសអើងដោយផ្អែកលើមូលដ្ឋានគ្រឹះនៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រក៏ដោយ ក៏ក្រសួងកិច្ចការនារី បានរួមបញ្ចូលសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នាទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេល ៥ ឆ្នាំរបស់ខ្លួន ក្នុងសមភាពយេនឌ័រ និងពង្រឹងអំណាចដល់ស្ត្រីនៅកម្ពុជា ក្នុងឆ្នាំ ២០១៤ - ២០១៨ (ឈ្មោះជាខ្មែរ គឺនារីរតនៈ ៤ ដែលមានន័យថា "ត្បូងដ៏មានតម្លៃ")។ [20] បន្ថែមពីលើនោះ ក្នុងឆ្នាំ ២០១៤ ក្រសួងកិច្ចការនារី បានចេញផ្សាយគោលនយោបាយសង្ខេបដែលមានចំណងជើងថា 'សិទ្ធិ ៖ ក្រុមស្ត្រី និងកុមារីដែលងាយរងគ្រោះ'[21] ផ្តោតជាពិសេសលើបញ្ហារើសអើង ដែលប្រឈមមុខដោយក្រុមស្ត្រីស្រលាញ់ស្ត្រី និងស្ត្រីដែលមានពីរភេទ និងអ្នកប្តូរភេទ។ នេះជាសសរស្តម្ភដ៏សំខាន់ក្នុងគោលនយោបាយផ្លូវការ ស្តីពីការដោះស្រាយបញ្ហារើសអើងរបស់ក្រុមអ្នកស្រលាញ់ភេទដូចគ្នា។ ជាពិសេស ផែនការនេះរួមបញ្ចូលទាំងសកម្មភាពលើកកម្ពស់សិទ្ធិស្មើភាពគ្នារបស់អ្នកស្រលាញ់ភេទដូចគ្នាដើម្បីទទួលបានការអប់រំ និងរៀបចំយុទ្ធសាស្ត្រពិគ្រោះយោបល់ជាមួយក្រុមអ្នកស្រលាញ់ភេទដូចគ្នា ស្តីពីការបញ្ចប់ការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នានៅក្នុងសាលារៀន និងកន្លែងការងារ សហគមន៍ និងក្រុមគ្រួសារ។

ថ្វីបើមានជំហានវិជ្ជមានរៀបរាប់ដូចខាងលើក៏ដោយ ប៉ុន្តែក៏មិនទាន់មានច្បាប់ប្រឆាំងនឹងបទល្មើសដែលកើតមកពីការស្អប់ខ្ពើម ឬច្បាប់ហាមឃាត់ការរើសអើងនៅថ្នាក់មូលដ្ឋាន ទាក់ទងនឹង និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនៅកម្ពុជានៅឡើយទេ។[22] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញបានបញ្ជាក់ថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ"។ ចំណុចនេះបានផ្តល់នូវការការពារប្រឆាំងនឹងការរើសអើង ផ្អែកលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ត្រឹមតែតាមរយៈបញ្ញត្ត "ស្ថានភាពឯទៀត" ប៉ុណ្ណោះ។

ស្រដៀងគ្នានេះដែរ មិនមានវិធានផ្នែកច្បាប់ ឬរដ្ឋបាលណាមួយត្រូវបានអនុវត្ត ដែលអាចការពារប្រឆាំងនឹងការរើសអើងក្នុងវិស័យការងារនោះទេ។[23] ច្បាប់ការងារ ឆ្នាំ១៩៩៧ មិនបានរាប់បញ្ចូលដោយចំហនូវអ្នកស្រលាញ់ភេទដូចគ្នាស្ថិតលើមូលដ្ឋានដែលហាមឃាត់ក្នុងការរើសអើងនោះទេ ថ្វីបើមានភស្តុតាងផ្អែកលើរឿងរ៉ាវជាក់ស្តែងដែលបញ្ជាក់ថា អ្នកស្រលាញ់ភេទដូចគ្នាជាច្រើនពិបាកក្នុងការស្វែងរកការងារ ឬរក្សាការងារនោះណាស់។[24]

[20] ក្រសួងកិច្ចការនារី 'នារីរតនៈ ៤' ខែធ្នូ ឆ្នាំ២០១៤
http://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Cambodian%20Gender%20Strategic%20Plan%20-%20Neary%20Rattanak%204_Eng.pdf.

[21] ក្រសួងកិច្ចការនារី 'សិទ្ធិ ៖ ក្រុមស្ត្រី និងកុមារីដែលងាយរងគ្រោះ' (ឆ្នាំ ២០១៤) ៖
http://www.kh.undp.org/content/dam/cambodia/docs/DemoGov/NearyRattanak4/Neary%20Rattanak%204%20-%20Vulnerable%20Groups%20of%20Women%20and%20Girls_Eng.pdf.

[22] ម.ស.ម.ក 'ឥន្ទធនូខ្មែរ ៖ពីការរើសអើងទៅជាមោទនភាព' (ឆ្នាំ ២០១២): 6 http://bit.ly/1y6aGPi.

[23] ដូចខាងលើ, ទំព័រទី ២២។

[24] ដូចខាងលើ, ទំព័រទី ២១-២២។

## ឃ. ការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រលាញ់ភេទដូចគ្នា

*បញ្ហាទី ៥. [បន្ត]*

បច្ចុប្បន្ននៅមិនទាន់មានការទទួលស្គាល់ស្របច្បាប់ ស្តីពីសមគ្គសង្វាសអ្នកស្រលាញ់ភេទដូចគ្នានោះទេ ប៉ុន្តែសមគ្គសង្វាសបែបនោះក៏មិនបានហាមប្រាមដោយបើកចំហដែរ។ ខណៈដែលមាត្រា ៦ នៃ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ បានហាមឃាត់ដោយបើកចំហលើការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា ចំណុចនេះត្រូវធ្វើឲ្យអស់សុពលភាពដោយ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៨ និង ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលមិនបានហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នា។ ប៉ុន្តែ មិនទាន់មានការចង្អុលបង្ហាញណាមកពីរដ្ឋាភិបាល ដែលថារដ្ឋាភិបាលនឹងអនុម័តច្បាប់ដើម្បីទទួលស្គាល់ដោយបើកចំហដើម្បីទទួលស្គាល់សមគ្គសង្វាសភេទដូចគ្នាក្នុងពេលអនាគតនោះទេ។

មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញបញ្ជាក់ផ្តល់និយមន័យពីការរៀបអាពាហ៍ពិពាហ៍រវាងស្វាមី និងភរិយា ប៉ុន្តែខកខានក្នុងការកំណត់ភេទរបស់ស្វាមី និងភរិយា។ ដូច្នេះ មានការរាយការណ៍ពីករណីដែលគូស្នេហ៍ស្រលាញ់ភេទដូចគ្នារៀបការជាមួយគ្នា ហើយមានម្នាក់ចុះឈ្មោះជា "ស្វាមី" និងម្នាក់ទៀតចុះឈ្មោះជា "ភរិយា"។ មន្ត្រីមកពីក្រសួងមហាផ្ទៃ បានអះអាងថា មិនចាំបាច់ត្រូវធ្វើវិសោធនកម្មលើច្បាប់អាពាហ៍ពិពាហ៍នោះទេ ដោយសារថា "យើងមិនបានហាមឃាត់ពួកគេក្នុងការរៀបការនោះទេ…នៅពេលដែលមានការរៀបអាពាហ៍ពិពាហ៍រវាងស្ត្រី និងស្ត្រី អ្នកអាចចុះឈ្មោះម្នាក់ជាបុរស និងម្នាក់ទៀតជាស្ត្រី"។[25] ទោះបីជាបែបនោះក៏ដោយ ជាញឹកញាប់គូស្នេហ៍ភេទដូចគ្នាត្រូវបានអាជ្ញាធរចុះឈ្មោះថាជា 'ដៃគូ' ឬ 'បងប្អូនស្រី' ក្នុងសៀវភៅគ្រួសារ ជាជាងចេញលិខិតរៀបអាពាហ៍ពិពាហ៍ជូនពួកគាត់។[26] ខណៈដែលវិធានការនេះ មិនបានផ្តល់នូវសិទ្ធិអាណាព្យាបាល និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដល់គូស្វាមីភរិយានោះទេ មានន័យថាមិនមានសិទ្ធិគ្រួសារដូចដែលគួរតែមានក្នុងអាពាហ៍ពិពាហ៍នោះទេ។

---

[25] យូអិនឌីភី, យូសេដ (ឆ្នាំ ២០១៤)។ អ្នកស្រលាញ់ភេទដូចគ្នានៅអាស៊ី ៖ របាយការណ៍ប្រចាំប្រទេសកម្ពុជា។ ទីក្រុងបាងកក ទំព័រទី ២៨ ៖ http://bit.ly/1y6aXBO.

[26] ម.ស.ម.ក 'ឥន្ទធនូខ្មែរ ៖ ពីការរើសអើងទៅមោទនភាព' (ឆ្នាំ ២០១២) ៖ 28 http://bit.ly/1y6aGPi.

## ៣. សិទ្ធិរស់រានមានជីវិត និងការប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (មាត្រា ២ កថាខណ្ឌទី ៣ មាត្រា ៦ មាត្រា ៧ មាត្រា ២១ នៃ ក.អ.ស.ព.ន)

### ក. ការយាយីផ្នែកច្បាប់ និងវាយប្រហារមកលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជន និង កង្វះខាតគណនេយ្យភាព ក្នុងការបំពានពីសំណាក់ក្រុមហ៊ុនឯកជន

*បញ្ហាទី ៨. យោងតាមព័ត៌មានដែលបាននៅមុខគណៈកម្មាធិការ មានយ៉ាងហោចណាស់ អ្នកសារព័ត៌មានចំនួន ១២ នាក់ ត្រូវបានធ្វើឃាតនៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេល ២០ ឆ្នាំក្រោយមកនេះ ដោយមិនមានករណីណាមួយដែលត្រូវបាននាំយកទៅកាន់តុលាការនោះទេ។ សូមផ្តល់មតិយោបល់នៅលើរបាយការណ៍ ដែលអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន និងសហជីព អ្នកនយោបាយ និងតួអង្គសង្គមស៊ីវិល បានរងការយាយី និងអំពើហិង្សាក្នុងអំឡុងពេលនៃការត្រួតពិនិត្យ។ សូមផ្តល់ព័ត៌មានស្តីពីវិធានការដែលបានរៀបចំឡើងដើម្បីដោះស្រាយជាមួយការយាយី និងអំពើហិង្សា និងដើម្បីការពារបុគ្គលដែលពាក់ព័ន្ធនឹងសកម្មភាពទាំងនេះ។*

បរិយាកាសទូទៅចំពោះសំឡេងរិះគន់នៅតែប្រឈមនឹងគ្រោះថ្នាក់។ ក្នុងខែតុលា ឆ្នាំ២០១៤ អ្នកសារព័ត៌មានមកពីខេត្តក្រចេះ បានក្លាយទៅជាអ្នកសារព័ត៌មានទី ១៣ ដែលរងការសម្លាប់នៅកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៩៤ ខណៈពេលដែលប៉ុងប៉ងរាយការណ៍ពីការកាប់ឈើខុសច្បាប់។[27] បុគ្គលដែលជាប់សង្ស័យថាប្រព្រឹត្តបទល្មើស រួមមាន មន្ត្រីនគរបាល និងមន្ត្រីយោធា។ នៅទូទាំងប្រទេសកម្ពុជា បុគ្គលិកអង្គការ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនដទៃទៀតបានបន្តរងការគំរាមកំហែង និងយាយីដោយសារតែការងាររបស់ពួកគេ ពីសំណាក់ក្រុមអាជ្ញាធរ និងតួអង្គក្រុមហ៊ុនឯកជនដែលមានអំណាច។ ការយាយីផ្នែកច្បាប់ រួមទាំងការចោទប្រកាន់ដោយមិនសមហេតុផល និងការប្រើប្រាស់ដោយខុសឆ្គងនូវការឃុំខ្លួនបណ្តោះអាសន្ន នៅតែជាការព្រួយបារម្ភដ៏ធ្ងន់ធ្ងរ និងប្រឈមមុខសម្រាប់អង្គការសង្គមស៊ីវិលឯករាជ្យ និងគណបក្សប្រឆាំងនៅកម្ពុជា។ ស្ថានភាពកាន់តែធ្ងន់ធ្ងរដោយសារតែអំពើពុករលួយជាច្រើន និងការសមគំនិតគ្នារវាងអាជ្ញាធរ និងបុគ្គល ឬក្រុមហ៊ុន។

ករណីដូចខាងក្រោម បង្ហាញពីអ្វីដែលអ្នកមានអំណាច អាចប្រើកម្លាំងនគរបាល និងតុលាការដើម្បីផលប្រយោជន៍របស់ខ្លួន និងបង្ហាញពីអ្វីដែលអាជ្ញាធរតែងតែអសកម្ម ពេលដែលទទួលពាក្យបណ្តឹង ប្តឹងផ្ទាល់ចំពោះក្រុមហ៊ុន ឬបុគ្គលដែលមានឥទ្ធិពល។

នៅថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៤ ឡាយ សាមៀន អ្នកយកព័ត៌មានពីវិទ្យុសំឡេងប្រជាធិបតេយ្យ ដែលជាអង្គភាពរបស់មជ្ឈមណ្ឌលដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ម.ប.ឯ) ត្រូវបានវាយដំ និងសន្លប់នៅលើផ្លូវ ពេលដែលមានបំណងចង់ថតរូប កងកម្លាំងសន្តិសុខកំពុងតែរត់ដេញព្រះសង្ឃ នៅក្នុងបាតុកម្មដែលរៀបចំដោយអ្នកគាំទ្ររបស់គណបក្សប្រឆាំងនៅ

[27] មាស សុខជា និង ជានៀល ផាយ 'អ្នកកាសែតត្រូវបានសម្លាប់នៅខេត្តក្រចេះ', សារព័ត៌មានភ្នំពេញប៉ុស្តិ៍ (ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤), http://goo.gl/lBtbnj.

ឯទីលានប្រជាធិបតេយ្យ ក្នុងទីក្រុងភ្នំពេញ។[28] គាត់រងរបួសត្រង់ក្បាល និងបាក់ឆ្អឹងថ្ពាល់ ដែលតម្រូវឲ្យលោកធ្វើដំណើរទៅទីក្រុងបាងកក ដើម្បីវះកាត់ ដែលត្រូវចំណាយថវិកាប្រហែល ៣០.០០០ ដុល្លារ។ ចក្ខុរបស់គាត់ក៏រងការប៉ះពាល់ជារៀងរហូតផងដែរ។ ម.ប.ឯ បានដាក់ពាក្យបណ្ដឹងទាមទារសំណងប្រឆាំងនឹងមន្ត្រីដែលទទួលខុសត្រូវចំពោះកងកម្លាំងសន្តិសុខសំណូមពរឲ្យមានការបង់ប្រាក់សំណងសម្រាប់ថ្លៃចំណាយផ្នែកថ្នាំពេទ្យ ប៉ុន្តែតុលាការក្រុងភ្នំពេញបានទម្លាក់រឿងក្តីនេះចោលដោយគ្មានការពន្យល់ទាល់តែសោះ។[29] ថែមទាំងមិនមានការស៊ើបអង្កេតលើបទល្មើសដែលប្រព្រឹត្ត ដោយមន្ត្រីនគរបាល ឬក៏តុលាការ ណាមួយនោះទេ ទោះបីជាមានការរិះគន់ជាច្រើនក៏ដោយ។

នៅថ្ងៃទី ៩ ខែឧសភា ឆ្នាំ២០១៤ អ្នកសម្របសម្រួល គម្រោងសម្របសម្រួលដីធ្លីរបស់ ម.ស.ម.ក លោក វណ្ណ សូផាត រងការគំរាមកំហែងដល់ជីវិតពីក្រុមសន្តិសុខរបស់ក្រុមហ៊ុនដ៏មានឥទ្ធិពល យុន សៀ ខណៈដែលកំពុងតែទៅទស្សនាកន្លែងដែលស្ថិតក្នុងជម្លោះដីធ្លីដ៏រ៉ាំរ៉ៃ ដែលមានទីតាំងនៅសង្កាត់បឹងកក់ ១ ទីក្រុងភ្នំពេញ។ ពាក្យបណ្ដឹងព្រហ្មទណ្ឌបានដាក់ប្រឆាំងនឹងជនល្មើស ហើយលោក វណ្ណ សូផាត បានកោះហៅចំនួនពីរដងដើម្បីទៅសាកសួរ ប៉ុន្តែមិនទាន់មាននរណាត្រូវបានផ្តន្ទាទោសនៅឡើយទេ។ បន្ថែមពីលើនោះ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពបញ្ចេញគំនិត និងមតិ និងអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី និងខាងសមាគម និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស បានចេញលិខិតរួមគ្នាមួយ។ លិខិតនេះ ដែលបានបញ្ជាក់ពីការព្រួយបារម្ភដោយសារការសម្លុត និងគំរាមមកលើលោក វណ្ណ សូផាត មកទល់ពេលនេះនៅមិនទាន់មានការឆ្លើយតបនៅឡើយ។*30*

កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ **លោក លី ស្រ៊ាខេង និងកូនស្រី កញ្ញា លី ស៊ីវមីង** ត្រូវបានចាប់ខ្លួនក្នុងបរិបទនៃជម្លោះដីធ្លីដ៏រ៉ាំរ៉ៃជាមួយក្រុមហ៊ុនយុន សៀ អ៊ីមផត អ៊ិចផត បន្ទាប់ពីពួកគេមិនព្រមចាកចេញពីដីនៅក្នុងតំបន់បឹកកក់ ១ ក្នុង ខណ្ឌទួលគោក ទីក្រុងភ្នំពេញ ដែលពួកគេបានរស់នៅតាំងពីឆ្នាំ ១៩៨២។[31] ក្រុមគ្រួសារនេះ បានរងការគំរាមដល់ជីវិតការវាយប្រហារដោយហិង្សា និងការសម្លុតបំភ័យជាច្រើន ដោយសារតែជម្លោះដីធ្លីនេះ។[32] មន្ត្រីនគរបាល ចាប់ខ្លួន លោកខេង ដោយមិនមានដីការចាប់ខ្លួន ដែលនេះរំលោភបំពានលើមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងនាំខ្លួនគាត់ទៅដោយមិនព្រមអនុញ្ញាតឲ្យគាត់ស្លៀកពាក់ឲ្យបានត្រឹមត្រូវនោះទេ។ ពេលល្ងាចបន្ទាប់ យោងតាមព័ត៌មានដែលទទួលបានដោយ មេធាវីរបស់ ម.ស.ម.ក ដែលជាតំណាងផ្នែកច្បាប់របស់គ្រួសារនេះ តំណាងរបស់ក្រុមហ៊ុន យុន សៀ ទាក់ទងមកកូនប្រុសរបស់

---

[28] ម.ស.ម.ក ‘ខ្ញុំនឹងមិនខ្លាចទេ’ (ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៤), http://www.seapa.org/?p=10326#_ftn5.

[29] សែន ដាវីត ‘ករណីអ្នកយកព័ត៌មាន មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ត្រូវទម្លាក់ចោល’ សារព័ត៌មានភ្នំពេញ ប៉ុស្ដិ៍ (ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤), http://www.phnompenhpost.com/national/ccim-reporters-case-dropped.

[30] ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប របាយការណ៍ទំនាក់ទំនងនៃនីតិវិធីពិសេស A/HRC/27/72 ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ http://www.ohchr.org/EN/HRBodies/HRC/RegularSessions/Session27/Documents/A_HRC_27_72_Eng%20Fre%20and%20Spa%20only.doc.

[31] សេចក្តីថ្លែងការណ៍រួមរបស់អង្គការមិនមែនរដ្ឋាភិបាល ‘ការចាប់ខ្លួនតាមទំនើងចិត្តក្នុងបឹងកក់ ១’ (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤), http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=press_detail.php&pro=LR&pro_id=12&prid=524&id=3.

[32] ម.ស.ម.ក ‘ជីវៈប្រវត្តិសកម្មជនដីធ្លី - លី ស្រ៊ាខេង ៖ ក្រុមគ្រួសារដែលរងការគំរាមកំហែង និងការវាយដំនៅទីក្រុងភ្នំពេញ’ (ឆ្នាំ២០១៤) http://www.cchrcambodia.org/index_old.php?url=project_page/project_page.php&p=land_profile_detail.php&profile_id=1&pro=LR&pro_id=12.

លោក ខេង ដើម្បីបន្តការចរចាលើដីដម្លោះនោះទៀត ដែលនេះបង្ហាញពីការប្រើអំណាចតុលាការក្នុងផ្លូវខុសដើម្បីដាក់សម្ពាធទៅលើក្រុមគ្រួសារលោក។ លោក ខេង ត្រូវអនុញ្ញាតឲ្យនៅក្រៅឃុំ កាលពីថ្ងៃទី៥ ខែធ្នូ ប៉ុន្តែនៅថ្ងៃទី៥ ខែមករា តុលាការមិនអនុញ្ញាតឲ្យកូនស្រីរបស់លោកក្រៅឃុំនោះទេ ដោយសំអាងលើហេតុផលដែលមិនច្បាស់លាស់ថា នេះជាការចាំបាច់ដើម្បីការពារមិនឲ្យមានការប្រព្រឹត្តបទល្មើសថ្មីបន្ថែម ការពារមិនឲ្យមានការបំផ្លាញភស្តុតាង ឬក៏គំរាមកំហែងលើសាក្សី។ បន្ថែមពីលើនោះ លោក ខេង និងក្រុមគ្រួសាររបស់លោកបានប៉ុនប៉ងដោយទទួលលទ្ធផលជាការបរាជ័យជាច្រើនលើកក្នុងការចុះបញ្ជីដីធ្លីជាមួយអាជ្ញាធរ។ ផ្ទុយមកវិញ អាជ្ញាធរមិនបានចាត់វិធានការណាមួយទៅលើពាក្យបណ្ដឹងរបស់លោក ខេង ទាក់ទងនឹងការគំរាមកំហែង និងការវាយប្រហារដោយផ្ទាល់មកលើក្រុមគ្រួសាររបស់លោក ពីសំណាក់សន្តិសុខក្រុមហ៊ុន យុន សៀ នោះទេ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្ដល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ធានាថាករណីការយាយីប្រឆាំងនឹងអ្នកសារព័ត៌មាន អ្នកធ្វើការអង្គការ សមាជិកសហជីព និងតួអង្គសង្គមស៊ីវិលដទៃទៀត ត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញ ទាន់ពេលវេលា ហើយដែលជនល្មើសទាំងអស់ត្រូវនាំយកមកផ្ដន្ទាទោសដោយមិនគិតពីឋានៈរបស់ពួកគេ*
- *ធានាថាជនរងគ្រោះនឹងទទួលបានសំណងយ៉ាងមានប្រសិទ្ធភាព ដែលធានាដោយប្រព័ន្ធតុលាការដែលមិនលម្អៀង*
- *ឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អ្នករាយការណ៍ពិសេស ស្ដីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ស្នើសុំមកធ្វើទស្សនកិច្ចនៅកម្ពុជា (សំណើសុំធ្វើទស្សនកិច្ចត្រូវបានស្នើសុំកាលពីឆ្នាំ ២០១២)។*

## ខ. ការប្រើប្រាស់កម្លាំងហួសហេតុពីសំណាក់មន្ត្រីនគរបាល និងកងកម្លាំងសន្តិសុខ ក្នុងអំឡុងការធ្វើបាតុកម្ម

*បញ្ហាទី ៩. សូមផ្ដល់មតិយោបល់លើរបាយការណ៍នៃការប្រើប្រាស់កម្លាំងហួសហេតុ ក្នុងអំឡុងពេលបាតុកម្ម និងការប្រើប្រាស់សន្តិសុខឯកជនក្នុងការតបតទៅការធ្វើបាតុកម្ម។ តើមានវិធានការណាខ្លះដែលភាគីរដ្ឋបានរៀបចំឡើងដើម្បីធានាថាមន្ត្រីអនុវត្តច្បាប់អនុវត្តក្នុងលក្ខខណ្ឌស្របទៅនឹងមាត្រា ៦ និង ៧ នៃកតិកាសញ្ញា? សូមបង្ហាញព័ត៌មានពីការស៊ើបអង្កេតណាមួយ និងដំណើរការបែបវិន័យ និង/ឬព្រហ្មទណ្ឌពាក់ព័ន្ធនឹងករណីដូចខាងក្រោម ៖*

*១) មរណភាពរបស់លោក ម៉ៅ សុខាចាន់ នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៣ ក្នុងអំឡុងការធ្វើបាតុកម្មនៅទីក្រុងភ្នំពេញ*

*២) មរណភាពរបស់ អ្នកលក់ឥវ៉ាន់តាមដងផ្លូវ លោកស្រី ហេង សុខុន អាយុ ៤៩ ឆ្នាំ នៅថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ២០១៣ ក្នុងអំឡុងការប៉ះទង្គិចរវាងកងសន្តិសុខ និងក្រុមបាតុករដែលជាកម្មកររោងចក្រ ដែលធ្វើការតវ៉ាប្រឆាំងដើម្បីទាមទារឲ្យមានការដំឡើងប្រាក់បៀវត្សរ៍ ការអនុញ្ញាតឲ្យមានពេលសម្រាកសម្រាប់អាហារ និងទាមទារឲ្យរោងចក្របញ្ឈប់ការជួលមន្ត្រីយោធាក្នុងការធ្វើជាភ្នាក់ងារសន្តិសុខ*

*៣) ការស្លាប់នៅថ្ងៃទី ២ - ៣ ខែមករា ឆ្នាំ២០១៤ របស់មនុស្សបួននាក់ និងការអះអាងថាបានបាត់ខ្លួនដោយបង្ខំរបស់លោក ខឹម សុផាត អាយុ ១៦ ឆ្នាំ ដែលត្រូវបានឃើញថារងរបួសគ្រាប់កាំភ្លើងនៅត្រង់ដើមទ្រូង ក្នុងអំឡុងការប៉ះទង្គិចរវាងកងសន្តិសុខ និងក្រុមកម្មកររោងចក្រ។ យោងតាមព័ត៌មាននៅចំពោះមុខគណៈកម្មាធិការ មានមនុស្សចំនួន ៣៨ នាក់ទៀតដែលរងរបួស ហើយដែលក្នុងនោះមនុស្សចំនួន ២៥ នាក់រងរបួសគ្រាប់កាំភ្លើង។*

ឆ្នាំ ២០១៣ គឺជាឆ្នាំដែលចំនួនបាតុកម្មកើនឡើងជាខ្លាំង ដោយមានមនុស្សជាច្រើនជាងរាប់សែននាក់ បញ្ចេញពីការរអ៊ូរទាំរបស់ពួកគេក្នុងទីសាធារណៈ ដែលមានដូចជា កម្មការរោងចក្រ និងជនរងគ្រោះដោយសារការបណ្តេញចេញដោយបង្ខំ និងក្រុមប្រឆាំងផ្នែកនយោបាយ។ ក្នុងឆ្នាំ ២០១៣ ម.ស.ម.ក បានវិភាគករណីដែលបានរាយការណ៍ ចំនួន ២៥ ដែលកងកម្លាំងសន្តិសុខប្រើអំពើហិង្សាក្នុងការបង្ក្រាបបាតុកម្ម ប្រើដំបងឆក់ ឧស្ម័នបង្ហូរទឹកភ្នែក ឡានទឹក ដំបង និងគ្រាប់កាំភ្លើង ដោយវាយដំ និងក្នុងករណីមួយចំនួន បាញ់មកលើក្រុមបាតុករ ដែលបណ្តាលឲ្យមនុស្សពីរនាក់ស្លាប់ ម្នាក់ត្រូវពិការ និងមនុស្ស ១៦ នាក់ ទៀតរងរបួស។[33] មិនមានការស៊ើបអង្កេតឯករាជ្យ ឬម៉ត់ចត់ណាមួយត្រូវបានធ្វើឡើងនោះទេ។[34]

អ្នកស្រី ទិត សាំង ដែលជាម្តាយរបស់ លោក **ម៉ៅ សុខចាន់** បានប្រាប់សារព័ត៌មានភ្នំពេញប៉ុស្តិ៍ កាលពីខែកញ្ញា ឆ្នាំ ២០១៤ ថា ៖ "ខ្ញុំរង់ចាំលទ្ធផលនៃការស៊ើបអង្កេតរបស់អាជ្ញាធរ...ប៉ុន្តែមកទល់បច្ចុប្បន្ន មិនទាន់មានអ្វីបង្ហាញនោះទេ។ ឃាតករមិនទាន់ត្រូវបានចាប់ខ្លួននោះទេ ហើយកូនប្រុសរបស់ខ្ញុំត្រូវស្លាប់។ មិនមានទេយុត្តិធម៌សម្រាប់ខ្ញុំ។" ខណៈដែលអ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្រ្ត បញ្ជាក់ថា៖ "ខ្ញុំសូមទោស! ខ្ញុំមិនទាន់មានព័ត៌មានអ្វីថ្មីនោះទេ"។*35*

លោកស្រី **អេង សុខុម** (សរសេរខុសថាជា ហេង សុខុនខាងលើ) រៀបចំលក់បាយនៅក្នុងតូបតាមចិញ្ចើមផ្លូវ នៅពេលដែលអំពើហិង្សាបានផ្ទុះឡើង រវាងកម្មកររោងចក្រ អែស អិល និងកងកម្លាំងសន្តិសុខរបស់រដ្ឋ ក្នុងអំឡុងបាតុកម្មនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។ កងកម្លាំងសន្តិសុខបាញ់ដោយមិនរើសមុខទៅក្នុងក្រុមបាតុករ ពេលនោះលោកស្រី អេង សុខុម ត្រូវគ្រាប់កាំភ្លើង និងស្លាប់។ បន្ទាប់ពីការស្លាប់របស់ លោកស្រី អេង សុខុម អ្នកនាំពាក្យនគរបាលជាតិ លោក គាត ច័ន្ទថារិទ្ធិ បានប្រាប់សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថាគណៈកម្មាធិការស៊ើបអង្កេត ត្រូវបានបង្កើតឡើងដើម្បីពិនិត្យមើលថាតើហេតុអ្វីបានជាមន្ត្រីនគរបាលប្រើកាំភ្លើង។[36] ក្នុងខែ តុលា ឆ្នាំ២០១៤ កូនស្រី របស់លោកស្រី អេង សុខុម កញ្ញា វង្ស វល័ក្ខ ប្រាប់ ម.ស.ម.ក "នៅពេលនោះ យើងមិនទាន់បានដាក់ពាក្យបណ្តឹងនោះទេ។ ឪពុករបស់ខ្ញុំមិនទាន់ធ្វើអ្វី ដោយសារតែករណីផ្សេងទៀតបានដាក់ពាក្យបណ្តឹងទៅហើយ តែមិនទាន់ទទួលបានលទ្ធផលអ្វីនោះទេ។ យើងចង់ការពារមនុស្សដែលនៅរស់ យើងខ្លាចថាយើងនឹងធ្វើឲ្យពួកគេមានបញ្ហា...ករណីនេះស្ងាត់ទៅហើយ មិនមាននរណាចាប់អារម្មណ៍នោះទេ ដិត

[33] ម.ស.ម.ក 'ការប្រើប្រាស់កម្លាំងហួសហេតុលើក្រុមបាតុករក្នុង ឆ្នាំ២០១៣ នៅកម្ពុជា' (ឆ្នាំ ២០១៤) ៖ http://www.cchrcambodia.org/admin/media/analysis/analysis/english/2014_01_03_CCHR_Briefing_ENG.pdf.

[34] ម.ស.ម.ក 'និទណ្ឌភាពនៅកម្ពុជា' (ឆ្នាំ ២០១៤) ៖ http://bit.ly/1rL5f24; ម.ស.ម.ក 'ឯណាទៅយុត្តិធម៌ខ្ញុំ?' (ឆ្នាំ ២០១៤) ៖ http://bit.ly/12iIBYc; ម.ស.ម.ក 'ការប្រើប្រាស់កម្លាំងហួសហេតុប្រឆាំងនឹងក្រុមបាតុករក្នុង ឆ្នាំ២០១៣ នៅកម្ពុជា' (ឆ្នាំ ២០១៤) http://bit.ly/11GAAMD.

[35] ម.ស.ម.ក 'ក្នុងឱកាសទិវាអន្តរជាតិប្រជាធិបតេយ្យ ម.ស.ម.ក សូមអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាបញ្ចប់និទណ្ឌភាព' (ឆ្នាំ ២០១៤) ៖ http://www.cchrcambodia.org/media/files/press_release/515_201cpidod2%28_en.pdf; សូមអាន ៖ ឡូរ៉ែន ក្រូជើ 'មួយឆ្នាំកន្លងផុតទៅ មិនទាន់មានយុត្តិធម៌សម្រាប់ជនរងគ្រោះ ម៉ៅ សុខចាន់' *សារព័ត៌មាន ឌឹ ខេមបូឌា ដេលី* (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៤) https://www.cambodiadaily.com/news/one-year-on-no-justice-for-shooting-victim-mao-sok-chan-68085/.

[36] ស្បែន រ៉ីវ៉ែល និង មុំ គន្ធា 'នគរបាលពាក់ព័ន្ធនឹងការផ្ទុះអាវុធក្នុងបាតុកម្ម នឹងត្រូវស៊ើបអង្កេត' *សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣) ៖ http://www.phnompenhpost.com/national/police-strike-shootings-be-investigated.

មួយឆ្នាំទៅហើយ... ប្រសិនបើយើងព្យាយាមទាមទារយុត្តិធម៌ ពួកគេនឹងបង្ក្រាប និងគំរាមយើង។ ដូច្នេះ ខ្ញុំមិនបានដាក់ពាក្យបណ្តឹងនោះទេ″។ ម.ស.ម.ក មិនបានដឹងថាមានការស៊ើបអង្កេតណាមួយធ្វើឡើងចំពោះករណីនេះនោះទេ។

ក្នុងឆ្នាំ២០១៣ នៅទីក្រុងភ្នំពេញ មន្ត្រីនគរបាលជាតិព្រមជាមួយនឹងសន្តិសុខខណ្ឌដូនពេញ មានតែងមានវត្តមាននៅក្នុងកន្លែងបាតុកម្ម ហើយកងកម្លាំងទាំងនោះតែងតែត្រូវបានឃើញជារូបភាព វីដេអូ ថាបានប្រើកម្លាំងហួសហេតុ វាយដំ និងធ្វើទុក្ខបុកម្នេញទៅលើក្រុមបាតុករ។[37] កងសន្តិសុខទាំងនេះ មិនមែនជាមន្ត្រីសាធារណៈនោះទេ ពួកគេគ្រាន់តែស្ម័គ្រចិត្តធ្វើបែបនេះដោយសារទទួលបានការឧបត្ថម្ភ និងធ្វើតាមបញ្ជារបស់អភិបាលខណ្ឌ ឬចៅសង្កាត់ដែលពាក់ព័ន្ធប៉ុណ្ណោះ។ ដូច្នេះហើយ មានការព្រួយបារម្ភជាច្រើនពាក់ព័ន្ធនឹងវត្តបណ្តុះបណ្តាល ក្នុងការឃ្លាំមើលការជួបប្រជុំ សម្រាប់ក្រុមសន្តិសុខខណ្ឌទាំងនេះ ដោយសារអ្នកទាំងនោះ មិនមានស្តង់ដារដើម្បីមានប្រសិទ្ធិភាព ត្រឹមត្រូវក្នុងការប្រើប្រាស់កម្លាំងនោះទេ។ បន្ថែមពីលើនោះ កងកម្លាំងទាំងនោះមិនអាចសម្គាល់អត្តសញ្ញាណនោះទេ ដោយសារតែពួកគេមិនពាក់កាតសម្គាល់ ឈ្មោះ ឬអត្តលេខ។ ដូច្នេះ អត្តសញ្ញាណរបស់ពួកគេភាគច្រើនគឺមិនស្គាល់។

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ មានព្រះសង្ឃប្រាំអង្គត្រូវបានចាប់ខ្លួន ជាមួយនឹងសកម្មជនសហជីព ១០ នាក់ និងកម្មកររោងចក្រ មកពី យ៉ាក ជីន នៅឯជាយក្រុងភ្នំពេញ។ ក្នុងពេលចាប់ខ្លួននោះ គេឃើញមន្ត្រីនគរបាល បានវាយដំទៅលើក្រុមបាតុករ។[38] ក្នុងព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ មនុស្សចំនួន ១៣ នាក់ផ្សេងទៀតត្រូវបានចាប់ខ្លួនក្នុងអំឡុងបាតុកម្មនៅលើមហាវិថីវេង ស្រេង។

បន្ទាប់ពីមានការតបតដោយខឹងសម្បារពីក្រុមបាតុករដែលនៅសល់ កងកម្លាំងសន្តិសុខបានបាញ់ដោយមិនរើសមុខទៅកាន់ក្រុមបាតុករ។ **យាន រិទ្ធី** (២៥ ឆ្នាំ) **ផេង កុសល** (២២ ឆ្នាំ) **គីម ផល្លាភ** (២៥ ឆ្នាំ) និង **គង់ រ៉ាវី** (២៥ ឆ្នាំ) ត្រូវបាញ់សម្លាប់[39] និងមនុស្សជាច្រើននាក់ទៀតរងរបួស។ បន្ថែមពីលើនោះ មិនមាននរណាដឹងដំណឹងរបស់ **ខឹម សុផាត អាយុ ១៦ ឆ្នាំ** ថានៅទីណានោះទេ ដែលសាក្សីបានរាយការណ៍ថាបានឃើញគេរងរបួសត្រង់ពោះ។

នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០១៤ ឧត្តមសេនីយ ខេង ទីតូ ត្រូវបានរាយការណ៍ថា ការស៊ើបអង្កេតណាមួយទៅលើករណីសម្លាប់នៅថ្ងៃទី៣ ខែមករា នឹងមិនស្ថិតក្រោមតួនាទីរបស់មន្ត្រីយោធានោះទេ ប៉ុន្តែជាតួនាទីរបស់ "អ្នកញុះញង់" ដែលដឹកនាំបាតុកម្ម។[40] នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ រដ្ឋាភិបាលបានប្រកាសថាបានបង្កើតគណៈកម្មាការ ចំនួនពីរ ដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង ដើម្បីស៊ើបអង្កេតលើការខូចខាតដែលកើតឡើងដោយសារ "ក្រុមបាតុករអានាធិបតេយ្យ" និងថាតើឧបទ្ទវហេតុនោះកើតឡើងដោយរបៀបណា។[41] រយៈពេល ៣ សប្តាហ៍ក្រោយមក មានការប្រកាសថាការស៊ើបអង្កេតនោះត្រូវបានបញ្ចប់ ប៉ុន្តែមិនមានលទ្ធផលជាផ្លូវការណាមួយត្រូវបានចេញផ្សាយនោះទេ។[42]

---

[37] ម៉ៃ ទិត្យថារ៉ា 'បាតុករត្រូវវាយដំដោយសន្តិសុខ' *សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣): http://bit.ly/1kvxaBU.

[38] ម.ស.ម.ក 'ការចាប់ខ្លួន និងចោទប្រកាន់លើអ្នកការពារសិទ្ធិមនុស្ស វ៉ន ពៅ ប្រធានសមាគមប្រជាធិបត្យដើម្បីសេដ្ឋកិច្ចក្រៅប្រព័ន្ធ' (សេចក្តីប្រកាសព័ត៌មានបន្ទាន់គម្រោងអ្នកការពារសិទ្ធិមនុស្ស) (ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤), http://bit.ly/1dMuwAD.

[39] លីកាដូ 'បញ្ជីឈ្មោះអ្នកស្លាប់ និងបាត់ខ្លួនកាលពីបាតុកម្ម ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤' http://bit.ly/1kpFgxK.

[40] ឃួន ណារីម និង ខូលីន ម៉េយ៍ 'មិនមានលទ្ធផលចំពោះការស៊ើបអង្កេតលើបាញ់បោះក្នុងបាតុកម្ម' *សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍* http://bit.ly/1dWztbk.

[41] ម៉ៃ ទិត្យថារ៉ា 'ក្រុមអង្គការសិទ្ធិមនុស្សរិះគន់ការស៊ើបអង្កេតរបស់រដ្ឋាភិបាល' សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ (ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤). http://bit.ly/MKwBXI.

[42] មាស សុខជា 'មិនមានដំណឹងអ្វី បន្ទាប់ពីការស៊ើបអង្កេតលើផ្លូវវែងស្រែងត្រូវបានបញ្ចប់' សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍ (ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤) ៖

ដោយសារតែ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាមេដឹកនាំគណៈកម្មាការ និងស៊ើបអង្កេតកងកម្លាំងដែលស្ថិតក្រោមការបញ្ជារបស់លោក ធ្វើឲ្យគណៈកម្មាការនោះមិនឯករាជ្យ និងគ្មានតម្លាភាពនោះទេ។ ក្នុងចុងខែមករា ឆ្នាំ២០១៤ មានមន្ត្រីចំនួន ៥ នាក់ ដែលមិនបញ្ចេញឈ្មោះត្រូវបានព្រះរាជអាជ្ញាសាកសួរនៅឯសាលាដំបូងទីក្រុងភ្នំពេញ អំពីការជាប់ពាក់ព័ន្ធរបស់ពួកគេនៅក្នុងការប៉ះទង្គិច ប៉ុន្តែយោងតាមឧត្តមសេនីយ ខេង ទីតូ មន្ត្រីទាំងនេះមិនត្រូវបានចោទប្រកាន់នោះទេ ព្រោះថាពួកគេធ្វើនោះដើម្បីការពារខ្លួន។ [43]

នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៤ អាជ្ញាធរបានហាមការរៀបចំវេទិកាសាធារណៈ ស្តីពីបញ្ហាឧស្សាហកម្មកាត់ដេរសម្រាប់ទិវាសិទ្ធិនារីអន្តរជាតិ។ នៅវេលាម៉ោង ៧ ព្រឹក មន្ត្រីនគរបាលបានបិទទីលានប្រជាធិបតេយ្យ និងផ្លូវនៅជុំវិញនោះ មួយម៉ោងក្រោយមក សន្តិសុខខណ្ឌដូនពេញបំពាក់ដោយមួកសុវត្ថិភាព បានមកដល់ ហើយក៏បំបែកក្រុមមនុស្សដែលប្រមូលផ្តុំគ្នានៅក្បែរទីតាំងហាមឃាត់ទាំងបង្ខំ។[44]

ការធ្វើបាតុកម្មជាច្រើនត្រូវបានធ្វើឡើងជាបន្តបន្ទាប់ក្នុងឆ្នាំ ២០១៤ ដែលបណ្តាលឲ្យកើតមានចំនួនការប៉ះទង្គិចរវាងក្រុមបាតុករ និងកងកម្លាំងសន្តិសុខ រួមទាំងសន្តិសុខឯកជនផងដែរ។ [45]

## គ. មន្ត្រីនគរបាល និងកងកម្លាំងសន្តិសុខខណ្ឌដូនពេញប្រព្រឹត្តទង្វើដែលពោរពេញដោយនិទណ្ឌភាព

### បញ្ហាទី ៩ *[បន្ត ]*

តាមរយៈការលើកឡើងខាងលើ បង្ហាញឲ្យឃើញច្បាស់ថា រដ្ឋាភិបាលមិនបានចាត់វិធានការណាមួយដើម្បីធានាថាមន្ត្រីអនុវត្តច្បាប់អនុវត្តការងារក្នុងលក្ខខណ្ឌដែលស្របនឹងមាត្រា ៦ និង ៧ នៃកតិកាសញ្ញានោះទេ។ ផ្ទុយមកវិញ ៖ លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានកើតសរសើរពីការដោះស្រាយចំពោះការតវ៉ានានាក្នុង ឆ្នាំ២០១៣[46] ហើយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង បានប្រកាសថា មន្ត្រីនគរបាលប្រហែល ៣.១០០ នាក់នឹងទទួលបានប្រាក់រង្វាន់ចំនួន ១៧,៥០

---

http://bit.ly/1dE2442.

[43] ប៊ុត រស្មីគង្គា និងដានីញែល ផាយ 'មន្ត្រីត្រូវបានសាកសួរក្នុងការបាញ់ប្រហារ' សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍ (ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤): http://bit.ly/1cyH93f.

[44] មាច ដារ៉ា 'ការហាមឃាត់មិនឲ្យធ្វើបាតុកម្មដាច់ខាត នៅថ្ងៃទីសិទ្ធិនារី' សារព័ត៌មាន ខែមបូឌា ដេលី (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤): http://bit.ly/1gf8N9Y.

[45] កាលពីថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ កម្លាំងសន្តិសុខរួមទាំងសន្តិសុខឯកជន និងមន្ត្រីយោធា បានរាយការណ៍ថាវាយដំដោយដំបងទៅលើបាតុករដែលព្យាយាមប្រមូលផ្តុំ នៅទីលានប្រជាធិបតេយ្យ និងធក់ដោយដំបងធក់ បន្ទាប់ពីបាតុករទាត់សន្តិសុខឯកជនចំក្រលៀន នៅក្បែរស្ពាននាគ។ មានសមាគម និងសហជីពចំនួន ៩ បានប្រមូលផ្តុំដើម្បីទាមទារ ឲ្យមានការដោះលែង ២៣ នាក់ ដែលឃុំខ្លួនកាលពីដើមខែមករា និងទាមទារការដំឡើងប្រាក់បៀវត្សរ៍អប្បបរិមា ចំនួន ១៦០ ដុល្លារសម្រាប់កម្មកររោងចក្រ។ កាលពីសប្តាហ៍មុន រដ្ឋាភិបាលបានបដិសេធការស្នើសុំរៀបចំបាតុកម្ម។ កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ការធ្វើបាតុកម្មដោយសន្តិវិធី នៅក្រៅក្រសួងព័ត៌មាន ដែលដឹកនាំដោយ លោក ម៉ម សូណង់ដូ ត្រូវបានបំបែកដោយហិង្សា នៅប្រហែលម៉ោង ១០ ព្រឹក។ មានមន្ត្រីនគរបាលប្រហែល ១០០ នាក់ ត្រូវបានដាក់ពង្រាយនៅឃ្លាំមើលបាតុកម្ម ដោយប្រើដំបង និងគ្រាប់បែកផ្សែង ដើម្បីបំបែកបាតុកម្ម។ សន្តិសុខខណ្ឌដូនពេញ ក៏ពាក់ព័ន្ធនឹងការបំបែកបាតុកម្មដោយប្រើប្រាស់ដំបងផងដែរ។ ការប្រើប្រាស់ហិង្សានេះបានរាយការណ៍ថាបណ្តាលឲ្យមានមនុស្ស ១០នាក់ រងរបួស។ សូមមើល កំណត់ត្រាសង្ខេប ម.ស.ម.ក 'សេរីភាពខាងការជួបប្រជុំកំពុងតែត្រូវបាន "ព្យួរ' (ឆ្នាំ ២០១៤): http://www.cchrcambodia.org/admin/media/analysis/analysis/english/CCHR_Briefing_Note-Freedom_of_Assembly_on_hold_ENG.pdf; ស៊ន ធីហាន និង ដានីញែល ឃ្វីនឡាន 'អំពើហិង្សាកើតឡើងថែមទៀតនៅទីលានប្រជាធិបតេយ្យ' *សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤): http://bit.ly/1kfIssi; យុត សុភ័ក្រ្ត ចរិយា និងខេវិន ប៉ុននៀ 'បាតុកម្មត្រូវបានបំបែកដោយហិង្សា' *សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤): http://bit.ly/1iF64Jy.

[46] មាស សុខជា 'នាយករដ្ឋមន្ត្រីសរសើរមន្ត្រីយោធាក្នុងការដោះស្រាយជាមួយបាតុករ' *សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤): http://bit.ly/1fDWXHF

ដុល្លារ សម្រាប់ការលើកទឹកចិត្តក្នុងការទប់ទល់នឹងបាតុកម្ម។[47] ក្នុងខែសីហា ឆ្នាំ២០១៤ អភិបាលក្រុងភ្នំពេញ ប៉ា សុជាតិវង្ស បានផ្តល់រង្វាន់ដល់មន្ត្រីយោធាប្រមាណ ១.០០០ នាក់ សម្រាប់ការអនុវត្តការងារ "ដ៏ល្អឥតខ្ចោះ" កាលពីឆ្នាំមុនដោយបានចំណាយថវិកាអស់ចំនួន ៣០.០០០ ដុល្លារ។[48]

ករណីដែលបានលើកឡើងក្នុងបញ្ហាទី ៨ និងបញ្ហាទី ៩ និងករណីប្រហាក់ប្រហែលដទៃទៀត មិនដែលទទួលបានការស៊ើបអង្កេតដោយពេញលេញនោះទេ ហើយក៏មិនមាននរណាម្នាក់ត្រូវចោទប្រកាន់នោះដែរ។ ម.ស.ម.ក មិនបានដឹងថាមានមន្ត្រីនគរបាល ឬសន្តិសុខណាមួយត្រូវបានផ្តន្ទាទោស ដោយសារតែការប្រើទារុណកម្ម ឬប្រព្រឹត្តិមិនគប្បីនោះដែរ។ ចំណុចនេះផ្ទុយទាំងស្រុងនឹងរបាយការណ៍រាប់រយដែលបានឃើញភាពឃោរឃៅរបស់មន្ត្រីនគរបាល។ មន្ត្រីនគរបាល និងសន្តិសុខខណ្ឌដូនពេញ បានប្រព្រឹត្តនូវទង្វើនិទណ្ឌភាព។ បន្ថែមពីលើនោះ ជនរងគ្រោះដោយបានទារុណកម្ម និងមេធាវីរបស់ពួកគេស្ទាក់ស្ទើរក្នុងការលើកយកការចោទប្រកាន់នេះដាក់ ទៅកាន់ព្រះរាជអាជ្ញា ឬតុលាការ ពីព្រោះថាមន្ត្រីនគរបាលណាមួយដែលមិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោស អាចប្តឹងបកពីបទព្រហ្មទណ្ឌទៅលើជនរងគ្រោះ និងមេធាវីរបស់ពួកគេបាន។ ដូច្នេះ ជនរងគ្រោះ និងមេធាវីរបស់ពួកគេអាចនឹងត្រូវប្រឈមមុខនឹងការផ្តន្ទាទោសព្រហ្មទណ្ឌនិងការផាកពិន័យ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ប្រើប្រាស់មន្ត្រីយោធាក្នុងករណីដែលមានបញ្ហាសន្តិសុខធ្ងន់ធ្ងរតែប៉ុណ្ណោះ និងបញ្ឈប់នូវរាល់ការប្រើប្រាស់កងកម្លាំងសន្តិសុខ ក្នុងការឃ្លាំមើលបាតុកម្ម*
- *ធានាថាមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធនឹងការឃ្លាំមើលបាតុកម្ម គោរពតាមគោលការណ៍មូលដ្ឋានរបស់ អ.ស.ប ស្តីពីការប្រើប្រាស់កម្លាំង និងអាវុធ និងក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីទាំងនេះ ត្រូវបានបណ្តុះបណ្តាលឲ្យបានពេញលេញទៅលើច្បាប់ខាងលើ និងច្បាប់សិទ្ធិមនុស្ស និងបទដ្ឋានដែលពាក់ព័ន្ធដទៃទៀត*
- *ធានាឲ្យមានការស៊ើបអង្កេតប្រកបដោយប្រសិទ្ធិភាព ម៉ត់ចត់ និងទាន់ពេលវេលា និងដាក់ទោសដល់ជនល្មើសដោយស្ថាប័នឯករាជ្យ និងមិនលម្អៀង ទៅលើរបាយការណ៍នៃការប្រើប្រាស់កម្លាំងហួសហេតុ របស់មន្ត្រីអនុវត្តច្បាប់ និងកងកម្លាំងសន្តិសុខឯកជន ដែលពាក់ព័ន្ធនឹងការឃ្លាំមើលបាតុកម្ម និងថែមទាំងប្រកាសនូវលទ្ធផលនៃការស៊ើបអង្កេតនោះជាសាធារណៈ*
- *ទប់ស្កាត់ការប្រើប្រាស់កងម្លាំងសន្តិសុខឯកជនក្នុងការឃ្លាំមើលបាតុកម្ម។*

[47] ស៊ិន ជីហាន់ យុត សុភ័ក្រ្ត ចរិយា និង សែន ដាវីត 'បន្ទាប់ពីមានការបិទផ្លូវ សហជីពគ្រោងធ្វើសកម្មភាពបន្ទាប់' *សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤): http://bit.ly/NVz42C

[48] ឃួន ណារីម 'មន្ត្រីយោធាដ៏ "ល្អឥតខ្ចោះ" ត្រូវបានកោតសរសើរដោយផ្តល់ប្រាក់រង្វាន់' *សារព័ត៌មាន ខេមបូឌា ដេលី* (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤): https://www.cambodiadaily.com/news/perfect-military-police-honored-with-cash-67263/

## ៤. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ភាពស្មើគ្នាចំពោះមុខច្បាប់ សំណង និងការគ្រប់គ្រងនៃប្រព័ន្ធតុលាការ ( មាត្រា ៧ មាត្រា ១៤ និង មាត្រា ២៦ នៃ ក.អ.ស.ព.ន )

### ក. ការជ្រៀតជ្រែកមិនស្របច្បាប់របស់រដ្ឋាភិបាលក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

*បញ្ហាទី ១៥. បន្ថែមពីលើព័ត៌មានដែលបានផ្តល់ជូនក្នុងកថាខណ្ឌទី ៧៤ របស់របាយការណ៍តាមពេលវេលារបស់ភាគីរដ្ឋ សូមផ្តល់មតិយោបល់លើរបាយការណ៍នៃការអះអាងពីការរារាំង ការមិនសហការណ៍ និងការជ្រៀតជ្រែកក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។*

រយៈពេលជាប៉ុន្មានឆ្នាំនេះ រដ្ឋាភិបាលបានរារាំង ខកខានក្នុងការសហការណ៍ ព្រមទាំងជ្រៀតជ្រែកក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") តាមរយៈប្រឆាំងនឹងករណី ០០៣ និង ០០៤ ដោយបង្អួក និងបញ្ឈប់មូលនិធិ និងឧបសគ្គផ្សេងទៀត។

រដ្ឋាភិបាលបានបញ្ជាក់យ៉ាងបើកចំហ និងម្តងហើយម្តងទៀត អំពីការប្រឆាំងរបស់ខ្លួនទៅលើករណី ០០៣ និងករណី ០០៤ និងបង្ហាញជាសាធារណៈពីបំណងក្នុងការឃើញ អ.វ.ត.ក ត្រូវបានបិទ បន្ទាប់ពីបញ្ចប់ដំណើរការបច្ចុប្បន្ន។[49] ករណី ០០៣ និង ០០៤ ពាក់ព័ន្ធជាមួយនឹងកម្មាភិបាលខ្មែរក្រហមថ្នាក់កណ្តាល ដែលបច្ចុប្បន្នគឺជាសមាជិករដ្ឋាភិបាលកម្ពុជា និងជាមន្ត្រីជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល ដែលបានអះអាងថាការផ្តន្ទាទោសទៅលើពួកគេអាចនឹងធ្វើឲ្យកើតអស្ថេរភាពក្នុងប្រទេស។[50] ក្នុងខែមេសា ឆ្នាំ២០១១ ការស៊ើបអង្កេតដំបូងលើករណីពីរត្រូវបានបិទ។ ករណីទាំងពីរត្រូវបានរាយការណ៍ថាបើកឡើងវិញក្នុងខែកុម្ភៈ ឆ្នាំ២០១២ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង លោក ឡូរ៉ែន ខាស្ពើ អាន់ស៊ើមេត ដោយគ្មានការអនុញ្ញាតពីខាងតុលាការកម្ពុជានោះទេ។ ជាលទ្ធផល ធ្វើឲ្យក្នុងថវិការបស់ អ.វ.ត.ក មិនបានចាត់ចែងទៅលើផ្នែកធនធាន និងពេលវេលាសម្រាប់ករណីទាំងពីរនេះទេ។[51]

ក្នុងខែមីនា ឆ្នាំ២០១២ លោកចៅក្រម ខាស្ពើ អាន់ស៊ើមេត បានលាឈប់ពី អ.វ.ត.ក ដោយលើកឡើងពីអសមត្ថភាពក្នុងការ "អនុវត្តតួនាទីរបស់លោកឲ្យបានត្រឹមត្រូវ និងសេរី" ដោយសារតែមានការជ្រៀតជ្រែកផ្នែកនយោបាយ។ ដៃគូជនជាតិកម្ពុជារបស់លោកគឺលោកចៅក្រម យូ ប៊ុនឡេង បានជំទាស់ជាខ្លាំងទៅលើករណី ០០៣ និង ០០៤ ដែលចៅក្រម ខាស្ពើ អាន់ស៊ើមេត អះអាងថានឹងបណ្តាលឲ្យ "មានស្ថានភាពជ្រួលច្របល់នៅក្នុង អ.វ.ត.ក"។ ចៅក្រម យូ ប៊ុនឡេង ជំទាស់ទៅនឹងអំណាចក្នុងការអនុវត្តការងាររបស់ ចៅក្រម ខាស្ពើ អាន់ស៊ើមេត ក្នុងនាមជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង មុនពេលការមកដល់របស់លោកនៅកម្ពុជា និងជាពិសេសក៏មានការបដិសេធពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមក្នុងការតែងតាំងលោកជា សហចៅក្រមស៊ើបសួរអន្តរជាតិ។ ចំណុចនេះ គឺជាការបំពានលើកិច្ចសន្យារវាង អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការផ្តន្ទាទោសដោយប្រើក្រមព្រហ្មទណ្ឌកម្ពុជាលើបទល្មើសដែលប្រព្រឹត្តិក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") ដែលតម្រូវឲ្យ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមដែល

---

[49] ម.ស.ម.ក 'ការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា' (ខែតុលា ឆ្នាំ២០១៣) http://bit.ly/1tHe7pn.

[50] ចេមស៍ អូ ធូល 'ជំណឹងថ្មីៗពីចៅក្រមសាលាក្តីខ្មែរក្រហម' *សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍* 2://www.phnompenhpost.com/national/judges February 2011, http-give-krt-update.

[51] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សំណើថវិកាសម្រាប់ ឆ្នាំ២០១២ ដល់ ២០១៣ (ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២), http://www.eccc.gov.kh/sites/default/files/ECCC%20Budget%202012-2013.pdf.

ស្នើឈ្មោះដោយ អ.ស.ប។[52] ចំណុចនេះរាំងស្ទះដល់ កិច្ចខំប្រឹងប្រែងរបស់ ខាស្តើ អាន់ស៊ើមេត ក្នុងការរៀបចំនូវការស៊ើបអង្កេតចាំបាច់ ឬសកម្មភាពផ្នែកផ្លូវច្បាប់ក្នុងករណី ០០៣ និង ០០៤។[53] កំណត់សម្គាល់របស់ ចៅក្រម ខាស្តើ អាន់ស៊ើមេត បានលើកឡើងថាដៃគូជនជាតិកម្ពុជា មិនបានឆ្លើយតបនឹងសំណើជាផ្លូវការ ហើយបដិសេធក្នុងការផ្សព្វផ្សាយឯកសារដែលនៅក្នុងសំណុំរឿង និងបដិសេធការប្រើអ្នកបកប្រែ និងត្រាផ្លូវការរបស់តុលាការ។ លោកចៅក្រម ប្លាំង នៃប្រទេសអាល្លឺម៉ង់ ដែលជាអ្នកបន្តតំណែងពីលោក ខាស្តើ អាន់ស៊ើមេត ទើបតែបានលាលែងពីតំណែងកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១១ បន្ទាប់ពីមានការព្រួយបារម្ភស្រដៀងគ្នាទៅនឹងការព្រួយបារម្ភរបស់លោក ខាស្តើ អាន់ស៊ើមេត។

នៅពេលនោះ រដ្ឋាភិបាលក៏បានបដិសេធក្នុងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុចំពោះតុលាការផ្នែកខាងកម្ពុជា ដូច្នេះនេះគឺជាការរំលោភបំពានលើកិច្ចព្រមព្រៀងដែលបង្កើតឡើងដោយ អ.វ.ត.ក។ ការខកខានក្នុងការបង់ប្រាក់ខែសម្រាប់បុគ្គលិកកម្ពុជា គឺជាឧទាហរណ៍នៃបច្ចេកទេសក្នុងការបង្អាក់ និងរារាំងដើម្បីរំខានដល់កិច្ចខិតខំប្រឹងប្រែងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមយកមកកាត់ទោស។[54]

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ធានាថាមានកិច្ចខំប្រឹងប្រែងជាក់លាក់បានដាក់ឡើងដើម្បីបន្តករណី ០០៣ និង ០០៤ និងដើម្បីរៀបចំឲ្យមានការស៊ើបអង្កេតពេញលេញទៅលើការចោទប្រកាន់ពីការជ្រៀតជ្រែកផ្នែកនយោបាយ*
- *បំពេញកាតព្វកិច្ចផ្នែកផ្លូវច្បាប់ និងផ្តល់ថវិកាឲ្យគ្រប់គ្រាន់ដើម្បីផ្តល់ប្រាក់បៀវត្សរ៍សម្រាប់ បុគ្គលិកថ្នាក់ជាតិ របស់ អ.វ.ត.ក ដោយគ្មានការយឺតយ៉ាវ។*

## ខ. កង្វះខាតឯករាជ្យភាពក្នុងប្រព័ន្ធតុលាការទាំងស្រុង

*បញ្ហាទី ១៧. សូមផ្តល់ព័ត៌មានស្តីពីវិធានការផ្នែកច្បាប់ និងវិធានការអនុវត្តជាក់ស្តែង ដើម្បីធានាឯករាជ្យភាព និងមិនលម្អៀងរបស់តុលាការ។ ក្នុងករណីនេះ សូមបញ្ជាក់ពីមាតិកានៃសេចក្តីព្រាងច្បាប់ដូចខាងក្រោម ៖ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការ ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា។ ព័ត៌មាននៅចំពោះមុខ គណៈកម្មាធិការ បានអះអាងពីកង្វះខាតក្នុងស្ថាប័នភាគីរដ្ឋ ជាពិសេស លើការខ្វះខាតធនធានបុគ្គលិក និងហិរញ្ញវត្ថុ។ តើមានវិធានការបែបណាដែលដាក់ឡើងដើម្បីដោះស្រាយស្ថានភាពបែបនេះ?*

ថ្វីបើមាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ បានចែងពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងការអនុម័តថ្មីៗ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការតុលាការ ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអា*ជ្ញា* ប៉ុន្តែនៅតែមានភាពខ្វះខាតនូវវិធានការដែលធានាឯករាជ្យភាព និងភាពមិនលម្អៀងរបស់ប្រព័ន្ធតុលាការ។ មានទឡ្ហីករណ៍នៃការជះឥទ្ធិពលដោយមិនត្រឹមត្រូវពីអំណាចនីតិប្រតិបត្តិ ទៅលើតួនាទីរបស់តុលាការ ដែលធ្វើ

---

[52] ម.ស.ម.ក 'រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែគោរពកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក បើមិនដូច្នេះទេនឹងប្រឈមដល់ការប៉ះពាល់លើសាលាក្តីទាំងមូល' (ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២), http://bit.ly/1rSH6qt

[53] ម.ស.ម.ក 'សលាកប័ត្រព័ត៌មាន - អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា' (ខែកក្កដា ឆ្នាំ២០១២), http://bit.ly/12kzp6F.

[54] ម.ស.ម.ក 'រាជរដ្ឋាភិបាលកម្ពុជា ត្រូវតែគោរពកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក បើមិនដូច្នេះទេនឹងប្រឈមដល់ការប៉ះពាល់លើសាលាក្តីទាំងមូល' (ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២), http://bit.ly/1rSH6qt.

ឲ្យរំខានឯករាជ្យភាពនៃតុលាការ និងអនុញ្ញាតឲ្យតុលាការត្រូវបានប្រើប្រាស់ជាឧបករណ៍ផ្នែកនយោបាយ។ ករណីដែលជំរុញដោយរឿងពាក់ព័ន្ធនឹងនយោបាយ តែងតែត្រូវនាំយកមកធ្វើសវនាការនៅចំពោះមុខតុលាការ ដោយដៅមុខសញ្ញាទៅលើអ្នកនយោបាយបក្សប្រឆាំង សកម្មជនដីធ្លី និងអ្នកការពារសិទ្ធិមនុស្ស។ ផ្ទុយមកវិញ និទណ្ឌភាព កំពុងតែរីករាលដាលការពារអ្នកមានអំណាច។

ច្បាប់ទាំង ៣ ដែលបានលើកឡើងខាងលើ ត្រូវបានអនុម័តយ៉ាងលឿនក្នុង ខែកក្កដា ឆ្នាំ២០១៤ ដែលកាន់តែចាក់ឫសគល់នៃអំណាចនីតិប្រតិបត្តិទៅលើអំណាចតុលាការ។ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ("ច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម") បានបញ្ជាក់ពីតួនាទីនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ មាត្រា ១ នៃច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បញ្ជាក់ថាខ្លួននឹងជួយដល់ព្រះមហាក្សត្រក្នុងការធានានូវឯករាជ្យភាពរបស់ប្រព័ន្ធ តុលាការ ដូចបានចែងក្នុងរដ្ឋធម្មនុញ្ញ។ យោងតាមមាត្រា ១៨ នៃច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែងថាឧត្តមក្រុមប្រឹក្សានេះ នឹងមានអំណាចសម្រេច និងស្នើទៅព្រះមហាក្សត្រឲ្យមានការតែងតាំង ការផ្លាស់ប្តូរ ការផ្តាច់ពីមុខងារ ការដាក់ឲ្យនៅក្រៅក្របខណ្ឌ ការដាក់ឲ្យនៅទំនេរ និងការលុបឈ្មោះចៅក្រម និងសកម្មភាពវិន័យលើចៅក្រម និងព្រះរាជអាជ្ញា។ ដូច្នេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាស្ថាប័នដ៏សំខាន់ក្នុងការធានាឯករាជ្យភាពប្រព័ន្ធតុលាការ។ ប៉ុន្តែ យោងតាមមាត្រា ៤ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គឺជាសមាជិក របស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយស្វយប្រវត្តិ និងបន្ថែមពីលើនោះ នឹងមានបុព្វសិទ្ធិជ្រើសតាំងសមាជិកសម្រាប់ក្រុមប្រឹក្សានេះផងដែរ។ មាត្រា ៤ ក៏បានអនុញ្ញាតឲ្យសមាជិកនៃរដ្ឋសភា និងព្រឹទ្ធសភាបោះឆ្នោតតែងតាំងសមាជិកថែមទៀតផង។ បន្ថែមពីលើនោះ ច្បាប់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានដាក់ឲ្យថវិការបស់ឧត្តមក្រុមប្រឹក្សានេះ និងអគ្គលេខាធិការដ្ឋានក្រោមរដ្ឋបាលកណ្តាលនៃក្រសួងយុត្តិធម៌ យោងតាមមាត្រា ៨ និង ១៥។

ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ផ្តល់អំណាចដល់ក្រសួងយុត្តិធម៌ក្នុងជះឥទ្ធិពលលើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់ចៅក្រម និងព្រះរាជអាជ្ញា។ គណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ("គណៈកម្មការ") បង្កើតឡើងដោយមាត្រា ៣៣ កំណត់នូវឋានន្តរស័ក្តិរបស់ចៅក្រម និងព្រះរាជអាជ្ញា។ គណៈកម្មការដែលមានសមាជិកចំនួន ៨ នាក់ មានប្រធានជារដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដែលមិនបានកំណត់ពីកម្រិតនៃអំណាចដាក់លាក់នោះទេ។ ចំណុចនេះបានគំរាមកំហែងលើឯករាជ្យភាពរបស់ចៅក្រម ដែលអាចនឹងត្រូវបានប្រើប្រាស់ដោយអំណាចនីតិប្រតិបត្តិដើម្បីដំឡើងឋានន្តរស័ក្តិរបស់ពួកគេ។[55]

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គការតុលាការ កំណត់ពីការរៀបចំ យុត្តាធិការ ការប្រព្រឹត្តទៅ និងហិរញ្ញវត្ថុនៅតុលាការ និងការិយាល័យព្រះរាជអាជ្ញាទាំងអស់។ ជំនួសឲ្យការដាក់ឲ្យ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គ្រប់គ្រងលើរដ្ឋបាល និងការគ្រប់គ្រងរបស់តុលាការ មាត្រា ១១ បានផ្ទេរអំណាចនេះទៅក្រសួងយុត្តិធម៌។ មាត្រា ៤៨ ក៏

[55] ម.ស.ម.ក 'ច្បាប់ទាំងបីពាក់ព័ន្ធនឹងវិស័យតុលាការ' ទំព័រទី ៨-៩ (ខែឧសភា ឆ្នាំ២០១៤) http://bit.ly/15M7EVV

បានកំណត់ផងដែរថាថវិការបស់តុលាការ គឺចាត់ចែងមកពីថវិការបស់ក្រសួងយុត្តិធម៌ ដែលកំណត់ទីកន្លែង និងរបៀបដែលថវិកានេះត្រូវបានចាត់ចែងរវាងតុលាការនីមួយៗ។[56]

ក្នុងរបាយការណ៍ចុងក្រោយទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងខែកញ្ញា ឆ្នាំ២០១៤ អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អះអាងជាថ្មីម្ដងទៀតពីការព្រួយបារម្ភរបស់លោក ទៅលើច្បាប់ទាំងបីដោយសារតែច្បាប់ទាំងនេះ "មានបញ្ញត្តដែលធ្វើឲ្យអន្តរាយដល់ការបែងចែកអំណាច"។[57] គណៈកម្មាធិការប្រឆាំងនឹងទារុណកម្ម បានបង្ហាញពីការព្រួយបារម្ភប្រហាក់ប្រហែលគ្នាស្ដីពីឯករាជ្យភាពនៃប្រព័ន្ធតុលាការ នៅក្នុងរបាយការណ៍សង្កេតបញ្ចប់របស់ខ្លួន ដែលបានអនុម័តក្នុង ឆ្នាំ២០១១។[58]

## គ. កង្វះខាតវគ្គបណ្ដុះបណ្ដាលផ្នែកច្បាប់ និងធនធានដែលធ្វើឲ្យគុណភាពនៃការកាត់ក្ដីធ្លាក់ចុះ

*បញ្ហាទី ១៧ [បន្ត ]*

រដ្ឋាភិបាល ចាត់វិធានការមិនទាន់បានគ្រប់គ្រាន់ក្នុងការផ្ដល់ឲ្យតុលាការនូវមូលនិធិធនធាន និងវគ្គបណ្ដុះបណ្ដាលគ្រប់គ្រាន់នោះទេ។ ឧទាហរណ៍ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដែលបានបើកក្នុង ឆ្នាំ២០០៣ បន្តរងការខូចកេរ្តិ៍ឈ្មោះពីបទចោទថាមានអំពើសូកប៉ាន់ និងអំពើពុករលួយ ដោយមានការតែងតាំងចៅក្រមសម្រាប់អ្នកដែលដេញថ្លៃបានខ្ពស់បំផុត ជាជាងរកអ្នកដែលមានសមត្ថភាពបំផុត។ គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក តែងតែតាមដានករណីដែលចៅក្រម ប្រកាសសាលក្រមដោយគ្មានហេតុផលផ្នែកច្បាប់ ឬប្រសិនបើមានក៏តិចតួចដែរ ដោយគុណភាពនៃអំណះអំណាងផ្នែកច្បាប់ក្នុងតុលាការគឺមានភាពអន់ខ្សោយខ្លាំងណាស់។ ឧទាហរណ៍ ក្នុង ៧៤,៥% នៃករណីដែលតាមដាននៅឯសាលាឧទ្ធរណ៍នៃទីក្រុងភ្នំពេញ ចន្លោះចាប់ពីខែមីនា ឆ្នាំ២០១៣ ដល់ ខែមករា ឆ្នាំ២០១៤ ចៅក្រមខកខានក្នុងការលើកយកនូវច្បាប់ដែលពាក់ព័ន្ធនឹងបទល្មើស។[59] បន្ថែមពីលើនោះ ភាពស្មុគស្មាញនៃផ្នែកច្បាប់ តែងតែមិនត្រូវបានយកចិត្តទុកដាក់ ហើយភស្តុតាងគឺកម្រត្រួតពិនិត្យឲ្យបានម៉ត់ចត់ សវនាការតែងតែប្រញាប់ប្រញាល់ ជាមួយនឹងសាលក្រមដែលមិនសូវមានភាពទាក់ទងនឹងភស្តុតាងដែលបានបង្ហាញ ហើយការចោទប្រកាន់ជាញឹកញាប់គឺផ្អែកលើការសារភាពទោះបីជាអវត្តមានភស្តុតាងបន្ថែមក៏ដោយ។ ការខកខានក្នុងការធ្វើតាមនីតិវិធីផ្នែកច្បាប់តិចតួចបែបនេះ អាចកើតឡើងដោយសារតែកង្វះវគ្គបណ្ដុះបណ្ដាលផ្នែកច្បាប់ប្រកបដោយគុណភាព។ ចៅក្រមតែងតែបរាជ័យក្នុងការប្រាប់ដល់ចុងចោទពីសិទ្ធិដែលកំណត់ដោយច្បាប់ ប៉ុន្តែបើចុងចោទត្រូវប្រាប់ពីសិទ្ធិរបស់ខ្លួន ក៏ចៅក្រមតែងតែខកខានក្នុងការពន្យល់ឲ្យបានច្បាស់លាស់ដល់ ចុងចោទផងដែរ។ ក្នុងអំឡុងរបាយការណ៍ទី ៥ នៃ គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក នៅក្នុងសាលាដំបូង ចាប់ពីថ្ងៃទី១ ខែកក្កដា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ចៅក្រមបានប្រាប់ និងពន្យល់ពីសិទ្ធិចុងចោទ

---

[56] ដូចខាងលើ ទំព័រទី ១០។

[57] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្រ្តាចារ្យ សូរិយា ភី. ស៊ូបេឌី (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤), A/HRC/27/70

[58] គណៈកម្មាធិការ អង្គការសហប្រជាជាតិ ប្រឆាំងនឹងទារុណកម្ម សេចក្ដីសង្កេតបញ្ចប់ស្ដីពីកម្ពុជា (ថ្ងៃទី២០ ខែមករា ឆ្នាំ២០១១), CAT/C/KHM/CO/2, http://docstore.ohchr.org/SelfServices/FilesHandler.ashx?enc=6QkG1d%2fPPRiCAqhKb7yhsjIcinYfXfIBAeGV1xgrevjA948RB8JUq8xvITFYWnZJkGmwpl%2bgeByCF5oXYGrXRS%2bX1gICAWZDJRUlIMVdbpFENmaaPP4CBTgisOWZewbl

[59] ចាប់ពីខែមីនា ឆ្នាំ២០១៣ និងខែមករា ឆ្នាំ២០១៤ មានករណី ២០៤ ត្រូវបានសង្កេត។

ក្នុងការទទួលបានតំណាងស្របច្បាប់ និងសិទ្ធិក្នុងការមិននិយាយស្ដី មានត្រឹមតែ ២% ប៉ុណ្ណោះក្នុងករណីទាំងអស់។ នៅឯសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ មានករណីតែ ១ ក្នុងចំណោមករណីចំនួន ២០៤ ដែលចៅក្រមបានពន្យល់ពីសិទ្ធិមិននិយាយស្ដី ហើយក្នុងករណីចំនួន ៥ ដែលចុងចោទត្រូវបានពន្យល់ពីសិទ្ធិទទួលបានតំណាងស្របច្បាប់។[60]

ចំណុចខ្សោយ ក្នុងវិស័យច្បាប់ និងតុលាការ បែបនេះ កើតឡើងដោយសារកង្វះធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ។ ក្នុងអំឡុងកិច្ចប្រជុំពិភាក្សារវាងសមាជិកតុលាការ និងក្រុមអ្នកសង្កេតការណ៍របស់ ម.ស.ម.ក ចៅក្រមបានបញ្ជាក់ថាមេធាវីការពារចុងចោទ ពេលខ្លះត្រូវបានតែងតាំងនៅចំថ្ងៃដែលធ្វើសវនាការតែម្ដង ដោយសារតែមិនមានមេធាវីគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងនីតិវិធីធម្មតា ដូចជាបង្ហាញសេចក្ដីប្រកាសជាសាធារណៈពីសវនាការ។ កង្វះខាតចំនួនមេធាវី ជាពិសេស មេធាវីការពារចុងចោទ គឺជាឧបសគ្គក្នុងការទទួលបានយុត្តិធម៌ និងថែមទាំងមានឥទ្ធិពលជាអវិជ្ជមានទៅលើគុណភាពនៃអ្នកតំណាង ប្រសិនបើមេធាវីនោះមិនអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំរឿងក្ដីទេនោះ។ ម.ស.ម.ក មិនបានដឹងពីចំណាត់ការណាដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីដោះស្រាយកង្វះខាតផ្នែកមូលនិធិធនធាន និងវគ្គបណ្ដុះបណ្ដាលនោះទេ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្ដល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *រដ្ឋាភិបាលនិរាករណ៍ ច្បាប់ដែលបានអនុម័តថ្មីៗស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ និងអយ្យការ និងច្បាប់ស្ដីពីវិសោធនកម្មនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្ដីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ឬក៏ធ្វើវិសោធនកម្មច្បាប់ទាំងនោះ ដើម្បីធានាថា ៖*
    - *សមាជិកនៃ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិកនៃក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងសមាជិកនៃគណៈកម្មការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ត្រូវបានបោះឆ្នោតដោយចៅក្រម និងព្រះរាជអាជ្ញា។ បេក្ខជននៃការបោះឆ្នោត មិនគួរមានជាប់ពាក់ព័ន្ធនឹងអំណាចនីតិបញ្ញត្ត និងនីតិប្រតិបត្តិ និងគួរតែរួមបញ្ចូលបុគ្គលដែលមិនមែនជាតុលាការផងដែរ*
    - *ក្រសួងយុត្តិធម៌មិនគួរមានអំណាចគ្រប់គ្រងលើនាយកដ្ឋានគ្រប់គ្រងតុលាការនោះទេ និង*
    - *ក្រសួងយុត្តិធម៌មិនគួរគ្រប់គ្រងលើហិរញ្ញវត្ថុរបស់សវនាការរបស់តុលាការ និងការិយាល័យព្រះរាជអាជ្ញានោះទេ ជំនួសមកវិញ គឺអំណាចនោះគួរតែជារបស់ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម*
- *ការបណ្ដុះបណ្ដាលសម្រាប់តុលាការគួរតែធ្វើឲ្យប្រសើរឡើង ចាប់តាំងពីដំណាក់កាលដំបូងបំផុតសម្រាប់ មេធាវី ចៅក្រម និងព្រះរាជអាជ្ញា ដោយផ្ដោតលើអំណះអំណាងផ្នែកច្បាប់ វិធានសម្រាប់ភស្ដុតាង និងគោលការណ៍នៃការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ដែលត្រូវតាមស្តង់ដារ។ អនុសាសន៍ខាងក្រោម គួរតែត្រូវអនុវត្ត ៖*
    - *គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គួរតែមានតួនាទីយ៉ាងសកម្មក្នុងការអប់រំមេធាវីហាត់ការ ហើយថែមទាំងបង្កើតនូវគម្រោងអភិវឌ្ឍន៍បុគ្គលិកជាបន្តប្រកបដោយប្រសិទ្ធភាព សម្រាប់មេធាវីអាជីព*

[60] ម.ស.ម.ក ‘កំណែទម្រង់ប្រព័ន្ធតុលាការ’ (ខែតុលា ឆ្នាំ២០១៤), ៥-៦ http://bit.ly/1vzg8t9.

- *ធនធានហិរញ្ញវត្ថុបន្ថែមគួរតែផ្តល់សម្រាប់វិស័យច្បាប់ និងតុលាការ ដើម្បីធានាថាតុលាការមានសម្ភារៈគ្រប់គ្រាន់ និងមានចំនួនមេធាវីផ្តល់ជំនួយផ្នែកច្បាប់គ្រប់គ្រាន់ និង*
  - *គួរតែធ្វើសេចក្តីព្រាង ក្រមសីលធម៌ដ៏មានទម្ងន់សម្រាប់ចៅក្រម និងអនុវត្តដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធានាឲ្យមានស្តង់ដារវិជ្ជាជីវៈគ្រប់គ្រាន់ ក្នុងប្រព័ន្ធតុលាការ។*
- *អញ្ជើញអ្នករាយការណ៍ពិសេស ស្តីពីឯករាជ្យភាពតុលាការ និងមេធាវី ដើម្បីមកទស្សនកិច្ចនៅប្រទេសកម្ពុជា។ ការធ្វើទស្សនកិច្ចនៅក្នុងប្រទេស បានដាក់ស្នើតាំងពី ឆ្នាំ២០០៦ និងមានការដាក់លិខិតរំលឹកនៅក្នុងឆ្នាំដដែលនោះ តែមិនមានការឆ្លើយតបនោះទេ។*

## ឃ. ការបង្ខិតបង្ខំឲ្យសារភាព និងកង្វះខាតមធ្យោបាយសមស្របក្នុងការស៊ើបអង្កេត

***បញ្ហាទី ១៨. សូមផ្តល់យោបល់លើរបាយការណ៍ ចំពោះការបន្តបង្ខិតបង្ខំឲ្យសារភាព ជាជាតុផ្សំនៃភស្តុតាងសម្រាប់នីតិវិធីតុលាការ ថ្វីបើការអនុវត្តន៍បែបនោះខុសនឹងច្បាប់ក៏ដោយ។***

ចាប់ពីខែសីហា ឆ្នាំ២០០៩ ដល់ខែមិថុនា ឆ្នាំ២០១២ ម.ស.ម.ក បានតាមដាន និងរាយការណ៍ស្តីពីស្តង់ដារសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅសាលាដំបូងទីក្រុងភ្នំពេញ តុលាការខេត្តកណ្តាល ខេត្តបន្ទាយមានជ័យ និងខេត្តរតនៈគិរី និងសាលាឧទ្ធរណ៍ពីខែមីនា ឆ្នាំ២០១៣ ដល់ ខែមករា ឆ្នាំ២០១៤។ ចាប់ពីខែសីហា ឆ្នាំ២០០៩ និងខែមករា ឆ្នាំ២០១៤ សវនាការចំនួន ២.៧៣៥ ត្រូវបានសង្កេតការណ៍។ ក្នុងចំណោមករណីទាំងនេះ ការចោទប្រកាន់ដែលមានការគំរាមកំហែង ដើម្បីបង្ខំឲ្យជនជាប់ចោទសារភាពនូវបទល្មើសចោទប្រកាន់ផ្សេងៗ ត្រូវបានរាយការណ៍នៅក្នុងសវនាការចំនួន ១១៩ ឬ ស្មើនឹង ៤,៤% នៃសវនាការដែលបានសង្កេតការណ៍។ បន្ថែមពីលើនោះ ក្នុងសវនាការចំនួន ១៦៥ ឬ ៦% ដែលត្រូវបានសង្កេត ជនជាប់ចោទ ឬមេធាវីចុងចោទ បានលើកឡើងថាមានករណីហិង្សា ឬទារុណកម្ម ត្រូវបានប្រើប្រាស់ដើម្បីបង្ខំជនជាប់ចោទសារភាព។ នៅឆ្នាំ២០១២ មេធាវីតំណាងមួយចំនួន នៃតុលាការខេត្តបន្ទាយមានជ័យ បានពន្យល់ថាមាន ៨០% នៃជនជាប់ចោទផ្លាស់ប្តូរការឆ្លើយតបរបស់ខ្លួន ក្នុងសវនាការ ដោយអះអាងថាមន្ត្រីនគរបាលទទួលបានការសារភាព ដោយសារតែមានការធ្វើទារុណកម្ម ប៉ុន្តែខកខានក្នុងការបង្ហាញភស្តុតាងជាក់លាក់ ហើយចៅក្រមបានសម្រាលទោសប្រសិនបើជនជាប់ចោទយល់ព្រមសារភាពទោស។[61] អ្នកតំណាងមួយចំនួន របស់សាលាដំបូងរាជធានីភ្នំពេញ បានលើកឡើងពីករណីប្រហាក់ប្រហែលគ្នានេះថាជនជាប់ចោទតែងតែខកខានក្នុងការលើកយកភស្តុតាងពីទារុណកម្ម ឬការគំរាមកំហែង ការសារភាពអាចទទួលយកបានជាភស្តុតាង ហើយនៅពេលដែលជនជាប់ចោទអះអាងថា ពួកគាត់ត្រូវបានធ្វើទារុណកម្ម ចៅក្រមតែងតែសួរចម្លើយដំបូងបំផុតជាមួយមន្ត្រីយុត្តិធម៌ ដែលជាអ្នកអះអាងថាជនល្មើស។[62]

ដូច្នេះ ភាពប្រថុយប្រថានធ្ងន់ធ្ងរ គឺការសារភាពដោយបង្ខិតបង្ខំតែងតែត្រូវបានប្រើក្នុងនីតិវិធីតុលាការ។ ខណៈដែលមានករណីតែមួយចំនួនតូចដែលមានការចោទប្រកាន់ពីការបង្ខិតបង្ខំខាងផ្លូវចិត្ត និងរូបរាងកាយ ការសង្កេតការណ៍

---

[61] ចំណុចនេះត្រូវបានរាយការណ៍ដោយចៅក្រមមួយចំនួនទាំងក្នុងកិច្ចប្រជុំមិនផ្លូវការ និងប្រជុំសម្ងាត់រវាង ក្រុមការងារ ម.ស.ម.ក និងចៅក្រមមកពីតុលាការខេត្តរតនៈគិរី និងបន្ទាយមានជ័យ (ថ្ងៃទី១០ – ១៤ ខែកញ្ញា ឆ្នាំ២០១២) និតចៅក្រមនៃតុលាការក្រុងភ្នំពេញ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២).

[62] ដូចខាងលើ។

សវនាការរបស់ ម.ស.ម.ក បានកត់សំគាល់ឃើញថាករណីមួយចំនួនដែលចៅក្រម មិនយកចិត្តទុកដាក់លើពួកគេ ដោយគ្រាន់តែសួរចុងចោទឲ្យផ្តល់ភស្តុតាងពីការបង្ខិតបង្ខំសារភាព ឬគ្រាន់តែសួរសំណួរថាហេតុអ្វីក៏មិនព្រមតបតវិញ តាំងពីដំណាក់កាលដំបូង។ មិនមានការស៊ើបអង្កេតឲ្យបានម៉ត់ចត់ ឬការចោទសួរត្រូវបានកត់ត្រាទុកនោះទេ។ បន្ថែមពីលើចៅក្រម មិនព្រមចេញបញ្ជា ឬជំរុញឲ្យមានការប្រមូលភស្តុតាង ប្រសិនបើចុងចោទអះអាងថាមានទារុណកម្ម ឬការប្រព្រឹត្តអមនុស្សធម៌។ មិនមានករណីណាមួយដែលម.ស.ម.ក បានឃើញចៅក្រមសាកសួរ និងបង្គាប់បញ្ជាឲ្យមានការធ្វើកោសល្យវិច្ច័យដើម្បីរកភស្តុតាងផ្នែកវិជ្ជសាស្ត្រ ឬចោទសួរទៅលើនគរបាលពាក់ព័ន្ធដែលមានបន្ទុកចងក្រងទៅលើចម្លើយសាកសួរនោះទេ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ព័ត៌មានដែលកំណត់ពីសិទ្ធិ និងការផ្តល់សិទ្ធិស្របច្បាប់ សម្រាប់ចុងចោទ ត្រូវបានចែកផ្សាយឲ្យបានទូលំទូលាយ និងអាចរកបានតាំងពីដើមដំបូងនៃនីតិវិធី*
- *ការចោទប្រកាន់ពីការសារភាពដោយបង្ខំ ត្រូវបានធ្វើការស៊ើបអង្កេតបានម៉ត់ចត់ ពេញច្បាប់ ក្នុងដំណាក់កាលនីមួយៗទៅតាមនីតិវិធី*
- *ការសម្រេចសេចក្តីដោយផ្អែកលើការសារភាពគ្មានតម្លៃជាភស្តុតាង ប្រសិនបើមានការបង្ខិតបង្ខំណាមួយត្រូវបានបញ្ជាក់ជាភស្តុតាង ដូចមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ*
- *អនុវត្តមធ្យោបាយស៊ើបអង្កេតផ្សេងទៀត និងដាក់ទម្ងន់តិចតួចទៅលើការសារភាព។*

## ៥. សេរីភាពខាងការបញ្ចេញមតិ និងខាងសមាគម និងសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី (មាត្រា ១៩ មាត្រា ២១ និង មាត្រា ២២ នៃ ក.អ.ស.ព.ន)

*បញ្ហាទី ១៩. សូមផ្តល់មតិស្តីពីសេរីភាពខាងការបញ្ចេញមតិ ដែលត្រូវបានធានានៅកម្ពុជា ជាពិសេស ចាប់តាំងពីក្រមព្រហ្មទណ្ឌថ្មីចូលជាធរមាន។ សូមបង្ហាញដោយលម្អិតពីការផ្លាស់ប្តូរ ដែលមាននៅក្នុងក្រមព្រហ្មទណ្ឌថ្មី ពាក់ព័ន្ធនឹងបទបរិហារកេរ្តិ៍ ការផ្តល់ព័ត៌មានមិនពិត និងបទញុះញង់។ សូមផ្តល់យោបល់ទៅលើការអះអាងដែលថាសកម្មជនសិទ្ធិមនុស្ស និងអ្នកសារព័ត៌មានបន្តរងការគំរាមកំហែង និងយាយី រួមទាំងការចោទប្រកាន់ដែលជំរុញដោយបញ្ហានយោបាយ។ សូមបញ្ជាក់ពីចំនួន នីតិវិធីព្រហ្មទណ្ឌដែលបានដាក់ឡើងក្នុងអំឡុងរយៈពេលនៃការពិនិត្យ ក្នុងករណីប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន និងតួអង្គសង្គមស៊ីវិលដទៃទៀត ពីបទបរិហារកេរ្តិ៍ បទបរិហារបង្ខូចកេរ្តិ៍ និងញុះញង់។*

សេរីភាពខាងការបញ្ចេញមតិគឺត្រូវបានធានាដោយច្បាប់ក្នុងប្រទេសកម្ពុជា។ ទាំងនៅក្នុងច្បាប់ជាតិ និងឧបករណ៍អន្តរជាតិ បានចែងថាកម្ពុជាមានកាតព្វកិច្ចការពារសិទ្ធិមូលដ្ឋានមួយនេះ។ ប៉ុន្តែ ស្ថានភាពសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ដែលស្ថិតក្នុងលំដាប់ថ្នាក់ ១៣៩ ក្នុងចំណោម ប្រទេសទាំង ១៨០ នៅក្នុងសន្ទស្សន៍វាស់វែងសេរីភាពពិភពលោករបស់អ្នកសារព័ត៌មានគ្មានព្រំដែន នៅតែស្ថិតក្នុងស្ថានភាពគួរឲ្យព្រួយបារម្ភ។

មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធានាថាប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ទទួលព័ត៌មាន និងការបោះពុម្ពផ្សាយដោយគ្មានព្រំដែនកំណត់ ដែលស្តាប់ទៅសមហេតុផលអ្នកវិភាគមួយចំនួន។[63] ថ្វីបើមានការធានាបែបនេះ ច្បាប់ក្នុងស្រុកមួយចំនួន មានលក្ខណៈផ្ទុយនឹងច្បាប់រដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា ដូច្នេះ បង្កើតនូវក្របខណ្ឌច្បាប់ដ៏ស្មុគស្មាញ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអនុវត្តសេរីភាពមូលដ្ឋាន។

### ក. ក្រមព្រហ្មទណ្ឌថ្មីបានពង្រីកវិសាលភាពគ្រប់ដណ្តប់លើបទបរិហាកេរ្តិ៍ ស្របពេលជាមួយនឹងមោឃភាពនៃការតស៊ូដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ

ខណៈដែល ច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ ("**ច្បាប់ស្តីពីរបបសារព័ត៌មាន**") បានចែងថា *"គ្មានជនណាម្នាក់ត្រូវចាប់ចង ឬដាប់ពន្ធនាគារ ដោយសារការបញ្ចេញមតិឡើយ"* [64] ជាអកុសល នៅពេលដែល **ក្រមព្រហ្មទណ្ឌថ្មី** ចូលជាធរមាននៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០ ជំនួសក្រមព្រហ្មទណ្ឌអ៊ុនតាក់ ក្រមថ្មីនេះនៅតែរក្សានូវស្ថានភាពព្រហ្មទណ្ឌចំពោះបទល្មើសបរិហារកេរ្តិ៍នៃមាត្រា ៣០៥។ មាត្រានេះកំណត់និយមន័យនៃបទបរិហារកេរ្តិ៍ដូចខាងក្រោម ៖ "បរិហារកេរ្តិ៍ មានន័យថាគ្រប់ការអះអាងបំផ្លើស ឬការទម្លាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិសព្ទនៃបុគ្គល ឬនៃស្ថាប័ន"។ ក្រមព្រហ្មទណ្ឌបានពង្រីកវិសាលភាពបទបរិហារកេរ្តិ៍ ដើម្បីឲ្យការបរិហារកេរ្តិ៍លើស្ថាប័នក៏ដូចជាបុគ្គល អាចមានលទ្ធផលជាបទចោទផ្នែកព្រហ្មទណ្ឌផងដែរ ចំណែកឯក្រមព្រហ្មទណ្ឌអ៊ុនតាក់ បានដាក់ត្រឹមតែ

[63] សូមមើលមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញ ៖ "ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភនាំឲ្យប៉ះពាល់ដល់ កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។"

[64] សូមមើលមាត្រា ២០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន។

មកលើបុគ្គលតែប៉ុណ្ណោះ។ មាត្រា ៣០៥ ក៏បានទម្លាក់កម្រិតអប្បបរមាដែលអាចបង្កើតបទបរិហាកេរ្តិ៍បានផងដែរ។ ក្រោមក្រមព្រហ្មទណ្ឌអ៊ុនតាក់ ការចោទប្រកាន់គឺត្រូវតែបានប៉ះពាល់ជាក់ស្តែងមកលើកេរ្តិ៍ឈ្មោះ ឬកិត្តិយស ខណៈដែលមាត្រា ៣០៥ បញ្ជាក់ថាដើម្បីអាចក្លាយជាបទចោទបានដោយគ្រាន់តែមានការប៉ុនប៉ងធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ ឬកិត្តិយស។[65] មាត្រា ៣០៦ ដែលចែងថា "ករណីបរិហារកេរ្តិ៍តាមរយៈសារព័ត៌មាន" នឹងស្ថិតក្រោមបញ្ញត្តច្បាប់ស្តីពីរបបសារព័ត៌មាន កម្រត្រូវបានយកមកប្រើខ្លាំងណាស់។

បន្ថែមពីលើមាត្រា ៣០៥ មាត្រាដទៃទៀតនៃក្រមព្រហ្មទណ្ឌបានបន្តរំលោភលើសេរីភាពខាងការបញ្ចេញមតិ រួមទាំង បទជេរប្រមាថជាសាធារណៈ (មាត្រា ៣០៧) បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣) និងបទប្រមាថ (មាត្រា ៥០២)។ មាត្រា ៥០២ បានចែងពីការឃុំខ្លួនបុគ្គលដែលមានវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃមន្ត្រីសាធារណៈ ឬ "ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត" ខណៈមាត្រា ៥២៣ បានចាត់ទុកជាបទល្មើសចំពោះការរិះគន់លើសេចក្តីសម្រេចរបស់តុលាការ ដែលបានលើកឡើងថាមានគោលដៅ "បង្កឲ្យមានភាពរំភើបរំជួលដល់សណ្តាប់ធ្នាប់សាធារណៈ" ឬ "បង្កឲ្យគ្រោះថ្នាក់ដល់ស្ថាប័ន" នៃកម្ពុជា។ បញ្ញត្តទាំងពីរមានការផ្ទុយគ្នាពីគោលការណ៍ដែលថាមន្ត្រីសាធារណៈ រួមទាំង ចៅក្រមនៃតុលាការ គួរតែជាកម្មវត្ថុស្របច្បាប់ ក្នុងការរិះគន់ និងប្រឆាំងផ្នែកនយោបាយ និងសម្របខ្លួនចំពោះការពិនិត្យពិច័យខ្ពស់ជាងបុគ្គលធម្មតា។ បញ្ញត្តទាំងនេះ គឺផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា និងមានផលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិក្នុងប្រទេស។ ការពិត បញ្ញត្តិទាំងនោះ អាចឈានទៅដល់ការដាក់ពន្ធនាគាររយៈពេលវែង និងដែលរដ្ឋាភិបាលកម្ពុជាបានបន្តប្រើប្រាស់ច្បាប់ទាំងនេះជាឧបករណ៍ក្នុងការបង្ក្រាបលើការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិរបស់អ្នកសារព័ត៌មាន អ្នកប្រឆាំងផ្នែកនយោបាយ អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនដទៃទៀត។[66]

ក្នុងអំឡុង ការត្រួតពិនិត្យជាសាកលតាមពេលវេលាកំណត់ ("យូភីអ") របស់អង្គការសហប្រជាជាតិ សម្រាប់ប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៤ រដ្ឋាភិបាលបានកត់សម្គាល់អនុសាសន៍ ដែលបានស្នើសុំដោយផ្ទាល់ដើម្បីលុបចោល ឬធ្វើវិសោធនកម្មលើមាត្រាទាំងនោះដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ។

ផ្ទុយទៅវិញ រដ្ឋាភិបាលទទួលយកនូវអនុសាសន៍ដែលជំរុញឲ្យកម្ពុជាបង្កើត **ច្បាប់ស្តីពីការទទួលបានព័ត៌មាន** ដែលជាធាតុផ្សំសំខាន់ក្នុងសេរីភាពបញ្ចេញគំនិត និងមតិយោបល់។ ជំហានដែលបានលើកឡើង ចំពោះការអនុម័តច្បាប់ និងគោលនយោបាយស្តីពីសិទ្ធិទទួលបានព័ត៌មាន គឺជាជំហានដ៏ប្រសើរមួយ ប៉ុន្តែ មិនសូវមានដំណើរការជាដុំកំភួនអ្វីនោះទេ មកដល់ពេលឥឡូវ។ ក្នុងខែមីនា ឆ្នាំ២០១១ ជាការឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការពីតួអង្គអន្តរជាតិក្នុងការទទួលបានព័ត៌មាន រដ្ឋាភិបាលបានបង្កើតអង្គភាពសារព័ត៌មាន និងប្រតិកម្មរហ័ស ដើម្បីផ្សាយព័ត៌មានបន្តទៅដល់អ្នកសារព័ត៌មាន ស្តីពីបញ្ហាដែលទាក់ទងនឹងសកម្មភាពយោធា ការទូត និងសន្តិសុខជាតិ។ ប៉ុន្តែ កម្ពុជាមិនទាន់បានអនុម័តច្បាប់

---

[65] ម.ស.ម.ក 'ការចាត់ទុកបទបរិហារកេរ្តិ៍ជាបទល្មើសព្រហ្មទណ្ឌ និងសេរីភាពបញ្ចេញមតិនៅកម្ពុជា' (ខែឧសភា ឆ្នាំ២០១៤), http://www.cchrcambodia.org/admin/media/analysis/analysis/english/2014_05_27_CCHR_Briefing_Note_Defamation_in_Cambodia_%28ENG%29.pdf.

[66] ម.ស.ម.ក 'ការគាបសង្កត់លើការបញ្ចេញមតិ ៖ ស្ថានភាពសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា' (ខែកញ្ញា ឆ្នាំ២០១៣), http://bit.ly/1lBgmal.

ស្តីពីការទទួលបានព័ត៌មាននៅឡើយទេ ហើយគោលការណ៍ការបើកចំហដោយអតិបរមាក៏មិនទាន់ត្រូវបានគោរពយ៉ាងពេញលេញនោះដែរ ទោះបីជាមានអ្នកនាំពាក្យរដ្ឋមន្ត្រីត្រូវបានតែងតាំងដើម្បីចែករំលែកព័ត៌មានក៏ដោយ។ កង្វះខាតការទទួលព័ត៌មានឲ្យបានគ្រប់គ្រាន់ និងមិនលម្អៀងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការបង្កើត និងចែកចាយគំនិតដោយសេរី។

សេរីភាពខាងការបញ្ចេញមតិប្រឈមមុខនឹងឧបសគ្គដ៏ធ្ងន់ធ្ងរមួយទៀតក្នុង **ច្បាប់ប្រឆាំងនឹងអំពើពុករលួយ** ឆ្នាំ ២០១០ ដែលខកខានក្នុងការផ្តល់ក្របខណ្ឌច្បាប់ ដើម្បីផ្តល់ការការពារផ្នែករូបរាងកាយ និងផ្នែកច្បាប់ទៅដល់បុគ្គលដែលជាអ្នកបើកកកាយអំពើពុករលួយ។ ការពិត ក្នុងមាត្រា ៤១ នៃច្បាប់នេះ ចែងថាការលេចធ្លាយព័ត៌មាន និងអំពើប្តឹងបរិហារដោយភូតកុហកនូវអង្គហេតុបទល្មើសពុករលួយ ត្រូវចាត់ទុកជាបទល្មើស។[67] ចំណុចនេះ មិនទាន់ច្បាស់ថាតើពាក្យបណ្តឹងដែលស្រាវជ្រាវមិនទាន់រកឃើញ ដែលមិនមែនជាការប្តឹងបរិហារដោយភូតកុហក នឹងត្រូវក្លាយជាបទល្មើសក្នុងច្បាប់នេះឬអត់នោះទេ។

បន្ថែមពីលើនោះ **ភាពសម្ងាត់ និងកង្វះតម្លាភាព** បន្តជាចរិតលក្ខណៈមួយក្នុងដំណើរការបង្កើតច្បាប់នៅកម្ពុជាដែលអាចមានផលវិបាកមកលើសេរីភាពខាងការបញ្ចេញមតិ។ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ អ្នកនាំពាក្យគណៈរដ្ឋមន្ត្រីលោក ផៃ ស៊ីផាន ត្រូវបានរាយការណ៍ថាបានលើកឡើងថា **សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យា** ដ៏ចម្រូងចម្រាស់ ត្រូវបាន "**ទុកចោល**" ដោយសារតែច្បាប់នេះ "មិនមែនជាអាទិភាព"។ កាលពីដំបូង ម.ស.ម.ក បានលើកយកក្តីព្រួយបារម្ភពាក់ព័ន្ធនឹងឥទ្ធិពលអវិជ្ជមាននៃច្បាប់នេះ ដែលអាចនឹងប៉ះពាល់ដល់សេរីភាពបញ្ចេញមតិ។ ថ្វីបើនៅមានកង្វះការទទួលព័ត៌មាន តែរដ្ឋាភិបាលក៏បានបង្ហាញពីគោលបំណងរបស់ខ្លួន ក្នុងការលើកយកនូវ **ច្បាប់ស្តីពីការសម្ងាត់របស់រដ្ឋ** ប៉ុន្តែមិនទាន់មានព័ត៌មានណាដែលទាក់ទងនឹងរឿងនេះនៅឡើយទេ។

## ខ. ការយាយីលើអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនសិទ្ធិដីធ្លី

### បញ្ហាទី ១៩ *[បន្ត]*

ក្នុងខែកុម្ភៈ ឆ្នាំ២០១២ បុគ្គលិកអង្គការ លោក **ស៊ុំ ចាន់គា** ត្រូវបានកោះហៅទៅសាកសួរពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទបរិហារបង្ខូចកេរ្តិ៍ ជាបទល្មើសដែលត្រូវដាក់ពន្ធនាគាររហូតដល់ ១ ឆ្នាំ និងត្រូវពិន័យរហូតដល់ ២ លានរៀល ក្នុងមាត្រា ៣១១ នៃក្រមព្រហ្មទណ្ឌ។ ការចោទប្រកាន់នេះ កើតឡើងដោយសារតែពាក្យបណ្តឹងរបស់បុគ្គលដែលមានអំណាច និងមានទំនាក់ទំនងល្អជាមួយសមាជិករដ្ឋាភិបាល លោក អ៊ុំ សុជាតិ ដែលជាប្រធានថ្នាក់ខេត្តនៃ មជ្ឈមណ្ឌលកំចាត់មីនខេត្ត។ លោក អ៊ុំ ជាតិ ត្រូវបានចោទប្រកាន់ពីបទបៀតបៀនកេរ្តិ៍ឈ្មោះ ដែលប្តឹងដោយអ្នករត់តុនៅភោជនីយដ្ឋាន ហើយដែលលោក ស៊ុំ ចាន់គា បានជួយផ្តល់ជំនួយដល់អ្នករត់តុ ក្នុងការដាក់ពាក្យប្តឹង។ ជាលទ្ធផល អ៊ុំ សុជាតិ បានដាក់ពាក្យបណ្តឹងតបមកលើ ស៊ុំ ចាន់គា។ ចុងក្រោយព្រះរាជអាជ្ញាបានទម្លាក់ករណីនេះនៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១២ ប៉ុន្តែតួអង្គសង្គមស៊ីវិល ក៏នៅតែត្រូវបានគំរាមកំហែងដោយដោយការប្រើប្រាស់តុលាការ។

[67] អានច្បាប់ប្រឆាំងអំពើពុករលួយ ៖ http://www.sithi.org/temp.php?url=law_detail.php&lg=&id=172.

មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ក៏តែងតែត្រូវបានប្រើដោយបំពាន ក្នុងការបំបិទសំឡេងអ្នកការពារសិទ្ធិមនុស្ស បុគ្គលិកអង្គការ និងបុគ្គល/ក្រុម ដែលហ៊ានបញ្ចេញមតិ។

ក្នុងខែតុលា ឆ្នាំ២០១២ លោក **អ៊ូ វីរៈ** អតីតប្រធានរបស់ ម.ស.ម.ក ត្រូវបានតុលាការខេត្តរតនៈគិរីកោះហៅទៅសាកសួរ ផ្អែកលើបទល្មើសដែលមិនពិត ពីបទញុះញង់ឲ្យសមាជិកក្រុមជនជាតិដើមភាគតិចធ្វើបាតុកម្មដោយហិង្សាប្រឆាំងនឹងការបណ្តេញចេញ។ ពាក្យបណ្តឹងនោះដាក់ថយក្រោយ ទៅពេលដែលសកម្មភាពបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សរបស់ ម.ស.ម.ក នៅតំបន់នោះ ក្នុងឆ្នាំ២០០៩។ បុគ្គលិកធ្វើការផ្នែកសិទ្ធិមនុស្សពីរនាក់ទៀត ក៏ត្រូវបានកោះហៅដោយសារបទល្មើសដូចគ្នានេះផងដែរ រួមទាំងអ្នកសារព័ត៌មានម្នាក់ដែលមានធ្វើការនៅក្នុងខេត្តរតនៈគិរី (នៅទិសឦសាននៃប្រទេសកម្ពុជា) ដែលបានរាយការណ៍ស្តីពីជម្លោះដីធ្លីនោះ គឺ លោក រដ្ឋា វិសាល។ ទោះបីជាមិនមានការចោទប្រកាន់នៅក្នុងករណីនេះក៏ដោយ ប៉ុន្តែការកោះហៅត្រូវបានប្រើប្រាស់ដើម្បីគំរាមកំហែងអ្នកធ្វើការសិទ្ធិមនុស្ស ដូច្នេះទើបធ្វើឲ្យក្លាយទៅជាការបង្អាក់ការប្រើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។

## គ. ការកើនឡើងនៃការចាប់ខ្លួន និងចោទប្រកាន់ពាក់ព័ន្ធនឹងបញ្ហានយោបាយ

*បញ្ហាទី ១៩* [*បន្ត*]

ថ្មីៗនេះ កាលពីខែវិច្ឆិកា ឆ្នាំ២០១៤ ឃើញមានការកើនឡើងជាច្រើន ក្នុង**ករណីការយាយីផ្នែកច្បាប់ និងការប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីជាឧបករណ៍ផ្នែកនយោបាយ**។ ចំនួននៃករណីចាប់ខ្លួន និងសវនាការយ៉ាងឆាប់រហ័សដែលទាក់ទងនឹងបញ្ហានយោបាយ បានបង្កឲ្យមានការព្រួយបារម្ភពីការប្រើប្រាស់តុលាការក្នុងការរារាំង នូវការអនុវត្តដោយស្របច្បាប់នូវសេរីភាពមូលដ្ឋាន ដែលធានាដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤ មានស្ត្រីចំនួន ៧ នាក់ មកពីសហគមន៍ **បឹងកក់** ត្រូវបានចាប់ខ្លួនខណៈដែលកំពុងតែធ្វើបាតុកម្មដោយសន្តិវិធី ទាមទារឲ្យអាជ្ញាធរចាត់វិធានការដោះស្រាយបញ្ហាទឹកជំនន់នៅក្នុងសហគមន៍របស់ពួកគេ។ តំបន់ដែលរងគ្រោះដោយទឹកលិចចាប់តាំងពីឆ្នាំ ២០០៨ នៅពេលដែលមានមនុស្សប្រហែលជា ២០.០០០ នាក់ត្រូវបណ្តេញចេញដោយបង្ខំ និងមានការចាក់ខ្សាច់បំពេញបឹងដោយក្រុមហ៊ុន ស៊ូកាគូ ដែលជាកម្មសិទ្ធិរបស់ព្រឹទ្ធសភានៃគណបក្សប្រជាជនកម្ពុជាម្នាក់។ សមាជិកសហគមន៍ទាំង ៧ នាក់ ត្រូវបានឃុំខ្លួនរយៈពេលមួយយប់ ហើយក្នុងរយៈពេល ៣៦ ម៉ោង អ្នកទាំងនោះត្រូវបានចោទប្រកាន់ពីបទប្រឆាំងមន្ត្រីរាជការសាធារណៈ កាត់សេចក្តី និងផ្តន្ទាទោស ដោយទទួលទោសអតិបរមាគឺរយៈពេល ១ ឆ្នាំ និងការពិន័យជាសាច់ប្រាក់ចំនួន ៥០០ ដុល្លារសហរដ្ឋអាមេរិក។[68] មានស្ត្រី ៣ នាក់ និងព្រះតេជគុណមួយអង្គបន្ថែមទៀត ត្រូវប្រឈមមនឹងហេតុការណ៍ដដែលនោះនៅថ្ងៃបន្ទាប់ ដោយត្រូវឃុំខ្លួនខណៈពេលធ្វើការប្រឆាំងតវ៉ាដោយសន្តិវិធី ទាមទារឲ្យមានការដោះលែងសកម្មជនដទៃទៀត ហើយក្រោយមកក៏ត្រូវបានផ្តន្ទាទោសពីបទប្រឆាំងមន្ត្រីរាជការសាធារណៈ។ ស្របពេលដែលមានការបន្ថយទោសតិចតួចដល់ចុងចោទ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១៥ សាលាឧទ្ធរណ៍បានតម្កល់ទោសរបស់ពួកគាត់ ដែលជាទោសសម្រេចដោយនីតិវិធីមិនត្រឹមត្រូវតាមស្តង់ដារសិទ្ធិ

[68] ម.ស.ម.ក 'សហគមន៍បឹងកក់រងការចាប់ខ្លួន ឃុំខ្លួន និងផ្តន្ទាទោសក្នុងរយៈពេល ៣៦ ម៉ោង' (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៤), http://bit.ly/15M7uOu.

ទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[69] ខណៈពេលដែលប្រព័ន្ធតុលាការបានបង្ហាញពីភាពងប់ងល់ ក្នុងការផ្តន្ទាទោសមកលើសកម្មជនសិទ្ធិដីធ្លី និងក្រុមបាតុករសន្តិវិធី មិនមានកិច្ចប្រឹងប្រែងណាត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាដីធ្លីដែលជាដើមចមនោះទេ។

ប៉ុន្មានថ្ងៃក្រោយ **មាច សុវណ្ណារ៉ា ទេព ណារិន អ៊ុក ពេជ្រសំណាង ស៊ុំ ពុទ្ធី** និងតែ **គីម** នៃ គ.ស.ជ ត្រូវបានចាប់ខ្លួនពាក់ព័ន្ធទៅនឹងអំពើហិង្សាក្នុងខែកក្កដា ឆ្នាំ២០១៤ នៅទីលានប្រជាធិបតេយ្យ នៅទីក្រុងភ្នំពេញ និងត្រូវបានចោទប្រកាន់ពីបទកុប្បកម្ម។ អ្នកទាំងនោះត្រូវបន្តដាក់ក្នុងពន្ធនាគារ ទោះបីជាមានការស្នើសុំឲ្យនៅក្រៅឃុំជាច្រើនលើកច្រើនសារហើយក៏ដោយ។ ក្រុមការងារ ម.ស.ម.ក បានចូលរួមសវនាការការស្នើសុំឲ្យនៅក្រៅឃុំ របស់អ្នកទាំង ៥ ខាងលើ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៤។ ក្នុងករណីរបស់ មាច សុវណ្ណារ៉ា ការស្នើសុំឲ្យនៅក្រៅឃុំត្រូវបដិសេធដោយផ្អែកលើមូលដ្ឋានថា ប្រសិនបើដោះលែងលោកនឹងត្រូវពាក់ព័ន្ធនឹងការធ្វើបាតុកម្ម និងគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ចំណែកឯការបដិសេធការស្នើសុំឲ្យនៅក្រៅឃុំរបស់ ទេព ណារិន និងអ្នកដទៃ គឺផ្អែកលើហេតុផលមិនច្បាស់លាស់ ដែលថាពួកគេអាចនឹងខកខានក្នុងការបង្ហាញខ្លួននៅតុលាការ ឬក៏បណ្តាលឲ្យមានចលាចលក្នុងសង្គម។ បុគ្គលទាំង ៥ នាក់ទៀតត្រូវបានបដិសេធមិនឲ្យនៅក្រៅឃុំដោយសារហេតុផលដូចគ្នា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥។ តាមការកត់សម្គាល់របស់ អ្នករាយការណ៍ពិសេសក្នុងរបាយការណ៍ថ្មីៗ [70] រយៈពេលនៃការចាប់ខ្លួន គឺចំពេលការចរចាស្តីពីកំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបង្ហាញថាអាចនឹងមានហេតុផលនយោបាយនៅពីក្រោយ។ អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័ក្ត្រ ក៏បានរាយការណ៍ថាបាននិយាយទៅកាន់អ្នកសារព័ត៌មានថា មាច សុវណ្ណារ៉ា អាចប្រឈមនឹងការដាក់ពន្ធនាគាររយៈពេលខ្លីជាងនេះ ប្រសិនបើ គ.ស.ជ សហការណ៍ឲ្យបានច្រើនជាងនោះលើបញ្ហាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញដោយបើកចំហថាមានហេតុផលនយោបាយនៅពីក្រោយការចាប់ខ្លួននេះ។[71]

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ប្រព័ន្ធតុលាការ និងអំណាចនីតិប្រតិបត្តិឈប់ប្រើប្រព័ន្ធតុលាការដើម្បីយាយីលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយគណបក្សប្រឆាំង និងដោះលែងឲ្យបានឆាប់ និងគ្មានលក្ខខណ្ឌចំពោះអ្នកដែលកំពុងត្រូវបានឃុំខ្លួនដោយសារតែបទចោទ ឬការផ្តន្ទាទោសពាក់ព័ន្ធនឹងរឿងនយោបាយ ដែលមិនមានមូលដ្ឋានក្នុងច្បាប់ និងមិនមាននៅក្នុងលទ្ធិប្រជាធិបតេយ្យសេរីនោះទេ*
- *អនុវត្តអនុសាសន៍ យូភីអ ដើម្បីធ្វើវិសោធនកម្មលើក្រមព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យស្របជាមួយនឹងបទដ្ឋានអន្តរជាតិ និងកាតព្វកិច្ចរបស់កម្ពុជា ក្នុង ក.អ.ស.ព.ន រួមទាំងបញ្ជាក់ពីពាក្យពេចន៍មិនច្បាស់លាស់ និងដកបទបរិហារកេរ្តិ៍ចេញពី*

---

[69] សេចក្តីថ្លែងការណ៍រួម របស់អង្គការសង្គមស៊ីវិល 'ក្រុមអង្គការសង្គមស៊ីវិល ថ្កោលទោសការឃុំខ្លួនបន្ត របស់សកម្មជនទាំង ១១ នាក់' (ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥), http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=533&id=5&lang=eng

[70] សេចក្តីថ្លែងការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សូរិយា ភី. ស៊ូបេឌី 'ការយាយីផ្អែកតុលាការដោយសារគោលបំណងនយោបាយគួរតែបញ្ឈប់' (ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤),
http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=15303&LangID=E#sthash.ddN96hv9.dpuf*Special*

[71] ឆាយ ច័ន្ទនីដា និង មាស សុខជា 'ការចាប់ខ្លួន គ.ស.ជ នៅតែបន្ត', សារព័ត៌មានភ្នំពេញប៉ុស្តិ៍, ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤,
http://www.phnompenhpost.com/national/cnrp-arrests-continue

*បទល្មើសព្រហ្មទណ្ឌ ក្នុងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ "បទប្រមាថ" ក្នុងមាត្រា ៥០២ និង "បទធ្វើឲ្យបាត់ជំនឿចិត្តលើសេចក្តីសម្រេចរបស់តុលាការ" ក្នុងមាត្រា ៥២៣*

- *ទប់ស្កាត់ការអនុម័តច្បាប់ស្តីពីឧក្រិដ្ឋកម្មលើប្រព័ន្ធបច្ចេកវិទ្យាដូចបានបង្ហាញខាងលើ និងពិចារណាលើច្បាប់ការសម្ងាត់របស់រដ្ឋរហូតទាល់តែមានកិច្ចពិគ្រោះយោបល់ប្រកបដោយតម្លាភាព ជាមួយសង្គមស៊ីវិល ព្រមទាំង និងធានាថាសេចក្តីព្រាងនេះនឹងស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ជាពិសេស ទាក់ទងនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ*
- *ចូលរួមជាអាទិភាពក្នុងដំណើរការអនុម័តច្បាប់ដ៏មានតម្លាភាព ដើម្បីអនុម័តច្បាប់ស្តីពីការទទួលបានព័ត៌មានដែលច្បាស់លាស់ ជាក់លាក់ និងធានាសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលបានព័ត៌មាន*
- *ទប់ស្កាត់ពីការអនុវត្តក្រមព្រហ្មទណ្ឌដោយមិនស្របច្បាប់ក្នុងករណីបរិហារកេរ្តិ៍ទាក់ទងនឹងអ្នកសារព័ត៌មាន ប៉ុន្តែអនុវត្តបញ្ញត្តនៃច្បាប់ស្តីពីរបបសារព័ត៌មានដែលពាក់ព័ន្ធជំនួសវិញ*
- *អញ្ជើញអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការបញ្ចេញគំនិត និងមតិមកធ្វើទស្សនកិច្ចនៅក្នុងប្រទេស*
- *ទប់ស្កាត់ការប៉ុនប៉ងបំបិទការមិនយល់ព្រមផ្នែកនយោបាយ និងការរិះគន់ ដោយប្រើប្រព័ន្ធយុត្តិធម៌*

## ឃ. ការបដិសេធនូវសិទ្ធិប្រមូលផ្តុំដោយសន្តិវិធី

*បញ្ហាទី ២០. យោងតាមព័ត៌មានដែលផ្តល់ដោយកថាខណ្ឌ ១៧៥ ដល់ ១៩៩ នៃរបាយការណ៍ភាគីរដ្ឋ សូមផ្តល់ព័ត៌មានបន្ថែមស្តីពីការរឹតត្បិតផ្នែកច្បាប់ និង/ឬផ្នែករដ្ឋបាល ដែលបានដាក់មកលើសិទ្ធិជួបប្រជុំដោយសន្តិវិធី រួមបញ្ចូលទាំងលក្ខខណ្ឌក្នុងការហាមឃាត់ ការប្រមូលផ្តុំ ក៏ដូចជាករណីផ្សេងៗដែលត្រូវបានចងក្រងក្នុងអំឡុងពេលរបាយការណ៍ ដែលការប្រមូលផ្តុំត្រូវបានហាមឃាត់ និងហេតុផលដែលហាមឃាត់។ ពាក់ព័ន្ធនឹងព័ត៌មាននៅក្នុងកថាខណ្ឌ ១៦៧ នៃរបាយការណ៍របស់ភាគីរដ្ឋ សូមផ្តល់ព័ត៌មានបន្ថែមស្តីពីវិធានគ្រប់គ្រងនៃការប្រើប្រាស់ "ទីលានប្រជាធិបតេយ្យ"។ សូមផ្តល់យោបល់ស្តីពីរបាយការណ៍ដែលបញ្ជាក់ថាមានការបិទផ្លូវដើម្បីរារាំងមិនឲ្យចូលទៅកាន់ទីលានប្រជាធិបតេយ្យនៅភ្នំពេញ។ សូមបញ្ជាក់ពីស្ថានភាពផ្លូវច្បាប់ របស់សន្តិសុខខណ្ឌ និងតួនាទីរបស់ពួកគេក្នុងការឃ្លាំមើលបាតុកម្ម។ សូមផ្តល់យោបល់លើរបាយការណ៍ដែលបង្ហាញពីការឃុំខ្លួនបាតុករអហិង្សា រហូតទាល់តែពួកគេចុះហត្ថលេខា ឬផ្តិតមេដៃលើឯកសារដែលយល់ព្រមថានឹងមិនចូលរួមបាតុកម្មនាពេលខាងមុខទៀតនោះទេ។*

នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ បន្ទាប់ពីមានការបង្ក្រាបដោយហិង្សាមកលើក្រុមបាតុករ ក្រសួងមហាផ្ទៃ ត្រូវបានរាយការណ៍ថាហាមឃាត់ការធ្វើបាតុកម្ម ការប្រមូលផ្តុំ ឬការដង្ហែក្បួនផ្សេងទៀតរហូតដល់ "សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខត្រូវបានស្តារមកកាន់សភាពដើមវិញ" បញ្ជាក់ដោយឧត្តមសេនីយ៍ ខេង ទីតូ អ្នកនាំពាក្យមន្ត្រីនគរបាលជាតិ ដែលចង់មានន័យថារហូតទាល់តែ គ.ស.ជ បញ្ចប់ការធ្វើពហិការចូលរួមក្នុងរដ្ឋសភា និងទទួលយកអាសនៈរបស់ខ្លួន។[72]

---

[72] កំណត់ត្រាសង្ខេប ម.ស.ម.ក 'កម្ពុជា ៖ សេរីភាពនៃការជួបប្រជុំត្រូវបាន "ព្យួរ",' (ឆ្នាំ២០១៤: http://sithi.org/CCHR_Briefing_Note-Freedom_of_Assembly_on_hold_ENG.pdf.

បន្ថែមពីលើនោះ នៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ សាលាខេត្តកំពង់ឆ្នាំង ចេញសារាចរណ៍ ស្តីពីការប្រមូលផ្តុំសាធារណៈ ទៅកាន់គណបក្សនយោបាយ សហជីពកម្មករ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមដទៃទៀត។ សារាចរណ៍នេះបានណែនាំថាដើម្បីអាចរៀបចំការប្រមូលផ្តុំជាសាធារណៈបាន អ្នករៀបចំត្រូវតែស្នើសុំការអនុញ្ញាតពីអាជ្ញាធរខេត្តក្នុងរយៈពេល ៧ ថ្ងៃមុន ដើម្បីអនុញ្ញាតឲ្យពួកគេកំណត់មើលថាតើបាតុកម្មនេះ "ស្របច្បាប់" ឬក៏អត់។ ប្រសិនបើមិនសុំការអនុញ្ញាតទេនោះ "*អាជ្ញាធរមានសមត្ថកិច្ចនឹងចាត់វិធានការម៉ត់ចត់ទៅលើការធ្វើបាតុកម្មនេះ ហើយអ្នករៀបចំនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន*" ។ [73] ចំណុចនេះគឺផ្ទុយទាំងស្រុងទៅនឹងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ ២០០៩ ដែលតម្រូវឲ្យបាតុករចូនដំណឹងតែប៉ុណ្ណោះ។[74]

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដូចជាបាននិយាយលុបចោលការហាមឃាត់លើការប្រមូលផ្តុំក្នុងសុន្ទរកថានៅខេត្តព្រះសីហនុ លោកប្រកាសថា "*ឥឡូវខ្ញុំមិនបានស្នើសុំធ្វើបាតុកម្មនោះទេ ប៉ុន្តែខ្ញុំក៏នឹងមិនប្រឆាំងនឹងការរៀបចំដែរ*" លោកបានបន្ថែមថា "*គួរតែជានាសន្តិភាពសម្រាប់អ្នករាល់គ្នា ក៏ដូចជា ជានាសេរីភាពក្នុងការប្រមូលផ្តុំផងដែរ*"។[75] សេចក្តីប្រកាសនោះបានបណ្តាលឲ្យមានការភ័ន្តច្រលំជាច្រើន ថាតើការហាមឃាត់នោះត្រូវបានលុបចោលដែរឬទេ សូម្បីតែក្នុងចំណោមមន្ត្រីរដ្ឋាភិបាលក៏ដោយ។ ប៉ុន្តែ ការធ្វើបាតុកម្មផ្សេងទៀតក៏ត្រូវបានហាមឃាត់ផងដែរ ដែលនេះបញ្ជាក់ថាការអនុវត្តការហាមឃាត់គឺនៅតែមានសុពលភាព។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ បន្ទាប់ពីសុន្ទរកថារបស់ លោក ហ៊ុន សែន អាជ្ញាធរបានប្រកាសថាទីលានប្រជាធិបតេយ្យនៅតែបិទសម្រាប់ក្រុមបាតុករទាំងអស់ ដោយគ្មានកាលកំណត់។[76] ក្រោយមក សាលាក្រុងភ្នំពេញក៏បានបដិសេធសំណើមួយចំនួនក្នុងការរៀបចំការប្រមូលផ្តុំក្នុងទីលានប្រជាធិបតេយ្យ ពីសំណាក់សហជីពកម្មករ និងសមាគមផ្សេងទៀត ក៏ដូចជា ម្ចាស់ស្ថានីយវិទ្យុ លោក ម៉ម សូណង់ដូផងដែរ។[77]

នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ សាលារាជធានីភ្នំពេញ ក៏បានបដិសេធម្តងទៀតចំពោះបាតុកម្មដែលគ្រោងនឹងរៀបចំឡើងដោយ លោក ម៉ម សូណង់ដូ ដោយលើកឡើងពីតម្រូវការក្នុងការស្តារនូវសណ្តាប់ធ្នាប់សាធារណៈ។ លោក សូណង់ដូ ដែលជារឿយៗ ស្នើសុំការអនុញ្ញាតដើម្បីធ្វើបាតុកម្មប្រឆាំងនឹងសេចក្តីសម្រេចរបស់ក្រសួងព័ត៌មាន ដែលបដិសេធក្នុងការផ្តល់អាជ្ញាប័ណ្ណពង្រីកកម្លាំងផ្សាយឲ្យបានទូលាយជាងមុន និងអាជ្ញាប័ណ្ណទូរទស្សន៍។ ប៉ុន្តែ លោកមិនដែលទទួលបានកាលបរិច្ឆេទផ្សេងទៀតនោះទេ ពេលដែលលោកស្នើសុំ។ អ្នកនាំពាក្យ លោក ឡុង ឌីម៉ង់ ប្រកាសថាការធ្វើបាតុកម្មនឹង

[73] ក្រសួងមហាផ្ទៃ សារាចរណ៍ស្តីពីការធ្វើបាតុកម្ម នៅខេត្តកំពង់ឆ្នាំសម្រាប់គណបក្សប្រឆាំង សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងសមាគមដទៃទៀតដែលមានទីតាំងនៅខេត្តកំពង់ឆ្នាំ (ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤).

[74] ម.ស.ម.ក 'លិខិតចំហរបស់ ម.ស.ម.ក ស្តីពីការអនុវត្តច្បាប់មកលើបាតុកម្មដោយសន្តិវិធី' (ឆ្នាំ២០១៤): http://cchrcambodia.org/media/files/press_release/510_201coltmoidl%28_en.pdf.

[75] ឃើ សុខវុទ្ធី និងខូលីន ម៉េយ៍ 'ហ៊ុន សែន ប្រឆាំងនឹងការហាមឃាត់ ព្រមានថាអាចនឹងមានបាតុកម្មគាំទ្រ ប្រ.ជ' *សារព័ត៌មាន ឌឹ ខេមបូឌា ដេលី* (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ ២០១៤ ): http://bit.ly/1heCg46.

[76] មុំ គន្ធា 'ទីលានប្រជាធិបតេយ្យ នៅតែមិនអាចប្រើប្រាស់បាន' *សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍* (ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤): http://bit.ly/1cEkgk2.

[77] គុជ ណារ៉ែន និងមាច ដារ៉ា 'កាន់តែធ្ងន់ធ្ងរឡើងសម្រាប់ការហាមឃាត់ក្នុងការធ្វើបាតុកម្ម' *សារព័ត៌មាន ខេមបូឌា ដេលី* (ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៤): http://bit.ly/OPGJjI.

មិនអាចធ្វើឡើងបានទេហូតទាល់តែ "*ស្ថានភាព និងសណ្ដាប់ធ្នាប់សាធារណៈត្រលប់មករកសភាពដើមទាំងស្រុង*" និងហូតទាល់តែការស៊ើបអង្កេតលើការសម្លាប់កម្មកររោងចក្រ ដែលកើតឡើងក្នុងដើមខែមករា ត្រូវបានបញ្ចប់។[78]

## ង. ការគំរាមកំហែង និងការឃុំខ្លួនតាមទំនើងចិត្ត ដើម្បីមិនឲ្យអ្នកការពារសិទ្ធិមនុស្សធ្វើបាតុកម្ម

*បញ្ហាទី ២០ [បន្ត]*

ការគំរាមកំហែង និងអំពើហិង្សា ក៏ត្រូវរាយការណ៍ថាបានប្រើដើម្បីរាំងការធ្វើបាតុកម្មផងដែរ។ ឧទាហរណ៍ ក្នុងកិច្ចប្រជុំមួយរវាងគណបក្សប្រឆាំង គ.ស.ជ នៅឃុំត្រើយស្លា ខេត្តកណ្ដាល ត្រូវបានលុបចោល នៅថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៤ បន្ទាប់ពីមានអ្នកគាំទ្រ គណបក្សប្រជាជនកម្ពុជា (ប្រ.ជ) ប្រហែលជាពីរបីរយនាក់ និងមន្ត្រីយោធា និងមន្ត្រីបង្ក្រាបកុប្បកម្ម បំពាក់ទៅដោយឧស្ម័នបង្ហូរទឹកភ្នែក ខែល និងដំបង បានបង្ហាញខ្លួននៅកន្លែងប្រជុំ។ កិច្ចប្រជុំនោះត្រូវបានពន្យារ មុនពេលការមកដល់របស់ថ្នាក់ដឹកនាំគ.ស.ជ បន្តិច ត្រូវបានរាយការណ៍ថាដើម្បីបញ្ចៀសហិង្សា ដោយសារតែមានវត្តមានរបស់កងកម្លាំងសន្តិសុខជាច្រើននាក់។[79] គ.ស.ជ បានទទួលការអនុញ្ញាតឲ្យមានកិច្ចប្រជុំនេះពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លោក ស ខេង កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្ដែង វត្តមានរបស់កងកម្លាំងសន្តិសុខ និងអ្នកគាំទ្ររបស់ ប្រ.ជ ជាការផ្ដល់សារក្នុងគោលបំណងរឹតត្បិតសិទ្ធិរបស់គណបក្សប្រឆាំងក្នុងការជួបប្រជុំដោយសន្តិវិធី។ បច្ចេកទេសស្រដៀងគ្នានេះ ត្រូវបានប្រើដើម្បីរាំងកិច្ចប្រជុំរបស់លោក កឹម សុខា ដែលជាអនុប្រធានគណបក្ស គ.ស.ជ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤ នៅខេត្តកំពង់ចាម។ [80]

នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ កងកម្លាំងសន្តិសុខបានចាប់ខ្លួន និងឃុំខ្លួនអ្នកការពារសិទ្ធិមនុស្សចំនួន ១១ នាក់ ក្នុងរយៈពេល ២ ទៅ ៣ ម៉ោងនៅប៉ុស្ដិ៍នគរបាលក្រុងភ្នំពេញ។ អ្នកទាំង ១១ នាក់ មានគោលបំណងក្នុងការដាក់ញត្តិទៅកាន់ស្ថានទូតបរទេស រួមទាំង ស្ថានទូតសហរដ្ឋអាមេរិក និងបារាំង អំពាវនាវឲ្យមានការដោះលែង បាតុករ ២៣ នាក់ ដែលអាជ្ញាធរបានចាប់ខ្លួន ក្នុងបាតុកម្មរបស់កម្មកររោងចក្រ នៅថ្ងៃទី២-៣ ខែមករា។ ខណៈដែលមានភាពមិនច្បាស់លាស់ស្ដីពីមូលហេតុនៃការឃុំខ្លួនអ្នកទាំង ១១ នាក់ ប៉ុន្តែមានការជឿជាក់យ៉ាងច្បាស់ថាពួកគេត្រូវឃុំខ្លួនដោយសារតែរំលោភលើការហាមឃាត់ដោយផ្ទាល់មាត់ លើការប្រមូលផ្ដុំជាសាធារណៈ ដែលមានអ្នកចូលរួមលើសពី ១០ នាក់ ដែលក្រសួងមហាផ្ទៃបានចេញកាលពីថ្ងៃទី ៤ ខែមករា។ អ្នកដែលបានចាប់ខ្លួន នៅថ្ងៃទី២១ ខែមករា មានដូចជា ៖ សមាជិកអ្នកការពារសិទ្ធិមនុស្សមកពីសហគមន៍បឹងកក់ ទេព វន្នី, យោម បុប្ផា, សុង ស្រីលាភ, ផាន់ ឈុនរ៉េត, អ៊ឹម ស្រីទូច, ប៉ូវ សោភា និង ង៉ួន គឹមឡាង ប្រធាន សមាគមគ្រូបង្រៀនឯករាជ្យកម្ពុជា លោក រ៉ុង ឈុន សមាជិកសម្ព័ន្ធសហជីពកម្ពុជា អ្នកស្រី ឈាង ជីតា សមាជិកនៃក្រុមការងារពិសេសសិទ្ធិលំនៅឋាន កញ្ញា ឡុង គឹមហ៊ាង និងសកម្មជនសិទ្ធិដីធ្លី អ្នកស្រី ដួង

---

[78] គុជ ណារ៉ែន 'សាលាក្រុងប្រកាសបដិសេធ គម្រោងធ្វើបាតុកម្មរបស់ លោក ម៉ម សូណង់ដូ' *សារព័ត៌មាន ខេមបូឌា ដេលី,* (ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤): http://bit.ly/1gww7ln

[79] ផាន់ អាណា និង អូន ភាព 'គ.ស.ជ ផ្អាកការប្រជុំដោយសារតែអ្នកគាំទ្រ ប្រ.ជ បង្ហាញខ្លួនជាច្រើននាក់' *សារព័ត៌មាន ខេមបូឌា ដេលី,* (ថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៤): http://bit.ly/1m3dvc7

[80] ម៉ៃ ទិត្យថារ៉ា និងស្ទួត វ៉ាយ៍ 'គ្មានការជជែកគ្នាថ្ងៃទីពេលមានហិង្សានោះទេ ៖ សុខា' *សារព័ត៌មាន ភ្នំពេញ ប៉ុស្ដិ៍* (ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤): http://bit.ly/1mrsK1n

សុភាព។ អ្នកទាំង ១១ នាក់ ត្រូវបានដោះលែងវិញ ក្នុងល្ងាចថ្ងៃដដែល បន្ទាប់ពីពួកគេត្រូវបានបង្ខំឲ្យចុះហត្ថលេខាលើកិច្ចសន្យាប្ដេជ្ញាមិនចូលរួម ដឹកនាំ ឬញុះញង់សកម្មភាព "ខុសច្បាប់" ឬក៏ធ្វើបាតុកម្មនាពេលអនាគតនោះទេ។[81]

ពីរថ្ងៃក្រោយ លោក សុខ ឈុនអឿង ប្រធានស្ដីទី សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ត្រូវបានចាប់ខ្លួនខណៈដែលប៉ុនប៉ងរៀបចំពិធីសម្រាប់អ្នកទាំង ២៣ នាក់ ដែលត្រូវបានឃុំខ្លួនតាំងពីការប៉ះទង្គិចដោយហិង្សា នៅថ្ងៃទី២ និង ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤។ លោកត្រូវបានឃាត់ខ្លួនអស់ពេលមួយយប់នៅស្ថានីយនគរបាលក្រុងភ្នំពេញ និងដោះលែងមកវិញប្រហែលជាម៉ោង ១០ ព្រឹក នៅព្រឹកថ្ងៃបន្ទាប់ បន្ទាប់ពីការចុះហត្ថលេខាលើលិខិតស្រដៀងគ្នាដែរនោះ។[82]

នេះមិនមែនជាលើកដំបូង ដែលរដ្ឋាភិបាលតម្រូវឲ្យអ្នកការពារសិទ្ធិមនុស្សចុះហត្ថលេខាលើកិច្ចសន្យាដើម្បីដោះដូរសិទ្ធិក្នុងការធ្វើបាតុកម្មនាពេលអនាគតដើម្បីអាចរួចខ្លួន។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១១ សមាជិកសហគមន៍បឹងកក់ចំនួន ១១ នាក់ ត្រូវបានចាប់ខ្លួនក្នុងការធ្វើបាតុកម្មដោយសន្តិវិធី ប្រឆាំងនឹងការបំផ្លាញផ្ទះសម្បែងរបស់ពួកគេ។ យោងតាមស្នងការនគរបាលក្រុងភ្នំពេញ លោក ទូច ណារ៉ុថ "អ្នកភូមិដែលត្រូវបានចាប់ខ្លួន ត្រូវបានប្រាប់ឲ្យចុះហត្ថលេខាលើកិច្ចសន្យាដើម្បីសន្យាថានឹងឈប់ធ្វើបាតុកម្ម ដែលបណ្ដាលឲ្យមានចលាចលសាធារណៈ និងឈប់ប្រើប្រាស់អំពើហិង្សា និងឈ្លោះជាមួយមន្ត្រីនគរបាល"។[83]

បន្ថែមពីលើនោះ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ វ៉ុង បញ្ញា ដែលជាតំណាងឲ្យសហព័ន្ធសហជីពកម្ពុជា បានចូលរួមក្នុងបាតុកម្ម ដែលមានកម្មករប្រមាណជា ៥០០ នាក់ មកពី រោងចក្រ *តៃណាន* នៅទីលានប្រជាធិបតេយ្យ ក្នុងទីក្រុងភ្នំពេញ។ កម្មករទាំងនោះប្រមូលផ្ដុំគ្នាដើម្បីដាក់ញត្តិ រៀបរាប់តម្រូវការរបស់ពួកគេ រួមមាន ការដំឡើងប្រាក់សំណងទៅកាន់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។ បាតុកម្មនោះបានប្រែក្លាយទៅជាហិង្សា បន្ទាប់ពីការមកដល់របស់នគរបាលបង្ក្រាបកុប្បកម្ម ដែលបណ្ដាលឲ្យលោក វ៉ុង បញ្ញា ត្រូវបានវាយដំដោយដំបង និងនាំខ្លួនទៅកាន់អគ្គស្នងការដ្ឋាននគរបាលជាតិ។[84] លោក បញ្ញា ត្រូវបានដោះលែងបន្ទាប់ពីផ្ដិតមេដៃលើឯកសារដែលបញ្ជាក់ថាលោកជាអ្នកបង្កជម្លោះដែលកើតឡើងនៅឯកន្លែងបាតុកម្ម និងមិនចូលរួមក្នុងសកម្មភាពផ្សេងទៀត ដូចជា បាតុកម្មនោះទេ។[85]

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ **សមាជិកសហជីព និងអ្នកដឹកនាំសហជីពចំនួន ៨ នាក់** មកពីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ត្រូវបានចាប់ខ្លួនក្នុងស្រុកបាទី ខេត្តតាកែវ ក្នុងអំឡុងពេលបាតុកម្មរបស់កម្មកររោងចក្រ នៅឯរោងចក្រ ដេអេសឌី តិចស្ដាយ ខូអិលធីឌី។ បាតុកម្មនេះត្រូវបានធ្វើឡើងដើម្បីអំពាវនាវឲ្យលក្ខខណ្ឌការងារបានប្រសើរ។ យោងតាម ការតាមដានរបស់ ម.ស.ម.ក អ្នកទាំង ៨ នាក់ត្រូវបានឃុំខ្លួនចំនួន ៤៨ ម៉ោង និងសាកសួរពាក់ព័ន្ធនឹងការចោទប្រកាន់ ស្ដីពីការញុះញង់ឲ្យមានបទល្មើស គំរាមកំហែងក្នុងការបំផ្លិចបំផ្លាញ ធ្វើឲ្យបាត់បង់ជំនឿចិត្តលើប្រព័ន្ធ

---

[81] ម.ស.ម.ក, អែហ្វ អាយ ឌី អេច, អូ អឹម ស៊ី ធី, លីកាដូ 'កម្ពុជា ៖ការយាយី ចាប់ខ្លួន និងឃុំខ្លួនរបស់អ្នកការពារសិទ្ធិមនុស្សនៅតែបន្ត' (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៤) https://www.fidh.org/International-Federation-for-Human-Rights/asia/cambodia/14511-cambodia-harassment-arrest-and-detention-of-human-rights-defenders

[82] យុត សុភ័ក្រ្តចរិយា និងស៊ិន ធីហាន់ 'អ្នកដឹកនាំសហជីពត្រូវបានដោះលែង' *សារព័ត៌មានភ្នំពេញ ប៉ុស្ដិ៍* (ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤): http://bit.ly/1coBosf.

[83] យុថ្ងៃទីត សុភ័ក្រ្តចរិយា 'ការធ្វើបាតុកម្មនៅបឹងកក់ក្លាយជាហិង្សា' (ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១): http://bit.ly/LiMLrd.

[84] ម.ស.ម.ក 'ហិង្សាឆ្លើយតបទៅនឹងបាតុកម្មរបស់កម្មករ' (ខែកក្កដា ឆ្នាំ២០១២) http://bit.ly/1dKrA7u.

[85] សែន ដាវីត 'តំណាងសហជីព 'ត្រូវបានបង្ខំ' ឲ្យសារភាព' *សារព័ត៌មាន ភ្នំពេញ ប៉ុស្ដិ៍* (ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២): http://bit.ly/1e40MoS.

តុលាការ និងជាអ្នកញុះញង់។ ពួកគេត្រូវបានដោះលែងឲ្យនៅក្រៅឃុំ នៅថ្ងៃទី២៥ ខែឧសភា បន្ទាប់ពីប្រធាន សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះហត្ថលេខាលើលិខិតធានាថាអ្នកទាំង ៨ នាក់ នឹងមិនបង្កបញ្ហានៅរោងចក្រ ព្រមទាំងនឹងបង្ហាញខ្លួននៅពេលដែលមានការស្នើសុំពីព្រះរាជអាជ្ញា។ ពួកគេទាំងអស់កំពុងតែស្ថិតក្រោមការឃ្លាំមើលរបស់តុលាការ (មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដោយសារតែការអនុវត្តសិទ្ធិធ្វើបាតុកម្មរបស់ពួកគេ។

ការអនុវត្តបែបនេះ ជះឥទ្ធិពលអវិជ្ជមានទៅលើការងារអ្នកការពារសិទ្ធិមនុស្ស ដោយសារថាបានរឹតត្បិតសមត្ថភាពរបស់ពួកគេក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងថែមទាំងបង្ហាញពីការគំរាមកំហែងដ៏ធ្ងន់ធ្ងរដែលថាពួកគេអាចនឹងត្រូវបានចាប់ខ្លួនគ្រប់ពេលវេលា។ មាត្រា ៥ នៃសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស[86] ទទួលស្គាល់សិទ្ធិជួបប្រជុំដោយសន្តិវិធីរបស់ខ្លួន និងអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស បានពិចារណាសិទ្ធិជួបប្រជុំដោយសន្តិវិធី ថាសំខាន់សម្រាប់អ្នកការពារសិទ្ធិមនុស្សធ្វើការនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់សាកលក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ ប្រសិនបើមិនមានសិទ្ធិទាំងអស់នេះទេ អ្នកការពារសិទ្ធិមនុស្សនឹងត្រូវរឹតត្បិតសមត្ថភាពរបស់ពួកគេក្នុងការបំពេញតួនាទីសំខាន់ដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។[87]

បន្ថែមពីលើនោះ ការអនុវត្តបែបនេះបង្ហាញពីគំរាមកំហែងជាបន្តបន្ទាប់ ក្នុងការចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស។ ដូចកត់សម្គាល់ដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស *"នេះជារឿងសាមញ្ញដែលអាជ្ញាធររដ្ឋខ្លះ បានជំរុញទាំងបំពានឲ្យអ្នកការពារសិទ្ធិមនុស្សត្រូវរង "កំហុស" ផ្នែករដ្ឋបាល និងដើម្បីប្រើចំណុចនេះជាមូលដ្ឋានក្នុងការចាប់ខ្លួន ឃុំខ្លួន និងផ្តន្ទាទោស។"*[88]

ការគំរាមកំហែងចាប់ខ្លួនជាអចិន្ត្រៃយ៍គឺផ្ទុយនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ស្តីពីការការពារសិទ្ធិមនុស្សក្នុងបរិបទនៃសិទ្ធិក្នុងការធ្វើបាតុកម្មដែលបានចែងថា ៖*"មនុស្សគ្រប់រូបគួរតែអាចបង្ហាញពីភាពអយុត្តិធម៌ ឬរបស់ពួកគេ ឬបំណងប្រាថ្នារបស់ពួកគេដោយសន្តិវិធី រួមទាំងតាមរយៈការធ្វើបាតុកម្មជាសាធារណៈ ដោយគ្មានភាពភ័យខ្លាចថានឹងត្រូវរងរបួស វាយដំ និងចាប់ខ្លួនតាមទំនើងចិត្ត និងឃុំខ្លួន ធ្វើទារុណកម្ម សម្លាប់ ឬក៏ជាគោលដៅនៃការបាត់ខ្លួនដោយបង្ខំនោះទេ"។*[89] បន្ថែមពីលើនោះ ប្រសិនបើមានការចាប់ខ្លួននាពេលអនាគតទៀត ដោយផ្អែកលើឯកសារទាំងនោះតែម្យ៉ាង គួរតែត្រូវបានពិចារណាថាជាការឃុំខ្លួនដោយខុសច្បាប់ និងតាមទំនើងចិត្ត។[90]

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

---

[86] សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ 53/144, សេចក្តីប្រកាសស្តីពីសិទ្ធិ និងទំនួលខុសត្រូវរបស់បុគ្គល ក្រុម និងស្ថាប័នក្នុងសង្គមដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានដែលទទួលស្គាល់ជាសាកល, (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៨): http://bit.ly/1fbj99p.

[87] មហាសន្និបាត អង្គការសហប្រជាជាតិ, របាយការណ៍របស់អ្នករាយការណ៍ពិសេស នៃអគ្គលេខាធិការស្តីពីអ្នកការពារសិទ្ធិមនុស្ស, ឯកសាររបស់ អ.ស.ប A/61/312 (ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៦), កថាខណ្ឌទី ៧៦ និងសេចក្តីផ្តើម: http://bit.ly/1fbiAN0.

[88] ឧ.ស.អ.ស.ប.ស 'អ្នកការពារសិទ្ធិមនុស្ស ៖ ការការពារសិទ្ធិដើម្បីការពារសិទ្ធិមនុស្ស' (សលាកប័ត្រព័ត៌មាន លេខ ២៩): http://bit.ly/1iFTNUY.

[89] សេចក្តីសម្រេចក្រុមប្រឹក្សាសិទ្ធិមនុស្ស 'ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សក្នុងបរិបទនៃបាតុកម្មដោយសន្តិវិធី,' A/HRC/Res/ 19/35, (ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២): http://bit.ly/1llo3qn.

[90] សេចក្តីព្រាងសេចក្តីពន្យល់ទូទៅលេខ ៣៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស (មាត្រា ៩, សេរីភាព និងសន្តិសុខរបស់បុគ្គល), (ឆ្នាំ២០១៣) ឯកសារ អ.ស.ប CCPR/C/107/R.3, កថាខណ្ឌទី១៧; ក្រុមប្រឹក្សាសិទ្ធិមនុស្ស, សេចក្តីសង្កេតបញ្ចប់លើប្រទេសកាណាដា, (ឆ្នាំ២០០៦) ឯកសារ អ.ស.ប CCPR/C/CAN/CO/5, កថាខណ្ឌទី ២០; គណៈកម្មាធិការសិទ្ធិមនុស្ស, សេចក្តីសង្កេតបញ្ចប់លើប្រទេសម៉ូលដូវ៉ា (ឆ្នាំ២០០៩) ឯកសារ អ.ស.ប CCPR/C/MDA/CO/2, កថាខណ្ឌទី ៨ http://bit.ly/1fbdi3S.

- *ធានាការគោរពសិទ្ធិសេរីភាពខាងការជួបប្រជុំ និងបញ្ឈប់ការហាមឃាត់តាមទំនើងចិត្ត ឬទាំងស្រុងទៅលើការប្រមូលផ្តុំជាសាធារណៈ*
- *បញ្ចប់នូវការអនុវត្តដែលបង្ខំឲ្យអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋពីការអនុវត្តសិទ្ធិមូលដ្ឋាន ខាងការបញ្ចេញមតិ និងខាងការជួបប្រជុំ ពីការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ដែលរឹតត្បិតសិទ្ធិរបស់ពួកគេ ជាថ្នូរនឹងការដោះលែង ឬគេចវេះពីការចោទប្រកាន់*
- *ដោះលែងអ្នកការពារសិទ្ធិមនុស្សដែលត្រូវបានចាប់ខ្លួនតាមទំនើងចិត្ត រួមមាន ទេព វន្នី យ៉ោម បុប្ផា សុង ស្រីលាភ ផាន់ ឈុន រ៉េត អ៊ឹម ស្រីទូច បូវ សោភា និងងួន គីមឡាង។*

## ច. ស្ថានភាពនៃច្បាប់អង្គការ និងច្បាប់សហជីពដ៏ចម្រូងចម្រាស់ នៅតែមិនច្បាស់លាស់

*បញ្ហាទី ២១. សូមផ្តល់ព័ត៌មានស្តីពីការព្យួរសកម្មភាព អង្គការ សមាគមធាងត្នោត ដែលត្រូវបានបញ្ជាដោយក្រសួងមហាផ្ទៃ អស់រយៈពេល ៥ ឆ្នាំ កាលពីខែសីហា ឆ្នាំ២០១១។ សូមផ្តល់ព័ត៌មានបន្ថែម ពីការអះអាងថាក្រសួងការងារបដិសេធក្នុងការចុះបញ្ជីឲ្យសហជីពសេរីកម្មករកម្ពុជា ក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ ក្នុងករណីនេះ សូមបង្ហាញថាស្ថានភាពនៃសេចក្តីព្រាងច្បាប់ដូចខាងក្រោម ៖ (១) សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (កថាខណ្ឌ ទី ១៩៨ នៃរបាយការណ៍ភាគីរដ្ឋ) និង (២) សេចក្តីព្រាងច្បាប់ស្តីពីសហជីព។*

នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១១ ក្រសួងមហាផ្ទៃបានចេញលិខិតទៅកាន់ សមាគមធាងត្នោត ដែលជាអង្គការក្នុងស្រុក ដោយបញ្ជាឲ្យអង្គការនេះ "ព្យួរសកម្មភាពរបស់ខ្លួន" រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១ ក្នុងរយៈពេល ៥ ខែ។ លិខិតនេះមិនបានបញ្ជាក់ពីមូលដ្ឋានផ្នែកច្បាប់ក្នុងការព្យួរនោះទេ ប៉ុន្តែគ្រាន់តែបានចោទប្រកាន់ថាសមាគមធាងត្នោត ខកខានក្នុងការបញ្ជាក់ពីរចនាសម្ព័ន្ធថ្នាក់ដឹកនាំនិងការកែប្រែលក្ខន្តិកៈរបស់ខ្លួន "យោងតាមការបង្គាប់របស់មន្ទីរជំនាញ"។[91] លិខិតនេះមិនបានផ្តល់ការពន្យល់បន្ថែម ដែលបង្ហាញថាការព្យួរអាចនឹងជំរុញដោយគោលបំណងក្នុងការរារាំងសកម្មភាពរបស់អង្គការនេះ ក្នុងការគាំទ្រសហគមន៍ដែលធ្វើការប្រឆាំងនឹងគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនគរូបនីយកម្ម ដែលដឹកនាំដោយរដ្ឋាភិបាល។[92] សមាគមធាងត្នោត ពិតជាបានព្យួរសកម្មភាពរបស់ខ្លួន ជាការឆ្លើយតបទៅនឹងសេចក្តីបង្គាប់នេះ ប៉ុន្តែបន្ទាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ បានបន្តការងាររបស់ខ្លួនវិញ។

រដ្ឋាភិបាលបានផ្សព្វផ្សាយ សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងខែធ្នូ ឆ្នាំ២០១១។[93] សេចក្តីព្រាងច្បាប់ មានចែងពីការចុះឈ្មោះដែលជាកាតព្វកិច្ច និងស្មុគស្មាញ សម្រាប់អង្គការសង្គមស៊ីវិល រួមទាំង ការរឹតត្បិតដោយហួសហេតុទៅលើអង្គការអន្តរជាតិនិងមានចែងពីពាក្យពេចន៍មិនច្បាស់លាស់ជាច្រើន ដែលអាចឲ្យរដ្ឋាភិបាល

---

[91] អូអ៊ឹមស៊ីធី និងសេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិល 'កម្ពុជា ៖ ការព្យួរសកម្មភាពការងាររបស់អង្គការសមាគមធាងត្នោតដោយទំនើងចិត្ត' (ខែសីហា ឆ្នាំ២០១១): http://www.omct.org/human-rights-defenders/urgent-interventions/cambodia/2011/08/d21402/.

[92] សេបាស្ទៀន ស្ត្រេជីអូ 'អង្គការកម្ពុជាស្ថិតក្រោមការគំរាមកំហែង' *អាស៊ី ថាមស៍* (ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១): http://www.atimes.com/atimes/Southeast_Asia/MI20Ae02.html.

[93] អាចមើលបាន : http://bit.ly/1oLiLWS.

ពន្យារ ឬបដិសេធការចុះឈ្មោះរបស់អង្គការសំខាន់ៗមួយចំនួនដោយគ្មានកាលកំណត់។ បន្ទាប់ពីអង្គការសង្គមស៊ីវិលជំទាស់យ៉ាងខ្លាំងទៅលើការបំពានដែលអាចនឹងកើតមានដោយសារការប្រើច្បាប់នេះដើម្បីដៅមុខសញ្ញាដល់អ្នករិះគន់ និងប៉ះពាល់ជាខ្លាំងដល់សេរីភាពខាងការបញ្ចេញមតិ រដ្ឋាភិបាលក៏បានប្តេជ្ញាចិត្តពន្យារសេចក្តីព្រាងច្បាប់នេះ សម្រាប់កិច្ចពិគ្រោះយោបល់បន្ថែម។ ប៉ុន្តែ ក្នុងរយៈពេលថ្មីៗនេះ មន្ត្រីរដ្ឋាភិបាលបានប្រកាសជាច្រើនដង ដែលបញ្ជាក់ថាច្បាប់នេះអាចនឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗខាងមុខ ដោយលើកនូវការព្រួយបារម្ភជាថាច្បាប់នេះអាចនឹងត្រូវបានអនុម័តដោយមិនបានពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល។[94]

សេចក្តីព្រាងច្បាប់ស្តីពីសហជីព ដំបូងត្រូវបានលើកឡើងដោយរដ្ឋាភិបាល ក្នុងឆ្នាំ២០១១ ប៉ុន្តែបានព្យួរទុកបន្ទាប់ពីក្រុមសង្គមស៊ីវិល និងសហជីពបានលើកឡើងពីបញ្ហា រួមទាំង (១) ច្បាប់នេះអាចនឹងធ្វើឲ្យសហជីពងាយរងគ្រោះដោយសារការរំលាយ និងការដកមិនឲ្យចុះឈ្មោះ (២) ច្បាប់នេះមានតម្រូវការដែលអាចជាបន្ទុក និងរើសអើងសម្រាប់បុគ្គលដែលមានបំណងចង់ក្លាយជាថ្នាក់ដឹកនាំសហជីព ថាត្រូវតែមានរបាយការណ៍ស្តីពីការប្រព្រឹត្តិបទល្មើសល្អស្អាត (ជាពិសេសមានការព្រួយបារម្ភថា សកម្មជនផ្នែកកម្មករតែងតែជាគោលដៅនៃនីតិវិធីព្រហ្មទណ្ឌ) និង (៣) ច្បាប់នេះផ្តល់ឲ្យឆន្ទានុសិទ្ធិច្រើនពេកដល់រដ្ឋាភិបាលក្នុងការសម្រេចចិត្តក្នុងវិស័យទាំងនេះ។[95] ថ្វីបើមានការព្រួយបារម្ភទាំងអស់នេះ មានការរាយការណ៍ថារដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការអនុម័តច្បាប់នេះនៅចុង ឆ្នាំ២០១៤[96] ប៉ុន្តែរដ្ឋាភិបាលមិនទាន់បានធ្វើបែបនេះនៅឡើយ។ ស្ថានភាពបច្ចុប្បន្នរបស់ច្បាប់នេះ នៅតែមិនទាន់ច្បាស់លាស់។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *ទប់ស្កាត់ការអនុម័តច្បាប់ស្តីពីសមាគម និងអង្គការ និងច្បាប់ស្តីពីសហជីព ដូចបានលើកឡើងខាងលើ និងរៀបចំកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យ ក្នុងរយៈពេលគ្រប់គ្រាន់សម្រាប់ការវិភាគ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងច្បាប់ ពីសំណាក់ភាគីអ្នកពាក់ព័ន្ធផ្សេងៗ រួមទាំង អង្គការសង្គមស៊ីវិលផងដែរ។*

[94] វេង រដ្ឋាវង្ស, ‘កម្ពុជារៀបចំសេចក្តីព្រាងច្បាប់ស្តីពីអង្គការ’ *ខ្មែរ ថាមស៍* (ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥): http://www.khmertimeskh.com/news/8200/cambodia-prepares-ngo-law/; សូមមើល: ឡាយ, ‘លោកវ៉ុន ៖ អង្គការនឹងត្រូវបានជំរុញឲ្យចេញ’ (ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៤): http://vodhotnews.com/25918.

[95] ម.ស.ម.ក ‘កម្រងឯកសារសេរីភាពមូលដ្ឋាន ៖ សេរីភាពសមាគម និងសមាជិកសហជីព’ (ខែមករា ឆ្នាំ២០១៤): http://bit.ly/1h4r2zh.

[96] ហ៊ុល រស្មី និង ខូលីន ម៉េយ៍, ‘ច្បាប់ស្តីពី សហជីពរបស់រដ្ឋាភិបាលអាចនឹងកំហិតសេរីភាពនៃការប្រមូលផ្តុំ’ *សារព័ត៌មាន ខេមបូឌា ដេលី,* (ថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៤): http://bit.ly/1fUIhDq.

## ៦. សិទ្ធិកុមារ ( មាត្រា ៧ និង មាត្រា ២៤ នៃ ក.អ.ស.ព.ន )

### ក. កង្វះខាតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កុមារ

*បញ្ហាទី ២៣. សូមបញ្ជាក់ថាតើរដ្ឋភាគីមានចាត់វិធានការណាខ្លះដើម្បីរៀបចំប្រព័ន្ធយុត្តិធម៌អនីតិជន ស្របទៅតាមបទដ្ឋានអន្តរជាតិ។*

ច្បាប់ស្តីពីយុត្តិធម៌សម្រាប់អនីតិជនត្រូវបានរៀបចំសេចក្តីព្រាងដំបូង ក្នុងឆ្នាំ ២០០២ ប៉ុន្តែនៅមិនទាន់បានអនុម័តនោះទេ។ ដូច្នេះ ប្រទេសកម្ពុជាពុំមានច្បាប់ដាច់ដោយឡែកកំណត់ពីសិទ្ធិរបស់កុមារនោះទេ។ ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ រួមមានបញ្ញត្តដែលធានាការប្រព្រឹត្តិផ្សេងពីនោះ ចំពោះអនីតិជននោះទេ។ មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ផ្តល់ការការពារជាទូទៅ ដល់អនីតិជនដែលប្រព្រឹត្តបទល្មើស និងមិនមានការប្តេជ្ញាចិត្តមុះមុតក្នុង "ការតាមដាន ការអប់រំ ការការពារ និងការឧបត្ថម្ភ" ដល់អនីតិជន។ ប៉ុន្តែ នៅមិនទាន់មាននីតិវិធីជាក់លាក់ណាមួយសម្រាប់អនីតិជននោះទេ ហើយបញ្ញត្តភាគច្រើនក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលសំដៅទៅលើអនីតិជន តែងលើកឡើងយ៉ាងសង្ខេប និងមិនបានកំណត់ឲ្យច្បាស់លាស់ ដើម្បីអាចប្រើប្រាស់ជាមគ្គុទេសក៍សម្រាប់គ្រប់គ្រងប្រព័ន្ធយុត្តិធម៌អនីតិជន។ បន្ថែមពីលើនោះ ការការពារផ្នែកច្បាប់ និងផ្នែកនីតិវិធីដែលមានស្រាប់ តែងមិនត្រូវបានគោរពក្នុងការអនុវត្ត។ រដ្ឋាភិបាលមិនបានចាត់វិធានការដើម្បីផ្តល់សំណងចំពោះភាពខ្វះចន្លោះនេះទេ។

កង្វះការយល់ដឹងក្នុងចំណោមអ្នកគ្រប់គ្រងប្រព័ន្ធយុត្តិធម៌អនីតិជនរួមទាំងចៅក្រមផងដែរនោះ ដូចជាការប្រព្រឹត្តិចំពោះកុមារត្រូវខុសពីការប្រព្រឹត្តិចំពោះមនុស្សធំ និងតម្រូវការចាំបាច់ឲ្យមានការបណ្តុះបណ្តាល ការយល់ដឹង និងធនធានឲ្យបានល្អប្រសើរជាងមុន។[97] ក្នុងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌដែលចែងពីចៅក្រមត្រូវបានផ្តល់ឆន្ទានុសិទ្ធិទូលាយពេកដែលអនុញ្ញាតឲ្យចៅក្រម "អាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ ឆ្នាំ ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ"។ ចំណុចនេះអនុញ្ញាតឲ្យចៅក្រមដាក់ទណ្ឌកម្មព្រហ្មទណ្ឌទៅលើកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ដូចនឹងមនុស្សធំដែរ។ ការរួមចំណែកចំពោះបញ្ហានេះ គឺជាកង្វះវិធីសាស្រ្តក្នុងការបញ្ជាក់អាយុរបស់កុមារ ដោយសារតែចំណាកស្រុក ការបណ្តេញចេញដោយបង្ខំ ឬដោយសារតែអាជ្ញាធរ ខកខានក្នុងការផ្តល់ឯកសារចុះបញ្ជីកំណើត។[98]

ច្បាប់ជាតិកម្ពុជា និងនីតិវិធី នៅក្នុងទ្រឹស្តី ចែងពីការការពារខ្លះៗ ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នសម្រាប់អនីតិជន។ មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានហាមឃាត់ដោយបើកចំហថាមិនឲ្យមានការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នសម្រាប់អនីតិជនក្រោមអាយុ ១៤ ឆ្នាំ។ ចំណែកឯមាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នសម្រាប់បុគ្គលដែលមានអាយុចាប់ពី ១៤ ដល់ ១៨ ឆ្នាំ ហើយមិនគាំទ្រឲ្យមានការឃុំខ្លួននោះទេ។ ដោយអនីតិជនចំនួន ៨៧% ស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្ន ធ្វើឲ្យការគ្រប់គ្រងយុត្តិធម៌អនីតិជនខកខានក្នុង

---

[97] ម.ស.ម.ក ‘កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា’ (ខែតុលា ឆ្នាំ២០១៤), http://bit.ly/1tyeTpq.

[98] ដូចខាងលើ ៥។

ការគោរពតាមច្បាប់អន្តរជាតិ។[99] តំណាងតុលាការ បានបញ្ជាក់ថាមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន គឺដោយសារភាពធ្ងន់ធ្ងរនៃបទល្មើស កង្វះខាតទីលំនៅជាក់លាក់របស់ចុងចោទ បុគ្គលខ្លះកុហកពីអាយុ ការប្រឈមមុខនឹងបទល្មើសផ្សេងទៀត និងកង្វះធនធានក្នុងការតាមដានចុងជាប់ចោទ។ ចំណុចនេះបញ្ជាក់ថាអត្រាឡើងខ្ពស់នៃការឃុំខ្លួនបណ្តោះអាសន្នជាលទ្ធផលនៃកង្វះធនធាន និងការគាំទ្រផ្នែកសង្គម និងរចនាសម្ព័ន្ធ ដើម្បីអនុញ្ញាតឲ្យមានជម្រើសផ្សេងទៀត។[100]

ទិន្នន័យនៃការសង្កេតការណ៍សវនាការ បង្ហាញថាប្រព័ន្ធតុលាការខកខានក្នុងការធានាសិទ្ធិឯកជនភាពរបស់អនីតិជន។ វិធានការដើម្បីការពារសិទ្ធិឯកជនភាព ត្រូវបានអនុវត្តតែ ៣ ករណី ក្នុងចំណោមករណី ២១៩ ផ្សេងទៀតដែល ម.ស.ម.ក បានសង្កេតការណ៍។[101] ជាធម្មតា មិនមានបន្ទប់តុលាការត្រូវបានចាត់ចែងសម្រាប់ករណីដែលពាក់ព័ន្ធនឹងអនីតិជននោះទេ ដែលនឹងការពារសាធារណជនមិនឲ្យចូលមើលបាន (លើកលែងតែឪពុកម្តាយ និងអាណាព្យាបាលរបស់អនីតិជននោះ)។ មិនមានការអនុវត្តជាក់ស្តែង ក្នុងការប្រើប្រាស់ឧបករណ៍ដូចជា ប្រព័ន្ធឆ្លងឆ្លើយតាមខ្សែវីដេអូដែលអាចបង្កើនការការពារឯកជនភាពសម្រាប់អនីតិជន។ ទោះបីជា ប្រព័ន្ធឆ្លងឆ្លើយតាមខ្សែវីដេអូ ត្រូវបានតំឡើងក្នុងបន្ទប់សវនាការខ្លះក៏ដោយ ក៏តាមការសង្កេតការណ៍របស់ ម.ស.ម.ក បានបង្ហាញថាប្រព័ន្ធទាំងនោះមិនដែលត្រូវបានប្រើប្រាស់នោះទេ។

ច្បាប់ជាតិ ចែងថាតុលាការមានឆន្ទានុសិទ្ធិពេញលេញក្នុងការដាក់ទោសលើអនីតិជន។ ទោះបីជាមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបានលើកឡើងពីទោសមិនជាប់ពន្ធនាគារសម្រាប់អនីតិជនដោយបញ្ជាក់ថាអនីតិជនដែលប្រព្រឹត្តបទល្មើសគួរតែដាក់ឲ្យស្ថិតក្រោមវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការការឧបត្ថម្ភ ចំណុចនេះក៏អនុញ្ញាតឲ្យមានទោសទណ្ឌព្រហ្មទណ្ឌប្រសិនបើ *"ស្របតាមកាលៈទេសៈតម្រូវ"* ។ នៅពេលដែលតុលាការខ្វះខាតនូវការបណ្តុះបណ្តាល និងការយល់ដឹងពីចំណុចក្តៅ នៅពេលដោះស្រាយរឿងអនីតិជន លទ្ធផលដែលបានមកគឺករណីស្ទើរតែទាំងអស់ត្រូវបញ្ចប់ដោយការដាក់ទោសឲ្យជាប់ពន្ធនាគារ។ ម.ស.ម.ក មានព័ត៌មានតែមួយករណីប៉ុណ្ណោះ ក្នុងអំឡុងការសង្កេតការណ៍សវនាការដែលចៅក្រមបានពិចារណាលើការដាក់ទោសដែលមិនតម្រូវឲ្យជាប់ពន្ធនាគារទៅលើជនជាប់ចោទជាអនីតិជន។ ក្នុងករណីនេះ ទោះបីជាចៅក្រមបានដាក់ទោសឲ្យអនីតិជននោះជាប់ពន្ធនាគារ ៣ ឆ្នាំ ៦ ខែ ប៉ុន្តែ ចៅក្រមបានសម្រេចព្យួរទោសចំនួន ៣ ឆ្នាំ។[102] តួលេខទាំងនេះ បណ្តាលឲ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរ និងការជំទាស់នឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ទិន្នន័យដែលប្រមូលបានអាចបញ្ជាក់ពីកង្វះធនធានផ្នែកសង្គម និងតុលាការ និងរចនាសម្ព័ន្ធដើម្បីជួយគាំទ្រតុលាការក្នុងការអនុវត្តច្បាប់។ តំណាងតុលាការ បានពន្យល់ថាតុលាការមានគោលបំណងប្រកាសទោសមិនដាក់ពន្ធនាគារលើចុងចោទដែលជាអនីតិជនដែរ ប៉ុន្តែការធ្វើបែបនោះមានចំណុចពិបាកជាច្រើន ដោយសារតែកង្វះខាតវិធីគ្រប់គ្រងច្បាស់

---

[99] ដូចខាងលើ ៥។

[100] ចំណុចនេះត្រូវបានរាយការណ៍ដោយចៅក្រមជាច្រើននាក់នៅក្នុងកិច្ចប្រជុំមិនផ្លូវការ និងសម្ភាសន៍រវាងក្រុមការងារ ម.ស.ម.ក និងចៅក្រមនៅតុលាការខេត្តរតនៈគិរី និងតុលាការខេត្តបន្ទាយមានជ័យ (ថ្ងៃទី១០ – ១៤ ខែកញ្ញា ឆ្នាំ២០១២) និងចៅក្រមនៅតុលាការក្រុងភ្នំពេញ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២)។

[101] ដូចខាងលើ ៧។

[102] ដូចខាងលើ ៨។

លាស់។[103] ជាងនេះទៅទៀត ឧទាហរណ៍ដូចជា មជ្ឈមណ្ឌលស្តារនីតិសម្បទាយុវជន មិនត្រូវបានប្រើការច្រើននោះទេ ដោយសារតែខ្វះខាតមូលនិធិ និងគាំទ្រសម្រាប់កម្មវិធីយុត្តិធម៌សម្រាប់អនីតិជន។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *រដ្ឋាភិបាលអនុម័តសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌របស់អនីតិជនឲ្យបានឆាប់ជាអាទិភាព។ សេចក្តីណែនាំសមស្រប មួយត្រូវតែបានបង្កើតឡើងព្រមជាមួយច្បាប់នោះ ស្តីពីការអនុវត្តវិធាននៃប្រព្រឹត្តចំពោះអនីតិជនខុសពីការប្រព្រឹត្តិចំពោះនីតិជនដ៏ទៃទៀត ឧទាហរណ៍ ស្តីពីបញ្ហាឯកជនភាព ការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្ន និងទោសទណ្ឌ ហើយដែលការបង្កើតនេះគួរតែមានកិច្ចពិគ្រោះយោបល់ ជាមួយអ្នកអនុវត្តច្បាប់ និងសង្គមស៊ីវិល*
- *ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនគួរតែប្រើក្នុងកាលៈទេសៈលើកលែងបំផុត*
- *ចៅក្រម និងព្រះរាជអាជ្ញាចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន*
- *មិនគួរអនុញ្ញាតឲ្យសាធារណជនចូលក្នុងសវនាការដែលមានពាក់ព័ន្ធនឹងនីតិជន និងត្រូវមានការរឹតបន្តឹងលើការផ្សាយព័ត៌មានផងដែរ*
- *អនីតិជនទាំងអស់ត្រូវតែផ្តល់សិទ្ធិឲ្យមាននីតិជនដ៏សមរម្យ (ឪពុកម្តាយ អាណាព្យាបាល និងបុគ្គលផ្សេងទៀតដែលសមរម្យ ដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើង) មានវត្តមានក្នុងអំឡុងពេលការសាកសួររបស់នគរបាល និងនៅគ្រប់ដំណើរការសវនាការរបស់តុលាការ។*
- *ការដាក់ទោសជាប់ពន្ធនាគារទៅលើអនីតិជន គួរតែត្រូវបានអនុវត្តក្នុងករណីដែលធ្ងន់ធ្ងរបំផុតតែប៉ុណ្ណោះ ក្នុងករណីដែលទម្រង់នៃការដាក់ទោសផ្សេងទៀតត្រូវបានពិចារណារួចរាល់ហើយ ឬនៅពេលដែលការដាក់ទោសត្រូវបានតម្រូវក្នុងហេតុផលការការពារសាធារណៈ។ គួរតែផ្តោតទៅលើការស្តារនីតិសម្បទា ជាជាងការដាក់ទារុណកម្មតែម្យ៉ាង។*

---

[103] ចំណុចនេះត្រូវបានរាយការណ៍ ដោយចៅក្រមជាច្រើននាក់នៅក្នុងកិច្ចប្រជុំមិនផ្លូវការ និងសម្ភាសន៍រវាងក្រុមការងារ ម.ស.ម.ក និងចៅក្រមនៅតុលាការខេត្តរតនៈគិរី និងតុលាការខេត្តបន្ទាយមានជ័យ (ថ្ងៃទី១០ – ១៤ ខែកញ្ញា ឆ្នាំ២០១២) និងចៅក្រមនៅតុលាការក្រុងភ្នំពេញ (ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២)។

## ៧. ការចូលរួមក្នុងកិច្ចការសាធារណៈ (មាត្រា ២៥ នៃ ក.អ.ស.ព.ន)

### ក. កង្វះខាតឯករាជ្យភាពនៃគណៈកម្មការជាតិបោះឆ្នោត

*បញ្ហាទី ២៦. យោងតាមព័ត៌មានដែលចែងក្នុងកថាខណ្ឌទី ២២៧ ដល់ ២៤០ នៃរបាយការណ៍របស់ភាគីរដ្ឋ សូមផ្តល់ព័ត៌មានលម្អិតស្តីពីយន្តការ ដែលមានស្រាប់ក្នុងរដ្ឋភាគី ដើម្បីធានាថាមានការបោះឆ្នោតដោយតម្លាភាព និងយុត្តិធម៌។ យោងតាមអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អនុសាសន៍ភាគច្រើនរបស់លោក ពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធបោះឆ្នោត មិនទាន់បានអនុវត្តតាមនោះទេ។ សូមផ្តល់យោបល់។ សូមបញ្ជាក់ផងដែរថាតើមានការស៊ើបអង្កេត ឬការដាក់ទោសណាខ្លះ ពាក់ព័ន្ធនឹងការអះអាងពីភាពខុសប្រក្រតីជាច្រើន រួមទាំងភាពលម្អៀងរបស់យន្តការប្រព័ន្ធបោះឆ្នោត ក្នុងអំឡុងការបោះឆ្នោតថ្នាក់ជាតិ ឆ្នាំ២០១៣។*

ម.ស.ម.ក បានសង្កេតឃើញចំណុចខ្វះខាតជាច្រើនក្នុងដំណើរការ និងស្ថាប័នបោះឆ្នោតនៅកម្ពុជា រួមទាំងកង្វះឯករាជ្យភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត("គ.ជ.ប")។[104] បន្ទាប់ពីមានការរាយការណ៍ពីភាពមិនប្រក្រតីជាច្រើនក្នុងការរៀបចំការបោះឆ្នោតឆ្នាំ២០១៣[105] ដូចបានកត់សម្គាល់ដោយអ្នករាយការណ៍ពិសេសគ.ជ.ប បានរៀបចំធ្វើការស៊ើបអង្កេតពាក្យបណ្តឹងមួយចំនួន តែក៏បានទម្លាក់ចោលពាក្យបណ្តឹងទាំងនោះផងដែរ។[106] ចំណុចនេះគួរឲ្យព្រួយបារម្ភដោយសារថាគ.ជ.ប ដែលបានលើកឡើងខាងលើ មិនមានឯករាជ្យភាព និងកម្រិតនៃការជឿជាក់មកលើស្ថាប័ននេះគឺតិចតួចបំផុតក្នុងចំណោមសាធារណជន។ ក្នុង *'លទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា - ឆ្នាំ២០១៤ : ការស្ទង់មតិស្តីពីប្រព័ន្ធបោះឆ្នោតនៅប្រទេសកម្ពុជា'*[107] មូលនិធិអាស៊ីបានរៀបចំធ្វើការស្ទង់មតិសាធារណជនលើកទី ៣ ស្តីពីប្រជាធិបតេយ្យនៅកម្ពុជា។ គោលបំណងនៃការស្ទង់មតិនេះ ដើម្បីវាយតម្លៃអាកប្បកិរិយា និងអាទិភាពចំពោះការបោះឆ្នោតជាសាធារណៈ ដែលអាចនឹងរួមចំណែក ឬរារាំងកំណែទម្រង់លទ្ធិប្រជាធិបតេយ្យ។ នៅពេលដែលសាកសួរអំពី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានត្រឹមតែ ៣២% ប៉ុណ្ណោះ ដែលពេញចិត្តនឹងការងាររបស់គណៈកម្មាធិការនេះ និង ២៥% ដែលជឿជាក់ថាគណៈកម្មាធិការនេះមិនរងឥទ្ធិពលពីគណបក្សនយោបាយ។[108] បន្ទាប់ពីរយៈពេលជិតមួយឆ្នាំ នៃការជាប់គាំងនយោបាយក្រោយពីមានជម្លោះក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ប្រ.ជ គណបក្សកាន់អំណាច និង គ.ស.ជ គណបក្សប្រឆាំង

---

[104] ម.ស.ម.ក 'ពង្រឹងការអនុវត្តប្រជាធិបតេយ្យ និងដំណើរការបោះឆ្នោតនៅកម្ពុជា៖ របាយការណ៍ស្តីពីវេទិកាលំហប្រជាធិបតេយ្យ និងការបោះឆ្នោត' (ឆ្នាំ២០១១)៖ http://www.cchrcambodia.org/admin/media/report/report/english/2011-07-20-report-eng.pdf; សូមអាន ៖ ម.ស.ម.ក 'កំណត់ត្រាសង្ខេប៖ កំណែទម្រង់ផ្នែកនយោបាយ និងបោះឆ្នោតនៅកម្ពុជា' (ឆ្នាំ២០១៣)៖ http://www.cchrcambodia.org/admin/media/analysis/analysis/english/2013_02_11_CCHR%20Briefing%20Note%20Electoral%20and%20Political%20Reform_Eng_u.pdf; ម.ស.ម.ក 'របាយការណ៍លទ្ធផល ៖ សិក្ខាសាលាស្តីពីយុវជន និងកំណែទម្រង់ការបោះឆ្នោត' (ឆ្នាំ២០១៣)៖ http://cchrcambodia.org/admin/media/report/report/english/2014_08_19_CCHR_Outcome_Report_Workshop_for_youth_on_electoral_reform_%28ENG%29.pdf.

[105] តម្លាភាពអន្តរជាតិ កម្ពុជា និងសម្ព័ន្ធដើម្បីបូរណភាព និងគណនេយ្យភាពសង្គម 'ការសង្កេតលើការបោះឆ្នោតចុងក្រោយរបស់ការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០១៣' (ខែកញ្ញា ឆ្នាំ២០១៣): http://bit.ly/1oLjGXc.

[106] របាយការណ៍របស់អ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, លោក សូរិយា ភី. ស៊ូប៊េឌី, A/HRC/27/70, (ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៤) កថាខណ្ឌ ទី១១។

[107] មូលនិធិអាស៊ី "*លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា - ឆ្នាំ២០១៤* ៖ ការស្ទង់មតិស្តីពីការបោះឆ្នោតនៅកម្ពុជា' *(ឆ្នាំ២០១៤)*៖ https://asiafoundation.org/resources/pdfs/DemocracyinCambodia2014.pdf.

[108] ដូចខាងលើ ទំព័រទី ៥១។

បានឈានដល់កិច្ចព្រមព្រៀងនយោបាយនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ គ.ស.ជ យល់ព្រមទទួលយកអាសនៈក្នុងរដ្ឋសភា និងធ្វើការជាមួយ ប្រ.ជ ដើម្បីធ្វើកំណែទម្រង់សំខាន់ៗមួយចំនួន រួមទាំង កំណែទម្រង់ គ.ជ.ប។ ការចាប់ខ្លួនរបស់ មាច សុវណ្ណារ៉ា ទេព ណារិន និងសមាជិកដទៃទៀតរបស់ គ.ស.ជ ក្នុងចំណោមការចោទចោបង្ហាញថាករណីនេះពាក់ព័ន្ធនឹងរឿងនយោបាយ។ នៅថ្ងៃទី១៥ ខែវិច្ឆិកា អ្នកនាំពាក្យក្រសួងមហាផ្ទៃ ខៀវ សុភ័ក្រ្ត បានរាយការណ៍ថាបានបញ្ជាក់ថា ប្រសិនបើគណបក្សប្រឆាំងយល់ព្រមសហការណ៍ក្នុងរឿងកំណែទម្រង់គ.ជ.ប មាច សុវណ្ណារ៉ា អាចនឹងមិនចាំបាច់ត្រូវជាប់នៅក្នុងពន្ធនាគាររយៈពេលយូរនោះទេ។[109]

ក្នុងខែតុលា ឆ្នាំ២០១៤ សមាជិករដ្ឋសភា បោះឆ្នោតធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ដើម្បីធ្វើឲ្យគ.ជ.ប ជាស្ថាប័នគោរពតាមរដ្ឋធម្មនុញ្ញដោយអនុវត្តច្បាប់ដែលជាប្រធានបទនៃការចោទចោក្នុងពេលថ្មីៗនេះ។[110]

## ខ. ការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិរបស់អង្គការ ក្នុងអំឡុងការបោះឆ្នោត

### *បញ្ហាទី ២៦ [បន្ត]*

ក្នុងខែមករា ឆ្នាំ២០១៥ ឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន នៃ ប្រ.ជ និងលោក គួយ ប៊ុនរឿន នៃ គ.ស.ជ ត្រូវរាយការណ៍ថាបានបញ្ជាក់ថាវិធានការដែលបានហាមឃាត់បុគ្គលិកអង្គការសង្គមស៊ីវិល ពីការផ្តល់បទសម្ភាសន៍ ឬក៏ចេញសេចក្តីថ្លែងការណ៍ដែលហាក់ដូចជា "ប្រមាថ" ដល់គណបក្សនយោបាយ ក្នុងអំឡុងការបោះឆ្នោត ត្រូវបានពិចារណាដើម្បីធានាថាគណបក្សនយោបាយឯករាជ្យពីអង្គការ។[111] ជាការឆ្លើយតប ម.ស.ម.ក រួមជាមួយនឹងអង្គការសង្គមស៊ីវិលកម្ពុជាមួយចំនួនបានអំពាវនាវឲ្យរដ្ឋាភិបាល និងគណបក្សនយោបាយគោរពសិទ្ធិសេរីភាពខាងការបញ្ចេញមតិ[112] ដោយដកស្រង់ពីសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្សថានៅក្នុងបរិបទការជជែកវែកញែកផ្នែកនយោបាយ ក.អ.ស.ព.ន បានឲ្យតម្លៃខ្ពស់ទៅលើការបញ្ចេញមតិដោយគ្មានការហាមឃាត់ និងអះអាងថាបើគ្រាន់តែ "អង្គហេតុតិចតួចនៃការបញ្ចេញមតិ ត្រូវបានចាត់ទុកថាជាការប្រមាថដល់បុគ្គលសាធារណៈនោះ មិនទាន់គ្រប់គ្រាន់ក្នុងការកំណត់ការដាក់

---

[109] ឆាយ ចន្ទនីដា និង មាស សុខជា 'ការចាប់ខ្លួន គ.ស.ជ នៅបន្ត' *សារព័ត៌មាន ភ្នំពេញ ប៉ុស្តិ៍,* (ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤)៖ http://www.phnompenhpost.com/national/cnrp-arrests-continue.

[110] ហេង រស្មី, 'រដ្ឋធម្មនុញ្ញកម្ពុជាធ្វើវិសោធនកម្មដើម្បីពង្រឹង 'ឯករាជ្យភាព' របស់ស្ថាប័នបោះឆ្នោត,' *វីអូអេ,* (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤): http://www.voanews.com/content/cambodian-constitution-amended/2469307.html; សូមអាន ៖ របាយការណ៍ប្រចាំសប្តាហ៍ អាសអេចអែស ជេន, 'ការផ្លាស់ប្តូររដ្ឋធម្មនុញ្ញដើម្បីការពារឯករាជ្យភាពរបស់គណៈកម្មការបោះឆ្នោត អាចនឹងបន្ថយអស្ថេភាពនយោបាយ' (ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤)៖ http://www.janes.com/article/43974/constitutional-change-to-secure-election-commission-s-independence-in-cambodia-likely-to-reduce-political-instability; គុច ណារ៉ែន, 'កំណែទម្រង់គណៈកម្មការបោះឆ្នោត អាចនឹងត្រូវបានពន្យារដោយសារតែការនិយាយមិនចុះសម្រុង' *សារព័ត៌មាន ខេមបូឌា ដេលី,* ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥៖ https://www.cambodiadaily.com/news/reformed-election-commission-likely-to-be-delayed-by-stalled-talks-76749/.

[111] គុជ ណារ៉ែន 'អង្គការនឹងត្រូវកំហិតក្នុងអំឡុងការឃោសនាបោះឆ្នោត' *សារព័ត៌មាន ខេមបូឌា ដេលី* (ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៥) ៖ https://www.cambodiadaily.com/news/ngos-to-be-restricted-during-election%E2%80%88campaigns-76343/.

[112] ម.ស.ម.ក អាដហុក ពន្លកខ្មែរ លីកាដូ សមធម៌កម្ពុជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច និងគណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា 'អង្គការសង្គមស៊ីវិល អំពាវនាវឲ្យរដ្ឋាភិបាល និងគណបក្សនយោបាយឲ្យគោរពសេរីភាពបញ្ចេញមតិ' (ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៤) ៖ http://www.cchrcambodia.org/index_old.php?url=media/media.php&p=press_detail.php&prid=534&id=5&lang=eng.

ទោសទណ្ឌនោះទេ"។[113] គណៈកម្មាធិការនេះក៏បានបញ្ជាក់ផងដែរថា "រាល់បុគ្គលសាធារណៈទាំងអស់ រួមទាំងអ្នកដែលមានអំណាចផ្នែកនយោបាយខ្ពស់បំផុតដូចជាប្រមុខរដ្ឋ និងរដ្ឋាភិបាល ក៏អាចជាកម្មវត្ថុនៃការរិះគន់ និងប្រឆាំងផ្នែកនយោបាយដោយស្របច្បាប់"។[114] វិធានការបែបនេះចាកឆ្ងាយពីការធ្វើឲ្យមានការបោះឆ្នោតដោយតម្លាភាព និងយុត្តិធម៌ ហើយមិនមែនត្រឹមតែរឹតត្បិតការជជែកពិភាក្សាសាធារណៈនោះទេ ថែមទាំងរំលោភដល់សិទ្ធិពលរដ្ឋដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយរបស់ប្រទេសជាតិ និងធ្វើឲ្យប៉ះពាល់ដល់តួនាទីស្របច្បាប់របស់អង្គការសង្គមស៊ីវិលក្នុងការទាមទារ ឲ្យអាជ្ញាធរសាធារណៈទទួលខុសត្រូវប៉ុណ្ណោះ។

*គណៈកម្មាធិការសិទ្ធិមនុស្សគួរតែពិចារណាផ្តល់អនុសាសន៍ឲ្យរដ្ឋាភិបាល ៖*

- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គួរតែមានឯករាជ្យពេញលេញ*
- *រដ្ឋាភិបាលធានានូវសេរីភាពខាងការបញ្ចេញមតិ របស់សង្គមស៊ីវិលគ្រប់ពេលទាំងអស់រួមទាំងក្នុងពេលបោះឆ្នោតផងដែរ*

[113] ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប, សេចក្តីពន្យល់ទូទៅលេខ ៣៤ (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) កថាខណ្ឌទី ៣៨៖ http://bit.ly/1xmySgV
[114] ដូចខាងលើ។

## ៨. អំពីអង្គភាពដែលបានដាក់ស្នើរបាយការណ៍នេះ

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា** ("ម.ស.ម.ក") ត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ដែលជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ ឈានមុខមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។ យើងធ្វើការផ្តល់អំណាចដល់សង្គមស៊ីវិល ដើម្បីទទួលបានសិទ្ធិ និងដឹកនាំការផ្លាស់ប្តូរ។ តាមរយៈការស្រាវជ្រាវ និងការវិភាគយ៉ាងលម្អិត យើងបង្កើតនូវគោលនយោបាយថ្មីៗ និងធ្វើការតស៊ូមតិឲ្យមានការអនុវត្ត។ ទស្សនៈវិស័យរបស់យើង គឺកម្ពុជាគ្មានអំពើហិង្សា ដែលប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋាន មានសិទ្ធិស្មើគ្នា និងត្រូវបានផ្តល់អំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានការចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍប្រទេសកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្ម ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម សមាជិកនៃដៃគូសន្ធនាអន្តរជាតិ ដើម្បីសេរីភាពខាងការបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពខាងការបញ្ចេញមតិ សមាជិកនៃសម្ព័ន្ធអ្នកសារព័ត៌មានអាស៊ី អាគ្នេយ៍ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមរបស់ពលរដ្ឋ។

**អង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្ម** ត្រូវបានបង្កើតក្នុង ឆ្នាំ១៩៨៥ ហើយមកដល់បច្ចុប្បន្ននេះគឺជាសម្ពន្ធអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិដ៏ធំមួយដែលធ្វើការប្រឆាំងនឹងការធ្វើទារុណកម្ម ការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួនដោយបង្ខំ និងការប្រព្រឹត្តដោយឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាបដទៃទៀត។ ដោយមានសមាជិកចំនួន ៣១១ និងបណ្តាញអេសអូអេស ប្រឆាំងទារុណកម្ម និងដៃគូការងាររាប់ពាន់អ្នកទៀតនៅលើពិភពលោក អង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្ម គឺជាបណ្តាញដ៏សំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដើម្បីការពារ និងលើកកម្ពស់សិទ្ធិមនុស្សនៅក្នុងពិភពលោក។

លេខាធិការអន្តរជាតិរបស់អង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្ម ផ្តល់ការគាំពារផ្នែកវេជ្ជសាស្ត្រដល់បុគ្គល ជំនួយផ្នែកច្បាប់ និងផ្នែកសង្គមទៅដល់ជនរងគ្រោះដែលរងទារុណកម្ម និងជានាំឲ្យមានការផ្សព្វផ្សាយជាប្រចាំនូវអន្តរាគមន៍បន្ទាន់ដទៃទៀតនៅជុំវិញពិភពលោក ដើម្បីការពារបុគ្គល និងប្រឆាំងនឹងនិទណ្ឌភាព។

កម្មវិធីជាក់លាក់អនុញ្ញាតឲ្យអង្គការនេះផ្តល់ជំនួយទៅកាន់ក្រុមមនុស្សងាយរងគ្រោះបានយ៉ាងជាក់លាក់ ដូចជាស្ត្រី កុមារ និងអ្នកការពារសិទ្ធិមនុស្ស។ ក្នុងក្របខណ្ឌសកម្មភាពរបស់ខ្លួន អង្គការពិភពលោកប្រឆាំងនឹងការធ្វើទារុណកម្មក៏បានដាក់បញ្ជូនការរាយការណ៍របស់បុគ្គល និងរបាយការណ៍ផ្សេងទៀតទៅកាន់យន្តការរបស់អង្គការសហប្រជាជាតិ និងសហការយ៉ាងសកម្ម ក្នុងការគោរព អភិវឌ្ឍន៍ និងពង្រឹងបទដ្ឋានអន្តរជាតិក្នុងការការពារសិទ្ធិមនុស្ស។